00815194

E1/84.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 12-Jun-2012, 14:52

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៧២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោកស្រី ណាតាចា វ៉ីស៊ែល រីស៊ើ

*(Ms. Natacha WEXELS-RISER)*

លោក ម៉ាតេអូ គ្រីប៉ា

*(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោក ហុង គីមសួន

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោក សំ សុគង់

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វ៉េកគែន | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក បាណាបេ ណោគ្វី | បារាំង |
| លោក សៅ សារុន (TCW-604) | ខ្មែរ |
| លោក ខឹម ងន (TCW-323) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក សៅ សារុន** (TCW-604)

សួរបន្តដោយលោក ឌេល លីសាក់ ផ្ដើមពី៖........................................................................ ទំព័រ ២

សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្ដើមពី៖ ......................................................................ទំព័រ ៤០

**ការសួរសំណួរទៅសាក្សី÷ លោក ខឹម ខន** (TCW-323)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី៖......................................................ទំព័រ ៥០

សួរដោយលោក ឡៅ ជុនធី ផ្ដើមពី៖ ...........................................................................ទំព័រ ៦៣

សួរដោយលោក បាណាបេ ណេគ្វី ផ្ដើមពី៖.....................................................................ទំព័រ ៧១

សួរដោយលោក ម៉ៃខល ផេសមិន ផ្ដើមពី៖.....................................................................ទំព័រ ៧៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៥]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងចាប់ផ្តើមដំណើរការ សូមលោកក្រឡាបញ្ជី ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចសវនាការនៅថ្ងៃនេះ ទាំងសាក្សីបម្រុងផងប្រសិនបើមាន។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី គាត់មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ នៅចំពោះមុខអង្គជំនុំជម្រះ សម្រាប់រយៈពេលពេញមួយថ្ងៃនៅថ្ងៃនេះ។

[០៩:០៤:០៥]

លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ អៀង សារី បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកសាក្សីបម្រុងឈ្មោះ ខឹម ងន គាត់មានវត្តមាននៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយគាត់សុំនៅតាមកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិន

អាចអង្គុយតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

[០៩:០៥:០១]

អង្គជំនុំជម្រះយល់ឃើញថា ពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចដំណើរការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បាន។

ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។ ហើយបង្គាប់ឲ្យមន្ត្រីផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចមានលទ្ធភាពតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៦:០៣]

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយសូមជម្រាបសួរលោកសាក្សី សៅ សារុន។

**ការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** កាលពីសប្តាហ៍មុនយើងបញ្ឈប់ត្រង់ចំណុចមួយ នៅពេលដែលយើងជជែកអំពីការប្រជុំដែលលោកបានចូលរួមនៅភ្នំពេញ ហើយដែលទាក់ទងទៅនឹងទំនាក់ទំនង ប្រាស្រ័យទាក់ទងដែលលោកបានធ្វើជាមួយ ខៀវ សំផន។ ហើយខ្ញុំនឹងសួរលោកបន្ថែមទៀតអំពីបញ្ហាដែលថាលោកបានដាក់សំណើសុំឧបករណ៍ សុំសម្ភារៈផ្សេងៗ។ ថាតើលោកអាចប្រាប់ខ្ញុំបានទេ ថាតើលោកស្នើសុំសម្ភារៈឧបករណ៍

ផ្សេងៗទៅមេដឹកនាំភ្នំពេញហ្នឹង លោកស្នើសុំញឹកញាប់ប៉ុនណាដែរ?

[០៩:០៧:១៥]

**លោក សៅ សារុន៖**

**ឆ៖** បាទ គេបាន-- មិនបានសុំញឹកញាប់ទេ គឺតាមជួនកាលមួយឆ្នាំ គឺសុំមួយគ្រប់មួយឆ្នាំៗ។

**ស៖** តើប៉ុន្មានដងដែលលោកចាំនោះ ដែលលោកដាក់សំណើសុំជូនទៅលោក ខៀវ សំផន នោះបាទ?

**លោក អាកទ្វូរ វែកគែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អាកទ្វូរ វែកគែន៖**

បាទ លោកប្រធាន សូមអរគុណ។ នេះគឺជាសំណួរដដែល។ សាក្សីនេះបានឆ្លើយតបទៅនឹងសំណួរនេះហើយ លោកប្រធាន។

[០៩:០៨:២៥]

**លោក ឌេល លីសាក់៖**

លោកប្រធាន លោកសាក្សីបានចង្អុលបង្ហាញថា បញ្ហាមួយចំនួនគាត់លើកមុនគាត់បញ្ជាក់ថាគាត់បានជជែកលេងជាមួយគាត់។ ប៉ុន្តែឥឡូវនេះខ្ញុំសួរថាតើគាត់បានដាក់សំណើទៅលោក ខៀវ សំផន ប៉ុន្មានដង? អ៊ីចឹង ខ្ញុំចង់បានឲ្យសាក្សីឆ្លើយនូវសំណួរនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់មេធាវីការពារក្ដីគ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួររបស់តំណាងអយ្យការ តំណាងសហព្រះរាជអាជ្ញាចុងក្រោយនេះ។

សាក្សីឆ្លើយ!

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំសូមសួរម្ដងទៀត អត់ច្បាស់។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សួរថាតើលោកបានធ្វើសំណើទៅ ខៀវ សំផន នោះប៉ុន្មានដង? តើលោកដាក់សំណើដោយផ្ទាល់ដៃ ដោយផ្ទាល់ខ្លួនទៅលោក ខៀវ សំផន សុំឧបករណ៍ និងសម្ភារៈឬ?

[០៩:០៩:៣២]

**ឆ៖** បាទ គឺខ្ញុំគ្រាន់តែសំណេះសំណាលជាមួយគាត់ប៉ុណ្ណឹងទេបាទ។

**ស៖** កាលពីសប្ដាហ៍មុនលោកនិយាយថា លោកបានជជែកលេង ហើយលោកបានស្នើសុំសម្ភារៈ និងឧបករណ៍មួយចំនួន។ តើចម្លើយពីលោក ខៀវ សំផន មកលោកវិញនោះ គាត់ឆ្លើយថាម៉េច?

**ឆ៖** បាទ អត់មានឆ្លើយទេ ពីព្រោះសំណេះសំណាលពីរឿងសេដ្ឋកិច្ចអី។ អាហ្នឹង គឺប៉ុណ្ណឹងទេបាទ។

**ស៖** សប្ដាហ៍មុន លោកបានប្រាប់តុលាការថា គ្រុនចាញ់ គឺជាបញ្ហាចម្បងនៅកម្ពុជាប្រជាធិបតេយ្យកាលនោះ។ ហើយលោកក៏បាននិយាយដែរថា លោកចាំថា លោកមានថ្នាំគ្រប់គ្រាន់នៅក្នុងតំបន់របស់លោក តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើមានថ្នាំអ្វីខ្លះនៅក្នុងមណ្ឌលគិរី ដើម្បីព្យាបាលជំងឺគ្រុនចាញ់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** បាទ នេះគឺមាន ដូចខ្ញុំជម្រាបខាងលើ គឺថ្នាំអីៗ ខ្ញុំមិនសូវក្ដាប់បានដែរ ពីព្រោះខាងហ្នឹងផ្នែកពេទ្យគេបាទ។

[០៩:១១:៣១]

**ស៖** តើលោកចាំដែរឬទេ នៅឆ្នាំ១៩៧៨ នៅពេលទទួលផ្ញើតេឡេក្រាម ទូរលេខមួយចំនួន ហើយលោកបានមកប្រជុំនៅភ្នំពេញ តើលោកបានស្នើសុំថ្នាំពេទ្យពីភ្នំពេញដែរឬទេ សម្រាប់ជំងឺគ្រុនចាញ់ ឬក៏សម្រាប់ជំងឺផ្សេងទៀតនោះ?

**ឆ៖** បាទ អាហ្នឹង គឺរឿងសុំថ្នាំអីហ្នឹង គឺខាងពេទ្យគេធ្វើតារាង ពីព្រោះខ្ញុំមិនយល់ដែរ ថ្នាំអីៗក៏មិនយល់ដែរអាហ្នឹង ខាងពេទ្យគេ បាទ។

**ស៖** ឥឡូវនេះ បញ្ហានិយាយពីការនិយាយជាមួយលោក ខៀវ សំផន ដែលថានិយាយក្នុងកិច្ចប្រជុំដែលលោកបានប្រាប់ខ្ញុំ អំពីថា លោកបានធ្វើដំណើរទៅភ្នំពេញដើម្បីទៅប្រជុំជាមួយ ប៉ុល ពត, នួន ជា, សុន សេន ហើយនិង ខៀវ សំផន ដែលកើតឡើងក្នុងរយៈពេលបី ឬ-- ពីរ ឬបីខែ បន្ទាប់ពី តាឡាំង

គាត់ស្លាប់ទៅ។ សប្តាហ៍មុន លោកនិយាយថា អំពីបញ្ហាដែលលោកបានរាយការណ៍ទៅក្នុងអង្គប្រជុំនោះ ដែលនៅក្នុងនោះមាន ប៉ុល ពត, នួន ជា, សុន សេន, ខៀវ សំផន ចូលរួមផង។ ឥឡូវនេះ ខ្ញុំចង់ដឹងពីលោក ថាតើលោកបានទទួលការណែនាំអ្វីខ្លះពីមេដឹកនាំទាំងនោះនៅក្នុងកិច្ចប្រជុំនៅភ្នំពេញនោះ?

**ឆ៖** បាទ ណែនាំ បានទទួលណែនាំបញ្ហាដឹកនាំប្រជាពលរដ្ឋធ្វើស្រែ ធ្វើចម្ការ ហើយគ្រប់គ្រងប្រជាពលរដ្ឋឲ្យបានល្អ គឺបាទ សូមអស់ប៉ុណ្ណឹង។

**សៈ** តើលោកបានទទួលការណែនាំអំពី ទាក់ទងនឹងវៀតណាមដែរឬទេ?

**ឆ៖** អត់។ សូមអស់។

[០៩:១៤:០០]

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅចំណុចនេះ ខ្ញុំសូមអនុញ្ញាតអានកំណត់ហេតុស្តាប់ចម្លើយទីមួយរបស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេត គឺ E3/367 ហើយ ERN គឺខ្មែរ 00251439, អង់គ្លេស ERN 002786965, បារាំង ERN 00486011។ ហើយខ្ញុំក៏សូមស្នើតុលាការ ដើម្បីបង្ហាញឯកសារនេះលើអេក្រង់ផងដែរ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយបុគ្គលិកដែលមានភារកិច្ចពាក់ព័ន្ធបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងអេក្រង់ទូរទស្សន៍ផង។

[០៩:១៥:១២]

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** នៅក្នុងចម្លើយរបស់លោក នៅក្នុងបទសម្ភាសន៍ទីមួយជាមួយសហចៅក្រមស៊ើបអង្កេតនោះ លោកបានឆ្លើយដូចខាងក្រោយនេះ ដកស្រង់។ នេះគឺជាចម្លើយដែលលោកទាក់ទងទៅនឹងប្រជុំ "យើងរាយការណ៍ទៅពួកគាត់អំពីសកម្មភាពនៅក្នុងតំបន់ ហើយយើងទទួលការណែនាំឲ្យពង្រឹងសេដ្ឋកិច្ច ហើយតទល់ជាមួយនឹងវៀតណាម"។ តើលោកអាចបញ្ជាក់ប្រាប់បានទេ ដែលថាលោកបានទទួលការណែនាំអំពីឲ្យពង្រឹងសេដ្ឋកិច្ច និងទប់ទល់នឹងវៀតណាមនៅក្នុងអង្គប្រជុំនោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ដូចខ្ញុំជម្រាបលោកសហចៅក្រមអីចឹងមែន បាទ សូមអស់។

**សះ** តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើការណែនាំអ្វីខ្លះ លោកបានទទួលពី ប៉ុល ពត, នួន ជា, សុន សេន, ខៀវ សំផន អំពីបញ្ហាទប់ទល់ជាមួយវៀតណាមនោះ?

[០៩:១៦:២៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយ ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់មេធាវីការពារក្តី លោក នួន ជា សិន។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សំណួរដែលសហព្រះរាជអាជ្ញាជាសំណួរនាំមុខ។ ពីព្រោះថាចម្លើយរបស់សាក្សីនៅសហចៅក្រមស៊ើបអង្កេតនោះ គឺថាមានតែប៉ុល ពត ទេ ដែលនិយាយអំពីវៀតណាម។ ដូច្នេះ សូមឲ្យសហព្រះរាជអាជ្ញាកុំសួរសំណួរនាំមុខ គឺថាតាមចម្លើយរបស់គាត់ គឺថា ប៉ុល ពត ជាអ្នកណែនាំទេ មិនមែនអ្នកផ្សេងទេ។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

ខ្ញុំ-- លោកប្រធាន ខ្ញុំនឹងសួរសំណួរឡើងវិញបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**សះ** លោកសាក្សី តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើការណែនាំអ្វី ដែលលោកបានទទួលពីបញ្ហាទាក់ទងទៅនឹងការទប់ទល់នឹងវៀតណាម ហើយអ្នកណាជាអ្នកៗផ្តល់ការណែនាំនេះ?

[០៩:១៧:៣៧]

**លោក សៅ សារុន៖**

**ឆះ** បាទ ខ្ញុំសូមឲ្យសួរម្តងទៀត អត់ៗច្បាស់បាទ។

**សះ** បាទ គឺថាសំណួរ តើលោកបានទទួលការណែនាំអ្វីខ្លះ ទាក់ទងទៅនឹងការទប់ទល់វៀតណាម? មួយទៀតសួរថា តើអ្នកណាជាអ្នកណែនាំនោះ? អ្នកផ្តល់ការណែនាំនោះបាទ?

**ឆះ** បាទ គឺ ប៉ុល ពត គាត់ណែនាំមែន។ គឺធ្វើយ៉ាងម៉េច ត្រូវទប់ទល់ ពីព្រោះ-- អាហ្នឹងគេឈ្លានពានទឹកដីកម្ពុជា យើងត្រូវទប់ទល់។ បាទ សូមអស់។

**សះ** នៅពេលដែលលោកត្រឡប់ទៅមណ្ឌលគិរីវិញក្រោយពីប្រជុំនោះ ដែលថាលោកបានជួបជាមួយមេដឹកនាំនៅភ្នំពេញ ថាតើគេតម្រូវឲ្យលោកអនុវត្តការណែនាំនៅមណ្ឌលគិរីវិញទេ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបខាងលើហ្នឹង គឺអនុវត្តដើម្បីទប់ទល់នឹងពួកវៀតណាមតែប៉ុណ្ណឹងបាទ។ ដូចខាងលើ បាទ។

**ស៖** នៅពេលដែលលោកត្រឡប់ពីប្រជុំនៅភ្នំពេញវិញ ថាតើលោកទៅរៀបចំនៅមណ្ឌលគិរីដែរទេ នៅពេលដែលមានកោះប្រជុំមន្ត្រីស្រុក កម្មាភិបាលស្រុក ឬក៏តំបន់ ហើយលោកផ្សព្វផ្សាយការណែនាំបន្ត តើមានដូច្នោះទេ?

**ឆ៖** បាទ មានដូច្នោះមែន បាទ។

**ស៖** តើអ្នកណាខ្លះដែលគេអញ្ជើញមកពីថ្នាក់តំបន់ឲ្យមកចូលរួមការប្រជុំបែបនោះ?

**ឆ៖** បាទ ប្រជុំនៅក្នុងតំបន់ មានតែស្រុក គណៈស្រុក និងគណៈឃុំ បាទ ប៉ុណ្ណឹងបាទ។

[០៩:២០:២២]

**ស៖** ថាតើតំណាងមកពីតំបន់ហ្នឹងខាងយោធាមកចូលរួមក្នុងការប្រជុំនេះដែរឬទេ? គេអញ្ជើញពួកនុ៎ងទេ?

**ឆ៖** បាទ បញ្ហានេះខ្ញុំនៅមិនទាន់ច្បាស់។ តើបញ្ហាសំណួរហ្នឹងគឺអញ្ជើញមកភ្នំពេញ ឬប្រជុំនៅក្នុងតំបន់? បាទ សូមបញ្ជាក់ម្តងទៀតសំណួរហ្នឹងបាទ។

**ស៖** ខ្ញុំសួរលោកអំពីការប្រជុំដែលលោកធ្វើឡើងនៅមណ្ឌលគិរី ដែលថាត្រឡប់ទៅភ្នំពេញ ថាតើពេលដែលប្រជុំនៅមណ្ឌលគិរីនោះ គេបានហៅខាងមេដឹកនាំយោធាមកចូលរួមដែរឬទេ?

**ឆ៖** បាទហៅ ទាំងគណៈស្រុក ទាំងយោធា យោធាតំបន់ និងឃុំ បាទ។

**ស៖** កាលពីសប្តាហ៍មុន លោក សៅ សារុន ខ្ញុំបានអានជូនលោកនូវសំណួរចម្លើយមួយចំនួនទាក់ទងទៅនឹងបទសម្ភាសន៍ដែលអ្នករួមការងាររបស់លោកដូច ហាំ អនស៊ី។

**លោក ឌេល លីសាក់៖**

ឥឡូវនេះសូមអនុញ្ញាតលោកប្រធាន ដើម្បីអានសេចក្តីដកស្រង់ពីចម្លើយ E3/366 ហើយ ERN ដែលយើងប្រើហ្នឹងគឺថាខ្មែរ ERN 00242414, អង់គ្លេស ERN 00250751 ហើយបារាំង ERN 00283166 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរបាទ។

[០៩:២២:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែល ហាំ អនស៊ី គាត់ផ្តល់បទសម្ភាសន៍ ហើយគាត់បានឆ្លើយមួយចំនួនដូចខាងក្រោមនេះ។ ដកស្រង់៖ "ខ្ញុំដឹងថា កិច្ចប្រជុំថ្នាក់តំបន់ គឺត្រូវទៅប្រជុំនៅមជ្ឈិម ជារៀងរាល់ខែម្តង ការប្រជុំហ្នឹងគឺថា គណៈតំបន់ប្រជុំ ហើយគណៈយោធាតំបន់ ហើយគណៈតំបន់យកពាក្យមកថ្នាក់លើ ហើយពន្យល់មកពួកយើង ដើម្បីឲ្យយើងផលិតស្បៀងអាហារ ហើយកុំ ធ្វើយ៉ាងណាកុំឲ្យមានការខ្វះខាត ឲ្យការពារព្រំដែនទល់នឹងវៀតណាម ហើយនិងតាមដានខ្មាំងបង្កប់ ដែលទាក់ទងជាមួយវៀតណាម ហើយនិងវៀតណាមជាដើមនោះ។ បាទ ខ្មាំងក្បត់"។ ខ្ញុំចង់សួរលោកដូចខាងក្រោមនេះ ថាតើ តើ ហាំ អនស៊ី ឆ្លើយបែបនេះ ដែលថាការណែនាំហ្នឹងគឺបញ្ជូនពីថ្នាក់លើ ហើយមកដល់ថ្នាក់តំបន់ ហើយថ្នាក់តំបន់ផ្សាយទៅថ្នាក់ស្រុក ថ្នាក់ឃុំ ហើយឲ្យតាមដាននូវខ្មាំង ហើយនិងជនក្បត់មួយចំនួននោះ។ តើអ៊ីចឹងដែរឬទេ?

[០៩:២៤:១៧]

**លោក សៅ សារុន៖**

**ឆ៖** បាទ អ៊ីចឹង គឺអ៊ីចឹង គឺបញ្ជាមកពីខាងលើអ៊ីចឹងបាទ។ គឺខាងក្រោមចេះតែអនុវត្តតាមបទបញ្ជាអ៊ីចឹងទៅបាទ។

**ស៖** ថាតើអ្នកណាដែលនៅថ្នាក់កំពូល ដែលណែនាំឲ្យតាមដាន ហើយនិងស្វែងរកខ្មាំងដែលបង្កប់នោះ?

**ឆ៖** បាទ ប៉ុល ពត បាទ។

[០៩:២៥:១១]

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ លោក សៅ សារុន ថាតើលោកបានធ្វើអ្វីខ្លះដើម្បីគោរពការបញ្ជារបស់ ប៉ុល ពត ដើម្បីតាមដានខ្មាំងបង្កប់ ហើយនិងស្វែងរកខ្មាំងនៅមណ្ឌលគិរីនោះ?

**ឆ៖** បញ្ជានេះ គឺអត់មានធ្វើអីទេ។ គឺគ្រាន់តែបញ្ជាក់តែប៉ុណ្ណឹង គឺសូមអស់ប៉ុណ្ណឹងបាទ។

**ស៖** ហើយខ្ញុំនឹងត្រឡប់មកប្រធានបទនេះ ថែមទៀតនៅពេលក្រោយលោកសាក្សី។ ឥឡូវនេះ គឺថា ខ្ញុំចូលទៅដល់ប្រធានបទថ្មីមួយទៀត គឺថានៅថ្ងៃព្រហស្បតិ៍ ខ្ញុំបានសួរលោកអំពីទូរលេខបីដែលលោកបានបញ្ជូនទៅមន្ទីរ៨៧០។ ចុងក្រោយនោះ គឺទូរលេខ៥៤ ដែលចុះថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៨។ ថ្ងៃនេះ ខ្ញុំនឹងសួរសំណួរលោកមួយចំនួនទៀតអំពីទូរលេខមួយទៀត ដែលលោកបានបញ្ជូនគឺចុះថ្ងៃទី២៤

មេសា ឆ្នាំ១៩៧៨។ ទូរលេខនេះ គឺលេខ៥៥។

[០៩:២៦:៣៥]

**លោក ឌេល លីសាក់៖**

លោកប្រធាន ឯកសារនេះ គឺ E3/498 ហើយនៅក្នុងសំណុំរឿងហៅថា D201/6.1 ហើយយើងខ្ញុំស្នើតុលាការដើម្បីបង្ហាញទៅសាក្សីមុន ហើយខ្ញុំនឹងសួរ ហើយបន្ទាប់មកក៏សូមការអនុញ្ញាតដើម្បីបង្ហាញទូរលេខនេះនៅក្នុងអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

លោក សៅ សារុន ខ្ញុំសូមអានទូរលេខនេះជូនលោក ដោយសារទូរលេខហ្នឹងខ្លីទេ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោក។ ទូរលេខនេះ គឺជូនទៅ "គោរព ជូនបងជាទីគោរព" បាទ ជាទូរលេខ ៥៥ ដែលលោកផ្ញើចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៨ កថាខណ្ឌទីមួយសរសេរថា "១. អំពីសភាពការណ៍ខ្មាំង យប់ម៉ោងមួយថ្ងៃ២៣ ខែមេសា ឆ្នាំ១៩៧៨ មានខ្មាំងយួនវាចូលវាយមន្ទីរកងពលនៅក្រុងតេះ ប្រហែលយូរ ប្រាំមួយ ឬប្រាំពីរនាទី។ យើងវ៉ៃតបវិញយ៉ាងខ្លាំងក្លា។ តាមការពិនិត្យពួកវាអាចត្រូវរបួសខ្លះ"។ កថាខណ្ឌទីពីរ ក្នុងទូរលេខរបស់លោកនោះនិយាយថា៖ "បញ្ហាទំនប់អូរច្បារ យប់ថ្ងៃ២២ ខែមេសា គឺមានភ្លៀងខ្លាំង គឺទឹកអូរច្បារជន់ ហើយក៏ប៉ុន្តែអត់មានបាក់បែកអីទេ"។ ហើយកថាខណ្ឌនៅក្នុងតេឡេក្រាម នៅក្នុងទូរលេខនោះនិយាយថា៖ "ស្នើសុំគ្រឿងឡាន អារ៉េវមួយចំនួន កូនជ្រូកមួយប៊ិកឡានអារ៉េវមួយចំនួន កូនជ្រូកឡានស៊ីសង់ប៊ិច ឡានស៊ីសង់ប្រាំមួយ ទឹកអំបិល-- ស្ងប៉ាប់ធ្វើម៉ាស៊ីនកិនស្រូវនេះ"។

[០៩:២៨:១៩]

តើនេះជាទូរលេខដែលលោកបានបញ្ជូនទៅថ្នាក់លើនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៨ តើលោកនៅចាំទេ ក្រោយពីខ្ញុំអានជូនលោកបែបនេះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ នៅចាំ។ គឺចូលវ៉ៃមែននៅមន្ទីរកងពលនៅក្រុងតេះ ហ្នឹងបាទ។ វ៉ៃតបខ្លាំងដែរ ធម្មតាគេវ៉ៃហើយ គេក៏វ៉ៃតបខ្លាំងដែរ បាទ។

[០៩:៣០:០៥]

**ស៖** ទូរលេខរបស់លោកបានបញ្ជាក់ថា ការវាយប្រហារហ្នឹងនៅក្រុងតេះ នោះនៅកន្លែងណាដែលថាកងពលនៅកន្លែងក្រុងតេះនោះបាទ?

**ឆ៖** បាទ នៅចំឃុំក្រុងតេះហ្នឹងតែម្ដងបាទ គឺអាហ្នឹង គឺជាវរសេនាធំទេបាទ ចូលវ៉ៃកន្លែងវរសេនារបស់កងពល៩២០ បាទ។ វ៉ៃគ្នាទៅវិញទៅមក វ៉ៃខ្លាំងដែរ គេហើយ គេវ៉ៃ តខ្លាំងដែរបាទ។

**ស៖** តើទីក្រុងនេះ តើក្រុងនេះគឺមានទីតាំងនៅជិតព្រំដែនវៀតណាមដែរឬទេ?

**ឆ៖** បាទ ឆ្ងាយដែរ ប្រហែលជា-- ក្ដាប់មិនបានដែរ ប្រហែលឆ្ងាយ។

**ស៖** នៅចុងនៃទូរលេខរបស់លោកនោះ គឺមានបញ្ជីចម្លងជូន ដែលក្នុងបញ្ជីចម្លងជូនហ្នឹងគឺដាក់ចម្លងជូន អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, មន្ទីរ ហើយនិងឯកសារ។ គឺថាបញ្ជីចម្លងជូនហ្នឹង គឺមានលក្ខណៈដូចគ្នានឹងទូរលេខ៤៤ ដែលខ្ញុំបានជម្រាបសួរលោកកាលពីមុនហើយ។ តើលោកគឺជាអ្នកសរសេរឈ្មោះបញ្ជីចម្លងជូន ឬមួយក៏ថាបញ្ជីចម្លងជូនហ្នឹងត្រូវអ្នកផ្សេងទេជាអ្នកសរសេរ? លោកន័យថា លោកជាអ្នកសរសេរផ្ទាល់ ឈ្មោះអ្នកចម្លងជូន ឬក៏អ្នកដទៃជាអ្នកសរសេរ?

[០៩:៣២:១៧]

**ឆ៖** បាទ គឺអ្នកដទៃអ្នកបកសារ គេជូន យកទៅជូន ប៉ុល ពត ទេបាទ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះយើងបានឃើញទូរលេខចំនួនបួនរួចទៅហើយ ដែលលោកបានបញ្ជូនទៅមេដឹកនាំបក្សនៅទីក្រុងភ្នំពេញ។ គឺពីចន្លោះថ្ងៃ០១ មេសា ៧៨ រហូតដល់ថ្ងៃ២៨ ខែមេសាឆ្នាំ៧៨។ តើលោកអាចជម្រាបបានដែរឬទេថា ហេតុអ្វីបានជាលោកត្រូវបញ្ជូនរបាយការណ៍ទៅមេដឹកនាំបក្សនៅទីក្រុងភ្នំពេញ ក្នុងរយៈពេលនោះ? ថាតើហេតុអ្វីដែរ?

**ឆ៖** បាទ ពីព្រោះអាហ្នឹងជាការរាយការណ៍ គឺជាប្រចាំខែ គឺត្រូវបញ្ជូនអ៊ីចឹងបាទ។ មានៗសភាពការណ៍ ឬអត់មាន ក៏ត្រូវតែបញ្ជូនដំណឹងឲ្យ ប៉ុល ពត ដែរបាទ។

**ស៖** ដូច្នេះហេតុផលដែលលោកត្រូវបញ្ជូន គឺថាដោយសារតែលោកបញ្ជូនហ្នឹងគឺក្រោយពេលដែល តាឡាំង ដែលជាអតីតមេតំបន់ហ្នឹងគាត់បានស្លាប់ តើមែនទេ?

**ឆ៖** បាទ កាលមុនខ្ញុំក៏អត់មានសិទ្ធិអីណាដែរ គឺខ្ញុំនៅស្រុក ពេល តាឡាំង ស្លាប់ទៅបានគេចាត់តាំងឲ្យខ្ញុំបានកាន់កាប់ហ្នឹង បានមានសិទ្ធិជូនសេចក្ដីរាយការណ៍អីជូន ប៉ុល ពត បាទ ពីមុនអត់មានទេ។

[០៩:៣៤:២៥]

**ស៖** លោកបានបញ្ជាក់កាលពីសប្តាហ៍មុនថា ចម្លើយតបដែលលោកបានទទួលទាក់ទងទៅនឹងតួលេខរបស់លោកហ្នឹង គឺចម្លើយហ្នឹងឆ្លើយតបដោយ ប៉ុល ពត ឬក៏ នួន ជាឬក៏ ម៨៧០។ ដូច្នេះអ្វីដែលខ្ញុំចង់សួរលោកថា តើគឺលោកចាំដែរឬទេថា ទូរលេខប្រភេទណាដែលលោកបានទទួលពី នួន ជា? តើលោកចាំទេ?

**ឆ៖** ដូចអត់ចាំទេ ភ្លេចការចងចាំហើយ វាយូរបាទ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវចម្លើយតបទីមួយ របស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ដែលមានលេខ E3/367 ដែលមានលេខខ្មែរគឺ 0026440, ភាសាអង់គ្លេសគឺមានលេខ 0028696 ហើយភាសាបារាំងគឺ 00486012។ ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

[០៩:៣៥:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបានផ្តល់នូវចម្លើយដូចតទៅនេះ៖ ខ្ញុំសូមដកស្រង់ "សំណួរ៖ តើលោកធ្លាប់បានទទួលទូរលេខពីអ្នកណាខ្លះ? ចម្លើយ៖ ខ្ញុំធ្លាប់បានទទួលពី នួន ជា ម្តងម្កាល ដែលនិយាយអំពីការទៅរៀន សន្និបាត វគ្គរៀនសូត្រផ្សេងៗ"។ តើអ្វីដែលខ្ញុំអាននេះ ធ្វើឱ្យលោកនឹកឃើញនៅលើ-- អំពីប្រភេទនៃទូរលេខ ដែលលោកបានទទួលពី នួន ជា ដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ បានទទួលហើយ ដូចខ្ញុំជម្រាបជូន វាយការណ៍ជូនលោកសហចៅក្រម។ បាទអស់។

**ស៖** ពាក់ព័ន្ធទៅនឹងទូរលេខ ដែលលោកបានបញ្ជូនទៅទីក្រុងភ្នំពេញហ្នឹង តើអ្នកណាជាអ្នកកំណត់ទម្រង់ ហើយនិងនីតិវិធីក្នុងការទូរលេខទៅទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ សូមសួរម្តងទៀត។ អត់ច្បាស់។

**ស៖** តើអ្នកណាជាអ្នកណែនាំលោកអំពីរបៀបរបប ឬក៏បែបបទនៃការបញ្ជូនទូរលេខទៅទីក្រុងភ្នំពេញ តើមានអ្នកណាជាអ្នកណែនាំលោក អំពីរបៀបរបប និងបែបបទ នៃការបញ្ជូនទូរលេខដែរឬទេ?

**ឆ៖** បាទ ប៉ុល ពត គាត់ណែនាំបាទ។ សូមអស់។

[០៩:៣៨:០៦]

**ស៖** តើលោកអាចជម្រាបយើងបានដែរឬទេថា នៅពេលណាដែល ប៉ុល ពត ណែនាំលោក គឺណែនាំអំពីរបៀបរបប និងបែបបទនៃការបញ្ជូនទូរលេខ ទៅទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ ហ្នឹងខ្ញុំវាយូរដែរគឺ វាបាត់ការចងចាំដែរ វាយូរបាទ។

**ស៖** ខ្ញុំនឹងព្យាយាមរំឭកលោកអំពីបញ្ហានេះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំស្នើសុំអាននូវកិច្ចសម្ភាសន៍ទីពីររបស់សាក្សី ជាមួយនឹងសហចៅក្រមស៊ើបអង្កេត។ គឺឯកសារដែលមានលេខ E3/383 ហើយលេខឯកសារយោងគឺ 00345910 ដល់ 345911, ភាសាអង់គ្លេស គឺមានលេខ 00350262 ហើយភាសាបារាំងគឺមានលេខ 00361762។ ហើយខ្ញុំអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត!

[០៩:៣៩:៥២]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក គឺលោកបានផ្តល់ចម្លើយដូចតទៅនេះ៖ “សំណួរ៖ តើលោកមានកំណត់ ទម្រង់ ឬក៏អ្វីដែរឬទេ?” ពេលនោះលោកនិយាយថា “តំបន់ ឬក៏ខាងភូមិភាគគឺត្រូវទទួលនូវទម្រង់ដូចគ្នា។ តើលោកធ្លាប់ទទួលបញ្ជាពីខាងមជ្ឈិមដែរឬទេ? លោកនិយាយថា ខ្ញុំទទួលបញ្ជាពី ប៉ុល ពត នៅពេលគាត់ធ្វើជា-- នៅពេលដែលគាត់បើកនូវកិច្ចប្រជុំ ហើយកិច្ចប្រជុំហ្នឹង គឺនៅជិតទីក្រុង-- នៅក្នុងទីក្រុងភ្នំពេញនៅជិតព្រះបរមរាជវាំង”។ តើលោកអាចចាំបានដែរឬទេ ដែលថាលោកបានទទួលការណែនាំពី ប៉ុល ពត នៅក្នុងពេលប្រជុំ ទាក់ទងទៅហ្នឹងទម្រង់ និងរបៀបរបបនៃការបញ្ជូនទូរលេខនេះ តើលោកចាំដែរឬទេ?

**ឆ៖** បាទ ដូចខ្ញុំរាយការណ៍ជូនលោកសហចៅក្រម បានច្បាស់ប៉ុណ្ណឹងហើយបាទ។ សូមអស់។

**ស៖** តើមានអ្នកចូលរួមប្រហែលប៉ុន្មាននាក់នៅក្នុងកិច្ចប្រជុំរវាង ប៉ុល ពត ជាមួយគណៈកម្មការតំបន់ និងភូមិភាគហ្នឹង? តើលោកចាំដែរទេថា វាជាកិច្ចប្រជុំតូច ឬមួយក៏ជាកិច្ចប្រជុំធំ?

**ឆ៖** អត់ស្គាល់ទេ មិនដឹងចំនួនប៉ុន្មានៗទេ គឺឃើញតែថាមនុស្សម្នាច្រើន។ តែជាចំនួនជាក់លាក់ ខ្ញុំអត់ដឹង។

[០៩:៤១:៤៦]

**ស៖** តើលោកទៅទីក្រុងភ្នំពេញប៉ុន្មានដងដែរ ដើម្បីចូលរួមនៅកិច្ចប្រជុំរវាង ប៉ុល ពត ជាមួយហ្នឹងនឹងគណៈកម្មការតំបន់ និងភូមិភាគនោះ តើប៉ុន្មានដងដែរ?

**ឆ៖** បាទ តាំងពីគេតែងតាំងមកទើបៗ សន្និបាតទើបតែខែ៩ ២០០៨ (ស៊ីក) តែម្ដងហ្នឹង ដល់មកទៅអាហ្នឹងបានតែពីរខែ ខែ០១ ហ្នឹងគឺយួនមកចូលមកស្រុកទៅក៏រត់ចូលព្រៃទាំងអស់។

**ស៖** តើភូមិភាគនិងតំបន់ឯករាជ្យទាំងអស់ នៅភូមិភាគឯករាជ្យទាំងអស់ហ្នឹង តើគាត់ចូលរួមទាំងអស់គ្នាឬ នៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** អត់ដឹងដែរ មិនដឹងមកទាំងអស់ឬអត់ អត់ដឹងដែរបញ្ហាហ្នឹងបាទ។

**ស៖** កាលពីមុនយើងបានពិភាក្សាអំពីដំណើរមកភ្នំពេញរបស់លោកបន្ទាប់ពី តាឡាំង ដែលជាអតីតលេខា គាត់បានស្លាប់ ហើយបន្ទាប់មក នៅក្រោយហ្នឹងពីរបីខែ ក្រោយពីការស្លាប់របស់ តាឡាំង ក៏លោកធ្វើដំណើរមកម្ដងទៀត។ តើលោកចាំទេថា នៅពេលដែលលោកធ្វើដំណើរមកភ្នំពេញហ្នឹង មកចូលរួមនៅក្នុងសមាជបក្សនៅក្នុងខែ៩ ឆ្នាំ៧៨ គឺប្រហែលជាក្នុងអំឡុងពេលខួបបក្សកុម្មុយនីស្តកម្ពុជានោះ តើលោកចាំទេថាលោកធ្លាប់អញ្ជើញមក?

[០៩:៤៣:៥២]

**ឆ៖** បាទ គឺដូចខ្ញុំជម្រាបខាងលើនេះហើយ គឺខែ៩, ២០០៨ (ស៊ីក) ហ្នឹងគឺប្រជុំសន្និបាត គឺគ្រប់ខេត្តទូទាំងប្រទេស គឺមកទាំងអស់បាទ។

**ស៖** ចម្លើយដែលគេបកប្រែមកខ្ញុំគឺថាខែ៩, ២០០៨។ តើលោកចង់និយាយឆ្នាំ១៩៧៨ មែនទេ? គឺជារយៈពេលដែលកើតឡើងក្នុងរបបខ្មែរក្រហម។ តើលោកចង់និយាយបែបនេះមែនទេ?

**ឆ៖** បាទ ខែ៩, ២០០៨ ច្បាស់ហើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីបញ្ជាក់ចំណុចនេះឡើងវិញ ព្រោះហាក់ដូចជាកំណត់ខុសកាលបរិច្ឆេទ។ មួយគឺខែ៩

ឆ្នាំ១៩៧៨ បានន័យថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែកឯមួយទៀត ឆ្នាំ២០០៨ បានន័យថា ទើបនឹងថ្មីៗនេះទេ បីបួនឆ្នាំមុននេះទេ។ លោកច្រឡំទេ លោកបញ្ជាក់ឲ្យបានច្បាស់មើល តើខែ៩ ១៩៧៨ ឬក៏ខែ៩ ឆ្នាំ២០០៨?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹង គឺខ្ញុំសូមអភ័យទោសចុះ ខ្ញុំភ្លេចការចងចាំ។ ពីឆ្នាំ១៩៧៨ ទេ មិនមែន២០០៨ ទេបាទ។ សូមអស់។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[០៩:៤៥:៤៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី តើលោកអាចប្រាប់យើងបានទេ ថាតើនៅក្នុងសមាជបក្សហ្នឹងគេពិភាក្សាអំពីប្រធានបទអ្វីខ្លះ គឺសមាជបក្សឆ្នាំ១៩៧៨ ខែ៩ នោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ សំខាន់ គឺជំរុញបញ្ហាគ្រប់គ្រងប្រជាពលរដ្ឋ ដឹកនាំប្រជាពលរដ្ឋ បញ្ហាដោះស្រាយជីវភាព ធ្វើយ៉ាងម៉េចកុំឲ្យប្រជាពលរដ្ឋអត់បាយ អត់អីតទៅទៀត ឲ្យមានផ្ទះសម្បែង រៀបចំផ្ទះសម្បែងឲ្យប្រជាពលរដ្ឋ ឲ្យគ្រប់គ្រួសារឲ្យមានផ្ទះរស់នៅ បាយហូបឲ្យគ្រប់គ្រាន់បាទ។

**ស៖** តើលោកចាំដែរឬទេ ថាមានការពិភាក្សាអំពីលទ្ធភាពក្នុងការបើកផ្សារជាថ្មីឡើងវិញ? គឺតើមានការពិភាក្សាបែបនេះទេ នៅក្នុងកិច្ចប្រជុំនៅពេលនោះ?

[០៩:៤៧:០២]

**ឆ៖** បញ្ហាដូចអត់ៗ ខ្ញុំអត់ឮទេបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវកិច្ចសម្ភាសន៍របស់សាក្សីលើកទីមួយ ជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារដែលមានលេខ E3/367។ ហើយចំណុចដែលខ្ញុំចង់ដកស្រង់ គឺភាសាខ្មែរ ERN 00251437, ERN ជាភាសាអង់គ្លេសគឺ 00278694 ហើយភាសាបារាំងគឺមានលេខ 00486010។ ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ផងដែរ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:៤៨:០៧]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ទីមួយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយដូចទៅ ខ្ញុំសូមដកស្រង់៖ “នៅក្នុង-- ក្នុងពេលធ្វើបុណ្យខួបបក្ស ប្រហែលជាខែ៩ ក្នុងឆ្នាំ៧៨ ខ្ញុំបានចូលរួមវគ្គរៀនសូត្រសន្និបាតទូទាំងប្រទេស ដែលនិយាយអំពីការបើកបោះពុម្ព និងចាយលុយ។ ឲ្យប្រជាជនចូលទីក្រុងវិញ ព្រមទាំងបើកឲ្យមានផ្សារ ហើយមិនឮថាបើកឲ្យមានវត្តវិញទេ។ ការប្រជុំនេះក៏បាននិយាយអំពីមូលហេតុថា ដោយសារអង្គការបានកម្ចាត់ខ្មាំងអស់ហើយ បានជាមានការប្រែប្រួលដូច្នេះ។ ប៉ុល ពត ជាអ្នកជាប្រកាសផ្ទាល់ពីគោលនយោបាយនេះ។ ចំណែកឯកសារគណៈអធិបតីបិទ និងបើកវគ្គទាំងអស់នៅអង្គុយជិតៗគ្នា ស្តាប់ទាំងអស់គ្នា”។ តើលោកអាចបញ្ជាក់បានដែរឬទេ ថានេះជាចម្លើយដែលត្រឹមត្រូវ ពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងៗ សមាជបក្សនៅខែ៩ ឆ្នាំ១៩៧៨ នោះ?

[០៩:៤៩:២២]

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងដូចខ្ញុំបានបញ្ជាក់ឲ្យលោកសហចៅក្រម ច្បាស់ជាអ៊ីចឹងហើយ ថាឲ្យប្រជាពលរដ្ឋចូលក្រុងវិញ ហើយប្រកាសថាឲ្យចាយលុយវិញ។ អាហ្នឹងគឺបានដូចខ្ញុំបានបញ្ជាក់ឲ្យលោកចៅក្រមច្បាស់អ៊ីចឹងបាទ។

**ស៖** ចម្លើយរបស់លោកនិយាយយោងអំពីគណៈអធិបតីដទៃទៀត តើលោកចាំដែរឬទេ ថាតើមេដឹកនាំដទៃទៀតណាខ្លះ រូបណាខ្លះដែលបានចូលរួមនៅក្នុងសមាជបក្សនេះ?

**ឆ៖** បាទ ខ្ញុំពេលហ្នឹងអត់ស្គាល់ទេ។ មានតែគណៈចាត់តាំងគេហៅឈ្មោះ បានខ្ញុំយល់បាទ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តអានជូនសាក្សីនូវផ្នែកបន្ទាប់នៃឯកសារកិច្ចសម្ភាសន៍ដដែលហ្នឹង គឺ E3/367 ដែលជាឯកសារដដែលនៅទំព័រដដែល។ តើខ្ញុំអាចបន្តទៅមុខបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

[០៩:៥១:០៧]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក ពាក់ព័ន្ធនឹងប្រធានបទនៃកិច្ចសម្ភាសន៍ហ្នឹង លោកបាននិយាយដូចតទៅ៖ “ចំណែកឯអ្នកចូលរួមបិទ និងបើកវគ្គមាន ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, និង សុន សេន ប៉ុន្តែ នួន ជា ជាអ្នកឧទ្ទេសនាមច្រើនជាងគេ”។ តើលោកអាចបញ្ជាក់បានដែរទេ ថានេះគឺជាចម្លើយត្រឹមត្រូវនៃអ្នកចូលរួមនៅក្នុងសមាជបក្សនៅខែ៩ ឆ្នាំ១៩៧៨ នោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំ ដូចខ្ញុំជម្រាបរាយការណ៍ជូនលោកសហចៅក្រម គឺច្បាស់ប៉ុណ្ណឹងហើយបាទ។ ខ្ញុំបាទបញ្ជាក់ច្បាស់ប៉ុណ្ណឹងហើយបាទ។

**ស៖** តើលោកអាចចាំបានដែរឬទេ ថាតើ នួន ជា គាត់ធ្វើបទឧទ្ទេសនាមទាក់ទងទៅនឹងប្រធានបទអ្វីខ្លះ?

**ឆ៖** បាទ ខ្ញុំចាំគាត់ឧទ្ទេសនាម មួយគឺថាបញ្ហាគ្រប់គ្រងប្រជាជនឲ្យបានល្អ រៀបចំភូមិដ្ឋានឲ្យប្រជាជនឲ្យបានល្អ និងដោះស្រាយជីវភាពប្រជាជនឲ្យមានហូបចុកឲ្យគ្រប់គ្រាន់បាទ។

[០៩:៥២:៤៩]

**ស៖** តើលោកចាំដែរឬទេ ថាតើបទឧទ្ទេសនាមនោះ មានបទឧទ្ទេសនាមធ្វើឡើងដោយ ខៀវ សំផន ដែរឬទេនៅក្នុងការប្រជុំលើកនោះ?

**ឆ៖** អត់ទេ។

**ស៖** តើលោកចាំដែរឬទេ ថាមានបទឧទ្ទេសនាមដោយលោក អៀង សារី នៅក្នុងសន្និបាតលើកនោះ?

**ឆ៖** បាទ អត់មានទេបាទ។

**ស៖** លោកបានបញ្ជាក់នៅក្នុងចម្លើយរបស់លោកថា បន្ទាប់ពីសន្និបាតនោះមក ប៉ុល ពត បានប្រកាសថាផ្សារនឹងត្រូវបើសាជាថ្មី ហើយប្រជាជនត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅទីក្រុងភ្នំពេញ ពីព្រោះ

អង្គការបានបោសសម្អាតខ្មាំងអស់ហើយ។ តើលោកចាំដែរឬទេ ថាតើកម្មាភិបាល និងអ្នកចូលរួមនៅក្នុងកិច្ចប្រជុំនុ៎ងគាត់មានប្រតិកម្មបែបណាដែលនៅពេលដែល ប៉ុល ពត ធ្វើការប្រកាសបែបនេះឡើង?

**ឆ៖** បាទ អាហ្នឹងគឺពិត គឺឲ្យចាយលុយ ឲ្យប្រជាជនចូលមកទីក្រុង តែកម្មាភិបាលទាំងអស់អត់ឮប្រតិកម្មអីទាំងអស់ទេបាទ។

[០៩:៥៤:៣២]

**ស៖** តើសន្និបាតហ្នឹងធ្វើឡើងនៅទីណា ហើយសន្និបាតហ្នឹងមានរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** បាទ សន្និបាទគឺធ្វើ-- ខ្ញុំវាមិនស្គាល់កន្លែង ប៉ុន្តែក្នុងសន្និបាតហ្នឹងជាងដប់ថ្ងៃបាទ។

**ស៖** តើសន្និបាតនេះ ជាសន្និបាតធំដែលមានអ្នកតំណាងមកពីទូទាំងប្រទេសដែរឬទេ?

**ឆ៖** បាទ សន្និបាតធំមានតំណាងគ្រប់ខេត្តមកចូលរួម បាទ។

**ស៖** តើកិច្ចប្រជុំហ្នឹងមានតំណាងមកពីខាងយោធាដែរឬទេ?

**ឆ៖** បាទ មាន។

**ស៖** តើកិច្ចប្រជុំហ្នឹងមានការចូលរួមពីសមាជិកគណៈមជ្ឈិមដែរឬទេ?

**ឆ៖** បាទ មាន។

[០៩:៥៦:១២]

**ស៖** តើលោកអាចប្រាប់បានទេ ថាតើកម្មាភិបាលណាខ្លះដែលបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹង? តើមានការកំណត់ប្រភេទនៃថ្នាក់ ថាថ្នាក់លើណាខ្លះ ឬក៏ថ្នាក់ណាខ្លះដែលត្រូវគេបានអញ្ជើញមកចូលរួមនៅក្នុងកិច្ចប្រជុំនេះដែរឬទេ?

**ឆ៖** បាទ តំបន់ ថ្នាក់តំបន់ ថ្នាក់កងពល បាទ គ្រប់តំបន់ គ្រប់កងពល បាទ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមដកស្រង់នូវកិច្ចសម្ភាសន៍ដដែល គឺ E3/367 ហើយជាការបន្តពីលេខ ERN ដដែល ហើយគឺជាឯកសារដែលខ្ញុំបានអានប៉ុន្មាននាទីមុននេះ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ទីមួយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត។ លោក សារុន លោកបាននិយាយដូចតទៅនេះ "ក្នុងសន្និបាតនេះ មានអ្នកចូលរួមទូទាំងប្រទេស ទាំងទាហាន ទាំងស៊ីវិល ចាប់ពីថ្នាក់វរសេនាតូច និងគណៈស្រុកឡើងទៅ"។ តើអ្វីដែលខ្ញុំអាននេះ ធ្វើឲ្យលោកនឹកឃើញថាតើកម្មាភិបាលណាខ្លះដែលបានចូលរួមនៅក្នុងសន្និបាតនេះដែរឬទេ? តើធ្វើឲ្យលោកនឹកឃើញដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ដូចខ្ញុំជម្រាបឲ្យលោកសហចៅក្រមហើយ គឺតំណាង ទាំងតំណាងខាងតំបន់ ទាំងតំណាងខាងកងទ័ព ខាងកងពលបាទ។ សូមអស់។

**ស៖** តើធ្វើយ៉ាងដូចម្ដេចទើបលោកដឹងថា មានសមាជិកគណៈមជ្ឈិមណាខ្លះដែលចូលរួមនៅពេល តើលោកដឹងដោយរបៀបណា?

**ឆ៖** បាទ ខ្ញុំដឹង ក្នុងការ-- គណៈចាត់តាំង គេហៅឡើងវេទិកាបាទ។ ខ្ញុំដឹងប៉ុណ្ណឹង។

[០៩:៥៨:៥៤]

**ស៖** តើលោកអាចចាំបានដែរឬទេ ថាតើមានមនុស្សប្រហែលប៉ុន្មានរូបដែរ ដែលបានឡើងលើវេទិកានោះ?

**ឆ៖** អត់ចាំទេ មិនដឹងប៉ុន្មានៗរូប អត់ចាំទេ ឃើញតែគេហៅឡើងវេទិកាបាទ។

**ស៖** នៅពេលហ្នឹង លោកអង្គុយកន្លែងណាដែរ ប្រសិនបើយើងធៀបជាមួយនឹងវេទិកាលោកអង្គុយនៅចម្ងាយប៉ុន្មានណាដែរ?

**ឆ៖** បាទ ប្រហែលជាបួនប្រាំម៉ែត្រ ដប់ម៉ែត្រអីហ្នឹងបាទ តាមគេរៀបហ្នឹងបាទ។

**ស៖** តើៗលោកមានអង្គុយនៅតុដែលគេរៀបចំសម្រាប់អ្នកតំណាងមកពីខេត្តមណ្ឌលគិរីដែរឬទេ?

**ឆ៖** បាទ គេរៀបតុហ្នឹង គឺគេឈ្មោះខេត្តណាៗ គឺយើងអង្គុយតាមលំដាប់គេដាក់លេខរៀងបាទ។

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំមិនយល់ខុសទេ តើសមាជិកគណៈមជ្ឈិមហ្នឹង ត្រូវបានគេកំណត់ហើយហៅឡើងលើវេទិកា តើមែនទេ? ហើយលោកដឹងថា ពួកគាត់ហ្នឹង ជាគណៈមជ្ឈិម ដោយសារតែ

គេហៅឡើងវេទិកាបែបនេះ តើមែនទេ?

**ឆ៖** បាទ គឺគណៈចាត់តាំងគេ ឡើងវេទិកា គឺខ្ញុំចាំប៉ុណ្ណឹងបាទ។

**ស៖** ចាតើអ្នកណាខ្លះជាសមាជិកគណៈមជ្ឈិមប៉ុន្មាននាក់ ដែលលោកចាំ ដែលគេបានហៅឱ្យមកវេទិកានោះ?

[១០:០១:២៤]

**ឆ៖** បាទ ខ្ញុំមិនដឹងប៉ុន្មាននាក់ទេ ឃើញតែគេហៅតាមឡើងវេទិកា បាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានអំពីបទសម្ភាសន៍មួយទៀតរបស់សាក្សីនេះ ដែលជាបទសម្ភាសន៍ទីបួន គឺឯកសារ E3/404 ហើយក៏នៅក្នុងសំណុំរឿងហៅថា D232/30។ ទំព័រដែលខ្ញុំយោងនោះ គឺខ្មែរ ERN 00398480, អង់គ្លេស ERN 00403024 រហូតដល់ 25 ខាងចុងនោះ, បារាំង ERN 00484 ហើយនិង 198 ហើយសូមអនុញ្ញាតបង្ហាញឯកសារ-- អំ អានឯកសារនេះជូនសាក្សីស្តាប់ ហើយនិងបង្ហាញលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងបទសម្ភាសន៍ទីបួនរបស់លោកទៅសហចៅក្រមស៊ើបអង្កេត លោកបានឆ្លើយដូចខាងក្រោមនេះ។ ដកស្រង់៖ "នៅខែប្រាំបួន ឆ្នាំ១៩៧៨ នៅជិតស្ពានអូឡាំពិក នៅបុរីកីឡា គណៈមជ្ឈិមក្នុងសមាជិកគណៈមជ្ឈិមទាំងអស់ចូលរួម រួមមានទាំង ប៉ុល ពត, ខៀវ សំផន, នួន ជា, អៀង ធីរិទ្ធ និងអៀង សារី ព្រមទាំងតំណាងគ្រប់ខេត្ត និងតំណាងគ្រប់កងពល មកចូលរួមក្នុងមហាសន្និបាតសរុបនូវ-- សរុបទៅមានចំនួនច្រើនរាប់រយនាក់"។ តើលោកនៅប្រកាន់ថា ចម្លើយរបស់លោកដែលឆ្លើយជូនសាក្សីនេះ នៅត្រឹមត្រូវដដែល ឬក៏ដូចម្តេចលោកសាក្សី?

[១០:០៣:៥៨]

**លោក សៅ សារុន៖**

**ឆ៖** បាទ ដូចខ្ញុំជម្រាបលោកសហចៅក្រម គឺត្រឹមត្រូវ។ បាទ សូមអស់។

**ស៖** តើនេះធ្វើឲ្យលោកនឹកឃើញថា តើកិច្ចប្រជុំនោះ គេប្រជុំនៅកន្លែងណាដែរឬទេ ដែលខ្ញុំអានជូនលោកស្ដាប់អម្បាញ់មិញនោះ?

**ឆ៖** បាទ ដូចចម្លើយខ្ញុំ លោកក៏អានអម្បាញ់មិញហ្នឹង។ បាទ សូមអស់។

**ស៖** ដូចដែលលោកបានចង្អុលបង្ហាញនៅក្នុងចម្លើយនោះ ថា ខៀវ សំផន ក៏ជាសមាជិកម្នាក់ដែលគេហៅថា ជាសមាជិកគណៈមជ្ឈិម ហើយក៏គេកោះ-- អ៎! គេអញ្ជើញគាត់ទៅវេទិកានោះដែរ តើអ៊ីចឹងឬទេ?

[១០:០៥:០០]

**ឆ៖** បាទ គឺត្រឹមត្រូវ។

**ស៖** ចាតើលោក អៀង សារី ក៏គេបញ្ជាក់ថា គាត់ជាសមាជិកនៃគណៈជម្មិម ហើយក៏គេអញ្ជើញគាត់ទៅវេទិកាដែរឬទេ?

**ឆ៖** បាទ ដូចខ្ញុំបញ្ជាក់ខាងលើហ្នឹងដែរ ពេលមហាសន្និបាតហ្នឹងបាទ។

**ស៖** ចាតើលោកចាំទេ សមាជិកគណៈមជ្ឈិមហ្នឹងគឺរាប់បញ្ចូលទាំងមេដឹកនាំមកខេត្តផង ដូចជា តាម៉ុក នោះ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ តាម៉ុក នោះ។

**ស៖** តើលោកដឹងដែរឬទេ មុនពេលដែលលេខាស្រុកមណ្ឌលគិរីម្នាក់ឈ្មោះ ឡាំង គាត់ស្លាប់ទៅនោះ តើគាត់ជាសមាជិកនៃគណៈមជ្ឈិមដែរឬទេបាទ?

**ឆ៖** បាទ តាមហ្នឹងគឺគាត់ថា គាត់ជាគណៈមជ្ឈិមបាទ។

[១០:០៦:៤៣]

**ស៖** ហើយមានមហាសន្និបាតបក្សដែលលោកបានពិភាក្សា គឺគេរៀបចំជារៀងរាល់ឆ្នាំនៅខែ៩ រៀងរាល់ឆ្នាំ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ពីមុនខ្ញុំអត់យល់ទេ។ ពីព្រោះយល់កាលតាំងពីខ្ញុំបានគេតែងតាំងជាប្រធានតំបន់។ ប៉ុណ្ណឹងទេ បានខ្ញុំយល់បាទ។

**ស៖** ចាតើមានអ្នកណាខ្លះ មកពីមណ្ឌលគិរី មកជាមួយលោកដែលចូលរួមក្នុងមហាសន្និបាតបក្សនោះ?

**ឆ៖** បាទ មានខ្ញុំ មានខាងកងពលគេ។

**ស៖** តើលោកនៅចាំទេ ថាតើអ្នកដែលមកពីកងពលនោះ គឺថ្នាក់ត្រឹមណា? មានប៉ុន្មាននាក់ដែរបាទ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។ ឃើញតែ-- ដឹងចំនួនប៉ុន្មានៗ ខ្ញុំអត់ចាំបាទ។

**ស៖** ដែលលោកហៅថា កងពល តើលោកចង់និយាយកងពល៩២០ ហ្នឹងឬ?

**ឆ៖** បាទ កងពល៩២០ ពីព្រោះគេប្រចាំការនៅមណ្ឌលគិរីបាទ។

[១០:០៨:៤២]

**ស៖** ថាតើនៅក្នុងមហាសន្និបាតបក្សខែកញ្ញា ឆ្នាំ១៩៧៨ ដែលគេតែងតាំងលោកឲ្យធ្វើជាលេខាតំបន់១០៥ នោះ?

**ឆ៖** បាទ គឺមែនពិតប្រាកដហ្នឹង ក្នុងឆ្នាំ១៩៧៨ ខែ៩ ហ្នឹងបាទ។

**ស៖** ថាតើការតែងតាំងហ្នឹងគេប្រកាសនៅក្នុងមហាសន្និបាតហ្នឹង ដែលមនុស្សភាគច្រើនចូលរួម ឬក៏គេប្រកាសការតែងតាំងហ្នឹងក្នុងការប្រជុំផ្សេងមួយទៀត?

**ឆ៖** បាទ គឺប្រកាសក្នុងមហាសន្និបាតខែ៩ ឆ្នាំ១៩៧៨ ហ្នឹងឯងបាទ។

**ស៖** ថាតើមានការតែងតាំងអ្នកណាផ្សេងក្រៅពីលោកទេ នៅក្នុងមហាសន្និបាតនោះ ឬក៏មានតែលោកម្នាក់ទេ ដែលគេប្រកាសនោះ?

**ឆ៖** បាទ មានតែខ្ញុំម្នាក់។

**ស៖** ហេតុអ្វីបានជាលោកមកភ្នំពេញចូលរួមមហាសន្និបាតនៅខែ៩ ឆ្នាំ១៩៧៨ តើគេបានឲ្យលោកអាន ឬក៏លោកបានឮថា គេអានចម្លើយសារភាពដែលគេឆ្លើយដាក់លោកដែរឬទេ?

**ឆ៖** អត់មានទេបាទ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានកន្លែងមួយនៅក្នុងចម្លើយទីមួយរបស់សាក្សីរូបនេះ គឺ E3/367 គឺជាសេចក្តីដកស្រង់ ERN 00251440, អង់គ្លេស ERN 00278697 ហើយបារាំង ERN 00486012 ហើយខ្ញុំក៏សូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរបាទ។

[១០:១១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងការសម្ភាសទីមួយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបានឆ្លើយដូចខាងក្រោមនេះ។ ដកស្រង់៖ "នៅពេលដែលខ្ញុំចូលសន្និបាតខួបបក្សនៅក្នុងខែ៩ ឆ្នាំ១៩៧៨ នោះ ប៉ុល ពត បានឲ្យខ្ញុំអានចម្លើយសារភាព មិនដឹងអ្នកណាជាអ្នកឆ្លើយទេ តែជាប់ទាំងឈ្មោះ ខ្ញុំ តាឡាន់ និង ម៉ាំង ទាំងអស់គ្នា"។ តើលោកអាចបញ្ជាក់បានទេ នេះជាចម្លើយត្រឹមត្រូវ ដែលជាហេតុការណ៍ ដែលលោកបានដឹង ឬក៏គេឲ្យលោកអានចម្លើយនេះនៅក្នុងពេលដែលលោកចូលរួមនៅក្នុងសន្និបាតឆ្នាំ១៩៧៨ នោះ?

[១០:១២:៤៣]

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំក៏បានអានមែន។ ដឹងចម្លើយខាងណាៗទេ ចេះតែឆ្លើយដាក់តែផ្តេសតែផ្តាស អ៊ីចឹង។ ខ្ញុំក៏-- អាហ្នឹងដែរ ខ្ញុំបដិសេធដែរ ចម្លើយអ៊ីចឹង។ ខ្ញុំមនុស្សស្មោះត្រង់ អត់បានធ្វើអ្វីទាំងអស់ ចេះតែឆ្លើយដាក់។

**ស៖** ថាតើ ប៉ុល ពត ជាអ្នកឲ្យចម្លើយសារភាពនោះមកលោក ហើយលោកអានដូចដែលលោកបង្ហាញ-- អ៎! ដូចដែលលោកឆ្លើយក្នុងចម្លើយហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** ថាតើៗលោកបានជួប ប៉ុល ពត នៅកន្លែងណាដែលគាត់បានបង្ហាញចម្លើយសារភាពដែលថាមានគេឆ្លើយដាក់លោកហ្នឹង? លោកជួបគាត់នៅកន្លែងណាបាទ?

**ឆ៖** បាទ អាហ្នឹងគាត់ផ្ញើ-- អាហ្នឹងនៅកន្លែងជួបហ្នឹងដឹងកន្លែងណាទេ ខ្ញុំអត់ស្គាល់នៅភ្នំពេញបាទ។

[១០:១៤:២៤]

**ស៖** នៅពេលដែលលោកនិយាយថា គេផ្ញើចម្លើយសារភាពទៅលោក តើលោកទទួល-- បានទទួលនៅកន្លែងណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ៗស្គាល់ ដឹងកន្លែងណាៗ គាត់-- នៅភ្នំពេញ ខ្ញុំអត់ស្គាល់កន្លែងបាទ។

**ស៖** តើលោកនៅចាំទេ ថាលោកបានស្នាក់នៅកន្លែងណានៅភ្នំពេញ ដែលលោកមកចូលរួមមហាសន្និបាតខែ៩ ឆ្នាំ១៩៧៨ នោះ គេស្នាក់នៅកន្លែងណា?

[១០:១៥:០៨]

**ផ៖** បាទ សម្រាកកន្លែងធ្វើមហាសន្និបាតហ្នឹងមានផ្ទះ អាហ្នឹងវែងៗពីរបីជាន់ ខ្ញុំដឹងប៉ុណ្ណឹងបាទ។

**ស៖** តើលោកដឹងដោយរបៀបណាថា ចម្លើយសារភាពដែលគេផ្ញើមកឲ្យលោកហ្នឹង គឺលោកដឹងថា ប៉ុល ពត ជាអ្នកផ្ញើមក? តើលោកដឹងដោយរបៀបណា?

**ផ៖** បាទ គឺដឹងឃើញថាគេផ្ញើមកចម្លើយហ្នឹង ខ្ញុំក៏បានមើល ដឹងចម្លើយហ្នឹងមកពីប្រភពណា? ចេះតែចម្លើយដាក់អ៊ីចឹង អាហ្នឹងគឺខ្ញុំមិនដឹងដែរ ក្តៅក្រហាយដែរពេលហ្នឹង អត់បានធ្វើអី ចេះតែចម្លើយដាក់ៗអ៊ីចឹងបាទ។

**ស៖** តើលោកចាំទេថា តើអ្នកណាជាអ្នកផ្ញើចម្លើយសារភាពហ្នឹងមកឲ្យលោកបាទ?

**ផ៖** បាទ--

**អ្នកបកប្រែ៖**

បាទ សូមកែតម្រូវសំណួរ៖ តើគេឆ្លើយដាក់លោកហ្នឹង ឆ្លើយដាក់របៀបម៉េចបាទ ពីអ្នកបកប្រែ?

**ស៖** សំណួររបស់ខ្ញុំគឺថា អ្នកដែលសរសេរចម្លើយហ្នឹង ថាតើលោកដឹងទេ? តើដែលឆ្លើយដាក់លោកហ្នឹងគឺចម្លើយសារភាពហ្នឹង ឆ្លើយដាក់ថាម៉េច?

**ផ៖** បាទ ខ្ញុំអត់ចាំទេ។ ឆ្លើយដាក់ដឹងម៉េចៗទេចេះតែដាក់មកថា អ៊ីចេះ ថាអ៊ីចុះ ខ្ញុំបាទ ខ្ញុំអត់ចាំពាក្យពេចន៍ហ្នឹងទាំងអស់ខ្លឹមសារហ្នឹងទេបាទ។

**ស៖** តើលោកបានពិភាក្សាជាមួយ ប៉ុល ពត អំពីចម្លើយសារភាពហ្នឹងទេ ក្រោយពីលោកបានទទួល ឬក៏គេផ្ញើឲ្យលោករួចហើយនោះ?

**ផ៖** បាទ អត់បានពិភាក្សាទេបាទ។

**ស៖** នៅក្នុងពេលដែលលោកឆ្លើយសក្ខីកម្មនៅតុលាការនេះ លោកបានបញ្ជាក់មួយចំនួនគឺ ថា តំបន់១០៥ ជាលេខា ហើយនិងប្រធានឈ្មោះ តាសុភា។ តើលោកជិតស្និទ្ធនឹង តាសុភា ហ្នឹងដូចម្តេចដែរ?

[១០:១៨:២២]

**ផ៖** បាទ ជិតស្និទ្ធ គឺតាមធម្មតាដូចតែពេលធ្វើការងារអី ហៅមកប្រជុំតែប៉ុណ្ណឹងបាទ ហើយ

ក្រៅពីហ្នឹងក៏អត់បាន។

**ស៖** ចាតើគាត់ជាបងថ្លៃប្រុសរបស់លោកដែល-- អ៊ំ! ប្អូនថ្លៃរបស់លោកដែលរៀបការជាមួយប្អូនស្រីរបស់លោកហ្នឹងមែនទេ?

**ឆ៖** បាទ មែន រៀបការជាមួយប្អូនស្រីខ្ញុំមែន។

**ស៖** ចាតើពួកគេរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏រៀបការមុនសម័យហ្នឹង?

**ឆ៖** បាទ រៀបការតាំងពីសម័យសម្ដេចឪ។

**ស៖** ចាតើលោកបានជួប តាសុភា ហ្នឹងញឹកញាប់ប៉ុនណានៅក្នុងឆ្នាំ១៩៧៨?

**ឆ៖** បាទមិនបានជួបញឹកញាប់ទេ ពេលប្រជុំបានជួប ពេលអត់ប្រជុំទេ ក៏មិនបានជួបទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងអានជូនលោកស្ដាប់នូវសេចក្ដីដកស្រង់ ចម្លើយរបស់លោកឆ្លើយជូនទៅសហចៅក្រមស៊ើបអង្កេត ដែលទាក់ទងទៅនឹង ហាំ អនស៊ី ដែលខ្ញុំជម្រាបលោកខាងដើម។

**លោក ឌេល លីសាក់៖**

លោកប្រធានឯកសារ E3/366 សេចក្ដីដកស្រង់ ដែលខ្ញុំនឹងអានជូនសាក្សីនោះគឺ ខ្មែរ ERN 00242413 រហូតដល់ 242414, អង់គ្លេស ERN 00250750, បារាំង ERN 283166។ បាទ សូមអនុញ្ញាតបង្ហាញលើអេក្រង់ផងដែរបាទ។

[១០:២១:០៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីនៅក្នុងចម្លើយរបស់ ហាំ អនស៊ី នោះគាត់ឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេត ហើយគាត់ឆ្លើយថា៖ “តាសុភា ខ្ញុំ-- ឲ្យខ្ញុំអានចម្លើយសារភាពពីមជ្ឈិម ដែលកងពល៩២០ បានឆ្លើយដាក់អ្នកស្គាល់គ្នា និងទាហានគ្នាឯង។ ខ្ញុំមិនចាំឈ្មោះអ្នកឆ្លើយនោះទេ។ ខ្ញុំចាំអ្នកដែលគេឆ្លើយដាក់ម្នាក់ជាប្រធានអនុសេនាធំឈរជើងនៅក្នុងស្រុកកែវសីមា”។ បាទ ចប់សេចក្ដីដកស្រង់។ តើលោកអាចបញ្ជាក់បានទេ ថាតើចម្លើយសារភាពមកពីមជ្ឈិម ត្រូវបានបញ្ជូនមកតំបន់ គឺជាពិសេសទៅ តាសុភា នៅក្នុងតំបន់១០៥ នោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំអត់យល់ទេបាទ។

**ស៖** នៅខែ៩ ឆ្នាំ១៩៧៨ នៅក្នុងមហាសន្និបាទ ដែលលោកបានពិភាក្សានោះ ថាតើ ប៉ុល ពត បានប្រកាសប្តូរគោលនយោបាយ ទាក់ទងពីរឿងការចាប់ខ្លួនមនុស្សដែរឬទេ?

[១០:២៣:០២]

**ឆ៖** បាទ គាត់បានប្រកាសមែន មិនឲ្យចាប់ មិនឲ្យចង មានការខុសត្រូវគឺមានតែអប់រំ ស្រុកក៏ដោយ ខេត្តក៏ដោយ កងពលក៏ដោយ គឺអត់មានសិទ្ធិនឹងចាប់ និងចងបាទ។

**ស៖** តើ ប៉ុល ពត បាននិយាយថា ជនស៊ីវិល ហើយនិងកម្មាភិបាលយោធា ត្រូវបញ្ឈប់ការសម្លាប់ និងចាប់ខ្លួន លុះត្រាតែមានការកោះពីថ្នាក់មជ្ឈិម តុលាការមជ្ឈិមជាមុនសិន?

**ឆ៖** បាទ ដូចខ្ញុំបញ្ជាក់ខាងលើ ព្រោះមានរឿងមានរ៉ាវអីក៏ដោយ គឺខេត្ត ស្រុក កងពល បើអត់មានដីកាកោះពីគណៈមជ្ឈិម គឺអត់មានសិទ្ធិនឹងឃាត់ខ្លួនគេទេ មានការខុសត្រូវ មានតែការអប់រំ និងណែនាំបាទ។

**ស៖** នៅក្នុងចម្លើយរបស់លោកចុងក្រោយទៅសហចៅក្រមស៊ើបអង្កេត លោកបានអានឯកសារមួយដែលជាឯកសារ D189.1, E3/764។ ឯកសារដែលគេអានជូនលោកស្តាប់នោះគឺ ចុះថ្ងៃទី២០ មិថុនា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា ដកស្រង់៖ “ការណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ស្តីអំពីនយោបាយរបស់បក្សទាក់ទងទៅហ្នឹងជនដែលភ័ន្តច្រឡំចូល សេ.អ៊ី.អា ហើយធ្វើជាភ្នាក់ងារ ឬក៏ចូល កា.ហ្សេ.បេ ហើយប្រឆាំងបក្ស បដិវត្តន៍ ហើយនិងប្រជាជន និងកម្ពុជាប្រជាធិប-តេយ្យ” បញ្ចប់នូវចំណងជើង។ តើលោកចាំដែរឬទេនៅក្នុងសម្ភាសចុងក្រោយរបស់លោកជាមួយសហចៅក្រមអង្កេត សហចៅក្រមអង្កេតបានអាឯកសារហ្នឹងនជូនលោកស្តាប់។ ថាតើឯកសារដែលគេឲ្យលោកស្តាប់នេះ ជាផ្នែកនៃនយោបាយថ្មីទាក់ទងនឹងការចាប់ខ្លួន ដែលលោកបានស្តាប់ឮថាគេបានប្រកាសនៅក្នុងមហាសន្និបាតខែ៩ ឆ្នាំ១៩៧៨ ដែរឬទេ?

**ឆ៖** បាទ អាហ្នឹងគឺ លោកសហចៅក្រមបានយកឯកសារហ្នឹងអានឲ្យខ្ញុំស្តាប់មែន។ មិនឲ្យចាប់ មិនឲ្យចងបាទ។ សូមអស់។

**ស៖** ឯកសារដែលគេអានជូនលោកស្តាប់នោះ តើលោកចាំដែរឬទេ ថានោះជាផ្នែកនៃនយោ-បាយថ្មី ដែលគេប្រកាសនៅក្នុងមហាសន្និបាត ខែ៩ ឆ្នាំ៧៨ ដែរឬទេ?

**ឆ៖** បាទ មែនបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ E3/764 ដែលជាឯកសារ D188 ហើយដាក់លើអេក្រង់ ហើយខ្ញុំនឹងអានជូនសាក្សីស្តាប់ ហើយនឹងសួរទៅសាក្សី កថាខណ្ឌចុងក្រោយនូវភាគខាងបញ្ចប់នៃឯកសារនោះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:២៨:០២]

**លោក ឌេល លីសាក់៖**

ដើម្បីកែតម្រូវនូវកំណត់ត្រា ខ្ញុំបានដកស្រង់ពីសហសេវិក គឺថាឯកសារដែលខ្ញុំអានគឺបកប្រែមិនត្រឹមត្រូវទេ គឺឯកសារនៅក្នុងសំណុំរឿងដំបូងនោះគឺ D189.1 គឺថាមានពីរដែលឲ្យជាលេខ D មួយគឺថា គឺ E3/764 ប៉ុន្តែនៅក្នុងឯកសារនេះគឺថា មួយទៀតគឺថា ឯកសារ E3/763។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវផ្នែកចុងក្រោយជូនសាក្សីស្តាប់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

នៅផ្នែកចុងក្រោយនៃឯកសារនេះ លោក សៅ សារុន គឺមានកថាខណ្ឌមួយនិយាយអំពី សេចក្តីណែនាំអនុវត្ត សម្រាប់ការណែនាំនោះ។ ផ្នែកទីមួយនៃកថាខណ្ឌនោះនៃការណែនាំនោះ និយាយដូចខាងក្រោមនេះ។ ដកស្រង់៖ “ស្នើគ្រប់ភាគ គ្រប់តំបន់ គ្រប់អង្គភាពយោធា យកសេចក្តីណែនាំខាងលើនេះទៅអប់រំ និងធ្វើមីទ្ទិងនៅក្នុងបក្ស អង្គការស្ហូល ក្រសួង មន្ទីរ ក្នុងអង្គភាពកងទ័ព ក្នុងសហករណ៍ ក្នុងរោងចក្រ ក្នុងការដ្ឋាន ដើម្បីឲ្យមហាជនទាំងអស់គ្នាក្តាប់បាននូវគោលនយោបាយនេះរបស់បក្ស”។

**ស៖** ឥឡូវនេះ សំណួរទីមួយរបស់ខ្ញុំទៅលោកនោះ តើលោកចាំបានដែរឬទេ ថាតើឯកសារហ្នឹងគេបានចែកជូនទៅលោក ឬក៏តំណាងផ្សេងទៀតនៅក្នុងសន្និបាតបក្ស ដើម្បីឲ្យលោកត្រឡប់ទៅវិញ អាចយកឯកសារហ្នឹងទៅផ្សព្វផ្សាយ? តើលោកចាំថា គេបានចែកឯកសារបែបនេះដែរឬទេ?

**ឆ៖** បាទ១ គឺបញ្ហានេះគឺមែន គេផ្សព្វផ្សាយ គេអានដូចលោកចៅក្រមបានអានខ្ញុំ-- ឲ្យអានខ្ញុំ

ស្តាប់បាទ។ តែឯកសារហ្នឹង គឺត្រឡប់ទៅពីសន្និបាត បានគេចែកតាមក្រោយបាទ។

**ស៖** តើលោកអាចប្រាប់ខ្ញុំដែរឬទេ ថាតើលោកបានធ្វើអ្វីខ្លះ នៅពេលដែលលោកត្រឡប់ទៅមណ្ឌលគិរីវិញ ដើម្បីផ្សព្វផ្សាយ ហើយនិងអនុវត្តនូវនយោបាយថ្មីរបស់បក្សនេះ នៅក្នុងតំបន់របស់លោកនោះ?

[១០:៣១:០៣]

**ឆ៖** បាទ បានផ្សព្វផ្សាយ ខាងទាំងខាងស្រុក ទាំងខាងឃុំ បាទបានផ្សព្វផ្សាយ ដើម្បីឲ្យគេយល់ជ្រួលជ្រាបទៅទាំងអស់នៅក្នុងសេចក្តីប្រកាសបាទ។

**ស៖** តើលោកមានធ្វើមីទ្ទីង ឬក៏កិច្ចប្រជុំ ដើម្បីប្រកាសផ្សព្វផ្សាយអំពីគោលនយោបាយរបស់បក្សថ្មីនេះដែរឬទេ?

**ឆ៖** បាទ គឺហៅគេមកប្រជុំ ហើយម្តងនេះគឺឲ្យគេទៅផ្សព្វផ្សាយតាមស្រុក តាមសហករណ៍បាទ។ ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោក សារុន។ លោកបានបញ្ជាក់ថា ប៉ុល ពត បានប្រកាសនៅក្នុងសន្និបាតឆ្នាំ៧៨ ខែ៩ ដែលថាប្រកាសថា ផ្សារត្រូវបើកសាជាថ្មី ហើយប្រជាជនត្រូវអនុញ្ញាតឲ្យត្រឡប់មកទីក្រុង ហើយលោក១ ប៉ុល ពត បានបញ្ជាក់ថា ហេតុផលដែលគេផ្លាស់ប្តូរនេះ គឺដោយសារតែអង្គការបានបោសសម្អាតខ្មាំងអស់ហើយ។ តើគេបើកផ្សារសាជាថ្មី ហើយប្រជាជនត្រូវអនុញ្ញាតឲ្យត្រឡប់មកទីក្រុងសាជាថ្មីឡើងវិញ នៅក្នុងខែ៩ ឆ្នាំ៧៨ គឺបន្ទាប់ពីមានមហាសន្និបាតនោះដែរឬទេ?

[១០:៣២:៤១]

**ឆ៖** បាទ អាហ្នឹងគឺគេប្រាកដហើយ គឺខ្ញុំក៏បានជម្រាបលោកចៅក្រមប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៥៧]

**ក្រឡាបញ្ជី!**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមរំឭកឡើងនូវចំណុចដែលយើងបានបញ្ឈប់នៅពេលមុនពេលសម្រាកនេះ។ ចំណុចដែលខ្ញុំសួរលោកគឺថា ខ្ញុំមិនមែនចង់ឲ្យលោកបញ្ជាក់ឡើងវិញថា តើអ្វីដែល ប៉ុល ពត បាននិយាយនៅក្នុងមហាសន្និបាត គឺថាការនិយាយអំពីការបើកផ្សារសាជាថ្មី និងការត្រឡប់មកទីក្រុងនោះវិញទេ។ អ្វីដែលខ្ញុំចង់សួរលោក គឺថាបន្ទាប់ពីមហាសន្និបាតនុំង បានន័យថានៅក្នុងរយៈពេលបីខែចុងក្រោយនៃរបបខ្មែរក្រហម គឺចាប់ពីខែ៩, ៧៨ មកនុំង តើបក្សពិតជាចាប់ផ្តើមបើកនូវទីផ្សារ និងឲ្យដំណើរការនូវហិរញ្ញ-- នូវរូបិយវត្ថុដែរឬទេ? តើមានការអនុវត្តនូវគោលនយោបាយទាក់ទងទៅនឹងការបើកផ្សារ និងឲ្យចាយលុយសាជាថ្មីនេះដែរឬទេ?

[១០:៥៥:៥៧]

**លោក សៅ សារុន៖**

**ឆ៖** បាទ គាត់បានបញ្ជាក់អ៊ីចឹងមែនបាទ។

**ស៖** ខ្ញុំដឹងថា នេះគឺជាអ្វីដែល ប៉ុល ពត បាននិយាយហើយ ប៉ុន្តែខ្ញុំចង់ដឹងថា តើអាការនិយាយហ្នឹង វាទៅជាការអនុវត្តជាក់ស្តែងដែរឬទេ? តើមានការអនុវត្តជាក់ស្តែងដែរឬទេ នៅក្នុងខែ៩ រហូតដល់ក្រោយមកហ្នឹង? តើការឲ្យបើកផ្សារសាជាថ្មីឡើងវិញហ្នឹង វាកើតឡើងដែរឬអត់ ឬមួយក៏អត់មានការបើកផ្សារសាជាថ្មីនោះទេ?

**ឆ៖** បាទ គឺខ្ញុំអត់យល់ទេ ពីព្រោះចប់ប្រជុំហ្នឹងហើយ ខ្ញុំមិនបានមកភ្នំពេញទេ។ ទម្រាំយួនវ៉ៃរំដោះស្រុកខ្មែរយើង។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅលើ ទៅឯកសារដែលមាន ដែលលោកបានបញ្ជាក់ពីមុននេះ គឺឯកសារដែលលោកបានបញ្ជាក់ថាបានប្រកាសនៅក្នុងមហាសន្និបាតបក្សដោយ ប៉ុល ពត។ ហើយលោកក៏បានបញ្ជាក់ថា ឯកសារហ្នឹងត្រូវបានប្រគល់ទៅជូនលោក ហើយលោកបានត្រឡប់ទៅខេត្តមណ្ឌលគិរីវិញ ហើយលោកបានណែនាំប្រជាជននៅមណ្ឌលគិរីហ្នឹងឲ្យយល់អំពីចំណុចនេះ។

**លោក ឌេល លីសាក់៖**

ដូច្នេះ ខ្ញុំសូមលោកប្រធានអនុញ្ញាតដាក់បង្ហាញនៅលើកឯក-- នៅលើអេក្រង់ គឺឯកសារដែលមានលេខ E3/764 ហើយចំណុចដែលខ្ញុំចង់ដកស្រង់យកមកសួរសាក្សីហ្នឹង គឺខ្មែរ ERN ដែលមានលេខ 0079280 (ស៊ីក), ភាសាអង់គ្លេសគឺមានលេខ 00275218 ភាសាបារាំងគឺមានលេខ 00623529។ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានដាក់បង្ហាញនៅលើអេក្រង់។

[១០:៥៨:១២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សារុន ខ្ញុំនឹងអានជូនលោកទៅលើផ្នែកនៃឯកសារ ដែលនិយាយថា-- ដែលៗជាឯកសារនោះបានផ្តល់ជូនលោកនៅក្នុងមហាសន្និបាត ហើយឯកសារហ្នឹងលោកបានយកត្រឡប់ទៅតំបន់របស់លោកវិញ ហើយលោកបានជម្រាបដល់ប្រជាជន ហើយអ្វីដែលខ្ញុំចង់អាន គឺដូចតទៅនេះ៖ "ទីបី ចំពោះអ្នកចូល សេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ ពីឆ្នាំ៧៥ ដល់៧៨។ ចំពោះអ្នកដែលចូល សេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ នៅពេលក្រោយរំដោះហើយ បក្សបែងចែកជាពីរប្រភេទដូចតទៅ៖ ប្រភេទទីមួយ អ្នកណារឹងរូស បន្តធ្វើសកម្មភាពប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា

ប្រឆាំងរដ្ឋអំណាចបដិវត្តន៍ កម្មករ កសិករ ប្រឆាំងរបបសម្ហូហភាព សង្គមនិយម ប្រឆាំងប្រជាជនកម្ពុជា និងប្រឆាំងកម្ពុជាប្រជាធិបតេយ្យតទៅទៀត អ្នកនោះត្រូវមានទោស។ ពីព្រោះអ្នកនោះធ្វើសកម្មភាពក្បត់ដោយចេតនា ដោយគោលជំហរប្រឆាំងដាច់ខាត ដោយគោលជំហរពេញចិត្តពេញថ្លើម បម្រើខ្មាំងសត្រូវជា សេ.អ៊ី.អា ឬជាយួន ឬជា កា.ហ្សេ.បេ។ អ្នកនោះ គេបែងចែកព្រំដែនរបស់គេច្បាស់ហើយ។ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាត្រូវតែកម្ចាត់"។ សំណួររបស់ខ្ញុំ គឺថាតើលោកចាំដែរឬទេ ថាតើមានមតិយោបល់អ្វីដែលប៉ុល ពត បានលើកឡើងពាក់ព័ន្ធទៅនឹងគោលនយោបាយចំណុចមួយនេះ គឺមតិយោបល់ដែលប៉ុល ពត ធ្វើនៅក្នុងមហាសន្និបាតឆ្នាំ៧៨ ខែ៩?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺអ៊ីចឹងមែន គឺលោកសហចៅក្រម គាត់ក៏យកឯកសារនេះអានឲ្យខ្ញុំស្ដាប់ ហើយកាលសម័យសន្និបាតហ្នឹងក៏បានបញ្ជាក់អ៊ីចឹងដែរ។ បាទ សូមអស់។

[១១:០០:៥០]

**ស៖** តើលោកចាំដែរឬទេ ថាតើមានការចាប់ខ្លួនបន្ថែមទៀតដែរឬទេ ចំពោះជនក្បត់ ឬក៏ខ្មាំងដែលគេចោទប្រកាន់នៅក្នុងខេត្តមណ្ឌលគិរី ក្រោយឆ្នាំ-- ក្រោយខែ៩ ឆ្នាំ១៩៧៨ គឺក្រោយមហាសន្និបាតនោះ តើមានការចាប់ខ្លួនបន្ថែមទៀតទេ?

**ឆ៖** បាទ អត់មានទេ ចាប់ពីខែ៩ ២០០៨ (ស៊ីក) តាំងពីមហាសន្និបាតហ្នឹង គឺអត់បានមានចាប់ជនណាម្នាក់ទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំព្យាយាមរំឭកលោកសាជាថ្មី ដោយលើកឡើងនូវព្រឹត្តិការណ៍មួយចំនួននៅចុងឆ្នាំ១៩៧៨។ នៅចុង៧៨ តើលោកមានធ្វើដំណើរម្តងទៀតដែរឬទេមកទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ បញ្ហាហ្នឹងដូចខ្ញុំភ្លេចភ្លាំងហើយ វាយូរហើយបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអាននូវកិច្ចសម្ភាសន៍ទីមួយរបស់សាក្សី ជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺឯកសារដែលមានលេខ E3/367 ហើយឯកសារដែលខ្ញុំយោង គឺខ្មែរ ERN មានលេខ 00251439, ភាសាអង់គ្លេស គឺមានលេខ 00278696 និងភាសាបារាំង គឺមានលេខ 00486012 ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:០២:៥៩]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាដំបូងរបស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេត លោកបានបញ្ជាក់ដូចតទៅ "ប្រហែលជាមួយ ឬពីរសប្ដាហ៍មុនពេលវៀតណាមចូលមកទីក្រុងភ្នំពេញ ខ្ញុំបានទទួលទូរលេខមួយពី ប៉ុល ពត។ ខ្ញុំមិនបានឃើញថា ដាក់ចម្លងទៅអ្នកណាទេ ថាឲ្យខ្ញុំ សុភា, តាឡូន និងតាលក ទៅប្រជុំនៅភ្នំពេញ-- តាឡាន់, តាលក ទៅប្រជុំនៅភ្នំពេញ"។ តើអ្វីដែលខ្ញុំអានហ្នឹងធ្វើឲ្យលោកនឹកឃើញដែរឬទេ នៅចុងបំផុតនៃឆ្នាំ៧៨ លោកបានធ្វើដំណើរទៅប្រជុំនៅភ្នំពេញនោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺបានទៅប្រជុំមែន។ ឈ្មោះទាំងអស់ហ្នឹង គឺត្រឹមត្រូវហើយ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាគេជម្រាបឲ្យលោកទៅប្រជុំហ្នឹង គឺគេប្រាប់លោកតាមរយៈទូរលេខដែលផ្ញើមកដោយប៉ុល ពត?

**ឆ៖** បាទ គេផ្ញើតាមទូរលេខឲ្យមកប្រជុំ។

**ស៖** តើទូរលេខនោះមានបញ្ជាក់អំពីកម្មាភិបាលផ្សេងៗនៅក្នុងតំបន់ ដែលត្រូវមកប្រជុំនៅទីក្រុងភ្នំពេញដែរឬទេ? តើមានបញ្ជាក់ឈ្មោះកម្មាភិបាលផ្សេងៗទៀតដែរឬទេ?

**ឆ៖** បាទ អត់មានទេ មានតែ ដូចជម្រាបខាងលើអំមិញហ្នឹង។

[១១:០៥:០៥]

**ស៖** នេះគឺជាអ្វីដែលខ្ញុំចង់សួរលោក តើទូរលេខហ្នឹងបញ្ជាក់ច្បាស់ថា តាសុភា គឺជាអ្នកដែលត្រូវមកភ្នំពេញជាមួយលោកដែរទេ? តើគេមានដាក់ឈ្មោះអីច្បាស់ៗអីចឹងដែរឬទេ?

**ឆ៖** បាទ គឺដាក់ច្បាស់ៗអីចឹងតាមទូរសារបាទ។

**ស៖** តើលោកចាំដែរឬទេថា អនុលេខាកងពល៩២០ ឈ្មោះតាគីម ត្រូវបានគេហៅឲ្យមកប្រជុំជាមួយលោកនៅភ្នំពេញដែរឬទេ?

**ឆ៖** បញ្ហាហ្នឹងគឺខ្ញុំភ្លេចអស់ហើយ អត់យល់ទេបាទ។

**ស៖** តើលោកចាំដែរឬទេ តើលោកជួបអ្នកណាខ្លះនៅទីក្រុងភ្នំពេញ?

**ឆ៖** បាទ ជួបតែប៉ុល ពត។

**ស៖** តើលោកចាំដែរឬទេ ថាមានមេដឹកនាំដទៃទៀត នៅក្នុងកិច្ចប្រជុំនៅទីក្រុងភ្នំពេញពេលនោះ?

**ឆ៖** ដូចអត់ឃើញទេ ឃើញតែប៉ុល ពត តែម្នាក់ហ្នឹង។

[១១:០៦:៥៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវសេចក្ដីដកស្រង់ពីកិច្ចសម្ភាសន៍ដដែលនេះ គឺឯកសារ E3/367 ហើយជាការបន្តពីទំព័រ-- បន្តនៅទំព័រដដែលគឺបន្តពីអ្វីដែលខ្ញុំអានពីមុនមកនោះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសារុន នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត គឺបន្តអំពីប្រធានបទដដែល គឺកិច្ចប្រជុំនៅទីក្រុងភ្នំពេញ លោកបានដកស្រង់ដូចតទៅ៖ "ពួកខ្ញុំទាំងបួននាក់ទៅជួបប៉ុល ពត, សុន សេន និងនួន ជា នៅមន្ទីរប៉ុល ពត ក្រោយវាំងនោះដដែល"។ តើលោកអាចបញ្ជាក់បានដែរឬទេ ថានេះជាចម្លើយត្រឹមត្រូវ ដែលថាលោកបានជួបជាមួយនឹងបុគ្គលទាំងអស់នេះ នៅពេលដែលលោកមកដល់ទីក្រុងភ្នំពេញ?

[១១:០៨:០១]

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងដូចខ្ញុំបានជម្រាបបញ្ជាក់ជូនលោកសហចៅក្រមត្រឹមត្រង់អីចឹងបាទ។

**ស៖** បុគ្គលដែលលោកបញ្ជាក់ឈ្មោះថា តាឡាន់ តើលោកអាចប្រាប់បានដែរឬទេ ថាតើគាត់មានតួនាទីអ្វីដែរនៅក្នុងខែ៩ ឆ្នាំ៧៨ហ្នឹង តាឡាន់ហ្នឹង គឺថាតើគាត់មានតួនាទីអ្វីដែរ?

**ឆ៖** បាទ គាត់ តួនាទីគាត់ខាងយោធា គឺវរសេនាតូច។

**ស៖** តើគាត់ជាមេបញ្ជាការមួយនៃវរសេនាតូចមួយ ក្នុងចំណោមវរសេនាតូចទាំងពីរនៅក្នុងកងពល៩២០នុ៎ង តើមែនទេ?

**ឆ៖** បាទគាត់ជាវរសេនាតូច ដឹងគេហៅលេខប៉ុន្មានទេ ខ្ញុំភ្លេចហើយពីព្រោះវាយូរហើយបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវចំណុចមួយចំនួន គឺជាចម្លើយដែលឆ្លើយដោយ តាឡាន់ ដែលសាក្សីបានបញ្ជាក់ថា ជាអ្នកមកជាមួយគាត់នៅក្នុងពេលប្រជុំនេះ។ ខ្ញុំអាននេះ ដើម្បីឲ្យសាក្សីគាត់រំឭកឡើងវិញ។ ឯកសារដែលខ្ញុំអានគឺ D125/151 ហើយចំណុចដែលខ្ញុំចង់ដកស្រង់ហ្នឹង គឺមានលេខ 00236734, ភាសាអង់គ្លេស គឺមានលេខ 00244338 និងភាសាបារាំងគឺមានលេខ 00274328។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី តាឡាន់ បានឆ្លើយដូចតទៅនេះ គឺការឆ្លើយរបស់គាត់ទាក់ទងទៅនឹងការធ្វើដំណើរថ្ងៃមួយ ក្នុងឆ្នាំ១៩៧៨ "ខ្ញុំត្រូវបាន តាសុភា និងតាសារុន ហៅឡើងកប៉ាល់ហោះស្ពាបកាត់ទៅភ្នំពេញ។ អ្នកដែលទៅជាមួយខ្ញុំមានតា គីម ជាអនុប្រធានកងពល៩២០ តាលក បងរបស់ តាឡាំង និងជាសមាជិកគណៈតំបន់១០៥ និងតារៀង។ នៅពេលទៅដល់ពោធិ៍ចិនតុង តាគីម ត្រូវបានគេឃាត់ខ្លួន។ ចំណែកតា សុភា វិញ មួយយប់ក្រោយមក ខ្ញុំបានឃើញគាត់ត្រូវគេហៅឡើងឡានទៅបាត់រហូត។" ខ្ញុំសូមបញ្ចប់ត្រឹមចំណុចនេះ។

[១១:១១:៣៨]

តើអ្វីដែលខ្ញុំបានអានហ្នឹងធ្វើឲ្យលោកនឹកឃើញឃើញដែរឬទេថា តាគីម អនុប្រធានកងពល--អនុប្រធានគណៈតំបន់១០៥ ត្រូវបានគេហៅទៅទីក្រុងភ្នំពេញ ហើយត្រូវបានគេឃាត់ខ្លួនភ្លាមៗនៅពេលទៅដល់ព្រលានយន្តហោះនោះ? តើលោកនឹកឃើញដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ពេលនោះ គឺឃើញ។ ទៅដល់ភ្នំពេញហ្នឹង គេហៅទៅឃាត់ខ្លួនហ្នឹងៗអត់ដឹងរឿងអីសោះបាទ។ ស្រាប់តែបាត់ៗទៅ។

**ស៖** តើអ្នកណាដែលមកព្រលានយន្តហោះហ្នឹង ហើយនាំគាត់ទៅៗហ្នឹង? អ្នកដែលមកព្រលានយន្តហោះ ហើយនាំគាត់យកទៅហ្នឹងជានរណា?

**ឆ៖** អត់ស្គាល់គេទេ។ អត់ដឹងអ្នកណាៗទេបាទ។

[១១:១២:៤៤]

**ស៖** តើមានមនុស្សប៉ុន្មាននាក់ដែលមកយក តាគីម ទៅហ្នឹង?

**ឆ៖** បញ្ហាហ្នឹងខ្ញុំភ្លេចអស់ហើយ មិនដឹងប៉ុន្មានៗនាក់ទេ ឃើញគេ--។

**ស៖** តើលោកឃើញ តាគីម ម្តងទៀតទេក្រោយ-- នៅពេលក្រោយមក?

**ឆ៖** បាទ អត់ឃើញទេ។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ តើមានអ្វីកើតឡើងចំពោះ តាសុភា ដែលជាប្អូនថ្លៃរបស់លោកនោះ នៅពេលដែលគាត់ធ្វើដំណើរជាមួយលោកដែរនោះ តើមានអីកើតឡើង?

**ឆ៖** បាទ ពេលធ្វើដំណើរមកភ្នំពេញ ឥតឃើញបញ្ហាអីកើតឡើងសោះបាទ។

[១១:១៤:០៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន ក្នុងពេលនេះ ខ្ញុំសូមអនុញ្ញាតរំឭកដល់សាក្សី ខ្ញុំសូមអាននូវកិច្ចសម្ភាសន៍របស់ខាងសហចៅក្រមស៊ើបអង្កេតជាមួយ ហាំ អនស៊ី គឺឯកសារដែលមានលេខ E3/366 ភាសាខ្មែរ គឺមានលេខ 00242413, ភាសាបារាំងគឺមានលេខ 00283165 និងភាសាអង់គ្លេស គឺមានលេខ 00250750 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សារុន នៅក្នុងចម្លើយរបស់លោក ហាំ អនស៊ី គាត់បាននិយាយដូចតទៅនេះ “ពេលមួយខ្ញុំបានប្រជុំជាមួយតាលក និងតាសារុន ពួកគាត់ប្រាប់ខ្ញុំថា តាសុភាត្រូវបានគេយកទៅរៀនសូត្រនៅភ្នំពេញហើយ”។ តើត្រឹមត្រូវដែរឬទេ ដែលថា តាសុភា ត្រូវបានគេយកទៅរៀនសូត្រនៅពេលដែលលោកនៅទីក្រុងភ្នំពេញនោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺត្រឹមត្រូវ។ គេថាដកយកទៅរៀនសូត្រ ប៉ុន្តែបាត់រហូតអត់ឃើញមកវិញ។

**ស៖** តើលោកចាំដែរឬទេថា នៅពេលដែលលោកជួបជាមួយ ប៉ុល ពត, នួន ជា និងសុន សេន ហ្នឹង តើពួកគេនុំងមាននិយាយអ្វីទាក់ទងនឹង តាសុភា ទេនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** បាទ តាមខ្ញុំចាំ គឺអត់ឮនិយាយអ្វីសោះបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអានឯកសារដែលមានលេខ E3/367 ដែលជាកិច្ចសម្ភាសន៍ទីមួយរបស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ហើយឯកសារនុ៎ងគឺ ERN ភាសាខ្មែរមានលេខ 00251439, ភាសាអង់គ្លេសមានលេខ 00278696 ហើយនិងភាសាបារាំងគឺមានលេខ 00486012 ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ផងដែរ។ សូមលោកប្រធានអនុញ្ញាត។

[១១:១៦:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ក្នុងកិច្ចសម្ភាសន៍ទីមួយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ប៉ុល ពត ជាអ្នក-- ប៉ុល ពត និយាយថាឲ្យពួកខ្ញុំប្រឹងប្រែងពង្រឹងកម្លាំង និងប្រយុទ្ធទប់ទល់ជាមួយវៀតណាម។ ពេលនោះ គាត់មិនបាននិយាយអំពីអ្នកណាជាជនក្បត់នោះទេ ប៉ុន្តែគាត់និយាយថា ឲ្យខាងយោធាគឺ សុភា ទៅធ្វើការខាងយោធាបន្តិចសិន។ ហើយឲ្យពួកខ្ញុំបីនាក់ផ្សេងទៀតជិះយន្តហោះត្រឡប់មកកោះញែកវិញ។ ចាប់ពីពេលនោះមក សុភា ត្រូវបានបាត់ខ្លួនរហូត។ " តើនេះជាចម្លើយដែលត្រឹមត្រូវដែរឬទេ ដែលថា ប៉ុល ពត បាននិយាយអំពី តាសុភា នៅពេលដែលលោកជួបជាមួយគាត់នៅក្នុងការប្រជុំនោះ?

[១១:១៨:១១]

**ឆ៖** បាទ គឺត្រឹមត្រូវហើយ គឺពង្រឹង គាត់បានបញ្ជាក់ថាពង្រឹងកម្លាំង ដើម្បីប្រយុទ្ធទប់ទល់នឹងៗយួនហ្នឹង គឺត្រឹមត្រូវហើយបាទ។

**ស៖** តើគាត់មាននិយាយដែរឬទេ ដែលថាគាត់បង្ហាញអំពី តាសុភា ដែលឲ្យនៅទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ បាននិយាយ គាត់ថាឲ្យនៅធ្វើការបន្តទៀតខាងយោធា ប៉ុន្តែបន្តបាត់រហូត អត់ឃើញត្រឡប់ទៅវិញសោះ។

**ស៖** លោក សារុន ដើម្បីរំឭកលោកឲ្យបានច្បាស់អំពីពេលវេលានៃកិច្ចប្រជុំនេះ យើងមានបញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ ដែលរាយការណ៍អំពីសមាជិកមន្ទីរ-- តំបន់១០៥ គឺ ប៊ុត ភី ហៅ សុភា

ត្រូវបានចាប់ខ្លួននៅក្នុងខែ៩ ឆ្នាំ៧៨ គឺឯកសារដែលមានលេខ D108/26.280 ហើយភាសាខ្មែរគឺមានលេខ 00086832, ភាសាអង់គ្លេសគឺមាន 00789507 ហើយយើងមានចម្លើយសារភាពរបស់មន្ទីរ ស-២១ នៃអនុលេខាកងពល៩២០ ឈ្មោះ ចាន់ ខៀម ចុះថ្ងៃ-- ចុះខែធ្នូ ឆ្នាំ៧៨ គឺឯកសារដែលមានលេខ D159.3.4 ហើយលោកបាននិយាយថា ដំណើរទស្សនកិច្ចរបស់លោកនោះ គឺប្រហែលជាពីរបីសប្តាហ៍មុនពេលវៀតណាមចូល។ តើលោកអាចរំឭកបានដែរឬទេថា ដំណើរទស្សនកិច្ចរបស់លោកហ្នឹង គឺនៅពេលដែល សុភា និង គីម ត្រូវបានគេចាប់ខ្លួនគឺ មិនមែនប្រហែលពីរបីអាទិត្យទេ គឺប្រហែលមួយខែមុនពេលវៀតណាមចូលមកប្រទេស។ តើវាត្រឹមត្រូវដែរឬទេដែលថា ការធ្វើដំណើររបស់លោកមកទីក្រុងភ្នំពេញនោះ វាអាចកើតឡើងមុននេះបន្តិច?

[១១:២០:៥២]

**ឆ៖** បាទ បញ្ហានេះគឺខ្ញុំសូមលោកបញ្ជាក់ថែម-- បញ្ជាក់វិញទៀត បញ្ហាសំណួរហ្នឹងបាទ។

**ស៖** យើងមានកំណត់ត្រា ដែលបញ្ជាក់ថា សុភា ត្រូវបានចូលនៅ-- ត្រូវបានគេចាប់មកមន្ទីរ ស-២១ ហ្នឹងគឺខែ-- គឺថ្ងៃ០៦ ខែធ្នូ ឆ្នាំ៧៨។ តើវាអាចធ្វើឱ្យលោកនឹកឃើញដែរឬទេ ថានៅពេលដែលលោកមកភ្នំពេញ ដើម្បីចូលរួមប្រជុំហ្នឹងគឺមានរយៈពេលប្រហែលមួយខែ មុនពេលវៀតណាមមកដល់?

**ឆ៖** បាទបញ្ហាហ្នឹងគឺខ្ញុំបាត់ការចងចាំ ភ្លេចអស់ហើយវាយូរពេក។

**ស៖** តើក្រោយពេលដែលលោកធ្វើដំណើរជាមួយគាត់ទៅភ្នំពេញ ហើយនៅពេលក្រោយមកហ្នឹងតើលោកធ្លាប់ជួប តាសុភា ហ្នឹងម្តងទៀតទេ គឺក្រោយពីធ្វើដំណើរទៅភ្នំពេញហើយនោះ?

**ឆ៖** បាទ អត់ដែលជួបទេ តាំងពីថា គេឃាត់ថាឱ្យនៅធ្វើការសិនហ្នឹង គឺតាំងពីហ្នឹងមកមិនដែលជួបទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីសំណួរមួយចំនួនទៀត ទាក់ទងទៅនឹងមន្ទីរសន្តិសុខភ្នំក្រៀល (ស៊ីក) នៅក្នុងខេត្តមណ្ឌលគិរី។ តើលោកអាចប្រាប់បានដែរឬទេ ថាតើអ្នកណាជាអ្នកគ្រប់គ្រង ត្រួតត្រាទៅលើមន្ទីរសន្តិសុខភ្នំក្រៀល (ស៊ីក) នៅក្នុងខេត្តមណ្ឌលគិរីនោះ?

**ឆ៖** បាទ ខ្ញុំចង់ឱ្យបញ្ជាក់ថា ភ្នំក្រៀលហ្នឹង វាអត់មានទេខេត្តមណ្ឌលគិរី បាទសូមបញ្ជាក់ម្តងទៀតបាទ។

[១១:២៣:១៥]

**អ្នកបកប្រែ៖**

អ្នកបកប្រែសូមកែតម្រូវ គឺភ្នំក្រោល។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមទោស នេះជាការ ជាបញ្ហានៃការអានគឺ ភ្នំក្រោល គឺមន្ទីរសន្តិសុខភ្នំក្រោល។ តើអ្នកណាជាអ្នកគ្រប់គ្រងទៅលើមន្ទីរសន្តិសុខភ្នំក្រោលនោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ពីមុនគឺមានតែ សុភា ទេបាទ។

**ស៖** តើ សុភា គាត់រាយការណ៍ទៅអ្នកណាដែរ?

**ឆ៖** បាទ កាលហ្នឹងគឺគាត់រាយការណ៍មកខាងប្រធានតំបន់បាទ។ រាយការណ៍មក តាឡាំង។

[១១:២៤:៣១]

**ស៖** តើលោកអាចប្រាប់បានដែរទេថា តាឡាំង ហ្នឹងគឺជាអ្នកណា?

**ឆ៖** បាទ តាឡាំង គឺជាប្រធានតំបន់មណ្ឌលគិរីបាទ។

**ស៖** ខ្ញុំមិនមែនសួរ តាឡាំង នេះទេ ខ្ញុំចង់សួរពី តាឡេង ដែលយើងសរសេរថា "អិល-អ៊ី-អិន-ហ្សេ" គឺ តាឡេង គឺដែលមានមន្ទីរនៅភ្នំក្រោលហ្នឹងដែរគឺ តាឡេង មិនមែន តាឡាំង ទេ។

**ឆ៖** បាទ បញ្ហា តាឡេង ហ្នឹង គឺខ្ញុំអត់យល់ទេ ពីព្រោះមុនដំបូងគាត់មកពីរតនគិរីបាទ ខ្ញុំអត់យល់។

**ស៖** តើលោកអាចប្រាប់បានដែរទេ ថាមានអ្វីកើតឡើងចំពោះ តាឡេង នៅក្នុងឆ្នាំ១៩៧៧ ឬ ១៩៧៨ នោះ?

**ឆ៖** បាទ ខ្ញុំអត់យល់បញ្ហាហ្នឹង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាន នូវកិច្ចសម្ភាសន៍ទីមួយរបស់សាក្សីគឺ E3/367 ហើយចំណែកដែលខ្ញុំចង់ដកស្រង់យកមកអាននោះគឺ ភាសាខ្មែរ 00251440, ភាសាអង់គ្លេស គឺ 00278697, ភាសាបារាំងគឺ 00486013។ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធាន ដាក់បង្ហាញនៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក ជាមួយសហចៅក្រមស៊ើបអង្កេត លោកសាក្សីបាននិយាយថា ខ្ញុំដឹងថាខាងកងពលទ៩៦០ (ស៊ីក) ដែលជាកងពលរបស់មជ្ឈិម គឺជា-- ៩២០ ដែលជាកងពលរបស់មជ្ឈិមដែលមានសិទ្ធិចាប់ទាំងយោធា ទាំងស៊ីវិលតំបន់។ ឧទាហរណ៍ដូចជា តាឡេងជាដើមត្រូវបានចាប់។ តើលោកអាចបញ្ជាក់បានដែរឬទេ ថានេះជាចម្លើយដែលត្រឹមត្រូវ?

**ឆ៖** បាទ អាហ្នឹងជាចម្លើយហ្នឹងគឺជាត្រឹមត្រូវ បានបញ្ជាក់ឲ្យលោកសហចៅក្រមរួចហើយបាទ។

**ស៖** តើលោកចាំបានអ្វីខ្លះទាក់ទងនឹងការចាប់ខ្លួន តាឡេង?

[១១:២៧:៤៥]

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ អត់ចាំអីទេ។ មិនដឹងគេចាប់ខ្លួន រឿងអីៗ អត់ដឹងបាទ។

**ស៖** ដូច្នេះ តើហេតុអីបានជាលោកដឹងថាកងពល៩២០ ហ្នឹងមានសិទ្ធិចាប់ទាំងយោធា ទាំងស៊ីវិលតំបន់ហ្នឹង តើលោកដឹងដោយរបៀបណា?

**ឆ៖** ដឹងរបៀបថា ឲ្យតែមានការងារអី គឺរឿងចាប់អី គឺឃើញថា ខាង៩២០ ហើយ។ គេចាត់ចែងកម្លាំងមកបាទ។ ដឹងតែប៉ុណ្ណឹងបាទ។

**ស៖** សម្រាប់កំណត់ត្រា ខ្ញុំសូមនិយាយអំពីចម្លើយសារភាពនៅមន្ទីរស-២១ ដោយ វ៉ាន់ ឡុក (ស៊ីក) ហៅ ឡេង ដែលប្រធានវរៈក្នុងកងពល១០៥ គឺឯកសារដែលមានលេខ D175/3.70។ ខ្ញុំសូមសួរលោកពីបុគ្គលម្នាក់ទៀត ដែលមានឈ្មោះបង្ហាញនៅក្នុងចម្លើយរបស់លោក ហើយលោកហៅបុគ្គលនោះថា ជាប្រធានស្រុកច្បារ ហើយលោកថាឈ្មោះ ចាំ ហើយលោកថាគាត់នោះឈ្មោះ ចាំ។

**ឆ៖** បាទ គឺប្រធានស្រុកច្បារហ្នឹង គេហៅ ចាំ ហ្នឹង គឺមែនបាទ។

**ស៖** តើលោកអាចប្រាប់ដែរទេថា មានអ្វីកើតឡើងចំពោះលេខាស្រុកច្បារ ឈ្មោះ ចាំ ហ្នឹង គឺនៅក្នុងឆ្នាំ៧៨ តើមានអ្វីកើតឡើងចំពោះគាត់?

[១១:២៩:៥៧]

**ឆ៖** បាទ ខ្ញុំអត់យល់ ពីព្រោះកាលហ្នឹង គឺខ្ញុំនៅស្រុកនៅឡើយ។ អត់យល់ រឿងអីៗ អត់យល់បាទ។

**ស៖** យើងមានបញ្ជីអ្នកទោស ស-២១។ អ្នកទោសដែលត្រូវបានសួរចម្លើយនៅថ្ងៃទី០៨ ខែ

មេសា ឆ្នាំ១៩៧៨ ដែលមានឈ្មោះថា អៀម ឃុត (យាម គ្រុឌ) ហៅ ចាំ ដែលមកពីតំបន់១០៥ ហើយ គាត់បញ្ជាក់ថា គាត់ចូល ស-២១ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ IS16.101 ខ្មែរ ERN 00039333, អង់គ្លេស ERN 00234245។ លោកចាំដែរឬទេ ថាតើ ចាំ បាត់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង ក្នុងអំឡុងពេលហ្នឹងដែរឬទេ?

[១១:៣១:១៥]

**ឆ៖** បាទ ពេល ចាំ គាត់បាត់ខ្លួនហ្នឹង គឺខ្ញុំនៅស្រុកនៅឡើយទេ ខ្ញុំអត់ដឹងកិច្ចការនៅក្នុងតំបន់នេះ យ៉ាងម៉េចៗ អត់ដឹងបាទ។

**ស៖** លោកសាក្សី សៅ សារុន នៅថ្ងៃព្រហស្បតិ៍ លោកបាននិយាយថា បុគ្គលម្នាក់ដែលគេហៅថា-- ដែលគេដាក់ឈ្មោះនៅក្នុងទូរលេខដែលលោកបានបញ្ជូននៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ E3/178 លោកបាននិយាយថា បុគ្គលដែលដាក់នៅក្នុងទូរលេខនោះ គឺអ្នកដែលទទួលខុសត្រូវក្នុងការបញ្ជាឲ្យមានហេតុការណ៍ទូក ដុតកាណូតនោះ គឺថាឈ្មោះ លីន ហ្នឹង គឺនៅរស់ ហើយមិនមានកំណត់ត្រានៅក្នុងស-២១ អំពីការចាប់ខ្លួនគាត់ទេ។ តើ គង់ លីន នៅរស់ដូចដែលលោកអះអាងនោះ? តើលោកអាចជម្រាបតុលាការបានទេ ថាគាត់នៅឯណាឥឡូវនេះ? ដូចដែលខ្ញុំបានប្រាប់លោកកាលពីថ្ងៃព្រហស្បតិ៍មុននោះ គឺថាបងប្អូនប្រុសរបស់គាត់ មិនបានឃើញគាត់ទេ គាត់បានបាត់ខ្លួនតាំងពីមានហេតុការណ៍ដុតកាណូត។ លោកនិយាយថា គាត់នៅរស់ ថាតើលោកអាចជម្រាបតុលាការទេថា លីន នោះ នៅឯណាឥឡូវនេះ?

**ឆ៖** បាទ អាហ្នឹង ដូចខ្ញុំជម្រាបលោកសហចៅក្រម គឺនៅៗរស់ នៅមណ្ឌលគិរី ប៉ុន្តែឥឡូវនេះ មិនគេផ្លាស់ភូមិលំនៅ ទៅកន្លែងណាៗ ខ្ញុំអត់យល់ កាលហ្នឹង គឺនៅមណ្ឌលគិរី កាលសម័យ-- អ៎ ឆ្នាំមួយពាន់ប្រាំបួន-- តាំងពី៧៥, ៧៦ នោះបាទ។

**ស៖** តើលោកបានឃើញ គង់ លីន ហ្នឹង ចុងក្រោយបំផុតនៅក្នុងឆ្នាំណា? ខែណាដែរ?

**ឆ៖** បាទ ខ្ញុំឃើញនៅឆ្នាំមួយពាន់-- ភ្លេចទៅ។ ខ្ញុំឃើញ ខ្ញុំទៅស្រុក ខ្ញុំឃើញគាត់ច្បាស់ អត់មានអីទេ គឺបាទ ឆ្នាំខែ ឆ្នាំ ខ្ញុំចាំមិនបាន ភ្លេចហើយ។

[១១:៣៤:១០]

**ស៖** បាទ មុននឹងខ្ញុំបញ្ចប់ចំណុចនេះ លោក សៅ សារុន ខ្ញុំត្រូវតែសួរលោក។ តើលោកមានការអល់អែកក្នុងការមកបង្ហាញខ្លួនជាសាក្សី ដើម្បីបញ្ជាក់អំពីជនជាប់ចោទ? តើលោកមានការស្ទាក់

ស៊ើរទេ ក្នុងចិត្ត ក្នុងការកំណត់ថា អ្នកណាជាជនជាប់ចោទនៅទីនេះនោះ?

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ អត់មានការអល់អែកអីទេបាទ។ គឺអត់មានអីអល់អែកទេ បាទដូចខ្ញុំជម្រាបខាងលើបាទ។

**ស៖** ខ្ញុំសូមអរគុណ តើលោកដឹងដែរឬទេ នៅពេលដែលមន្ត្រីតុលាការជូនដីកាលោកឱ្យមកតុលាការនេះ ហើយមេឃុំលោកប្រាប់លោកថា មេឃុំនោះប្រាប់ថា លោកស្លាប់ហើយ តើលោកបានដឹងពីរឿងហ្នឹងទេ?

**ឆ៖** បាទ ដឹងអ៊ីចឹង បានខ្ញុំទៅព្យាបាលពេទ្យបូរាណ ខ្ញុំឈឺខ្លាំង បាត់ប៉ុន្មានដង ខ្ញុំក៏បានរាយ-ការណ៍ឱ្យកូនថាខ្ញុំហ្នឹងអាចអត់រស់ទេ ហ្នឹងបានគាត់ចេះថា ខ្ញុំហ្នឹងស្លាប់ហើយ។ បាទ អ៊ីចឹង។

**លោក ឌេល លីសាក់៖**

សូមអរគុណលោក សៅ សារុន។ ឥឡូវនេះខ្ញុំចង់ជូនឱកាសរបស់លោកឱ្យបញ្ចាក់រឿងហ្នឹង។ ឥឡូវនេះខ្ញុំនឹងផ្តល់ពេលមួយចំនួនទៀត គឺថាឱ្យភាគីផ្សេង ហើយសូមអរគុណលោកប្រធាន លោកលោកស្រីចៅក្រម ដែលបានផ្តល់ឱកាសឱ្យខ្ញុំសួរ។ អរគុណលោកសាក្សីផងដែរបាទ។

[១១:៣៦:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា ហើយជាកិច្ចបន្តអង្គជំនុំជម្រះសូមវេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានមេធាវីរដ្ឋប្បវេណីទទួលសិទ្ធិ ឡើងអាចបន្តការសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការតាំងសំណួរទៅលោកសាក្សី។ ដំបូងនាងខ្ញុំសូមគោរពលោក សៅ សារុន។

[១១:៣៧:២៣]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** នាងខ្ញុំសូមធ្វើការតាំងសំណួរដូចតទៅ៖ ដោយសំណួររបស់ផ្តើមចេញពីឆ្នាំ១៩៧០ ដល់

១៩៧៥។ ខ្ញុំសូមៗ សួរថាតើនៅពេលដែលលោកចូលបដិវត្តន៍ដំបូងហ្នឹង ខ្ញុំចង់សួរលោកថាតើលោកមានបានដឹងឬទេ ថាអ្នកណាខ្លះជាអ្នកចូលរួមបង្កើតបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អត់យល់ទេបាទ។

**ស៖** លោកមិនយល់ ឬមួយក៏លោកអត់បានដឹងថា ការចូលរួមការបង្កើតបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ?

[១១:៣៨:២២]

**ឆ៖** បាទ អត់ដឹង ដឹងពីណាបង្កើត ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំសូមបន្តសំណួរទៀត។ កាលពីសប្តាហ៍មុនលោកបានឆ្លើយជាមួយនឹងខាងសហព្រះរាជអាជ្ញាថា លោកធ្លាប់ចូលរួមប្រជុំនៅខេត្តកំពង់ធំ នៅក្នុងឆ្នាំ១៩៧១ និងឆ្នាំ១៩៧២។ នៅក្នុងកិច្ចប្រជុំនោះ ខ្ញុំចង់សួរថាតើនៅក្នុងកិច្ចប្រជុំនោះ គេមានលើកអំពីផែនការរបស់បក្សកម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យសម្រាប់ឆ្នាំ១៩៧៥ និងឆ្នាំបន្តបន្ទាប់ទៀតដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបានចាំ ហើយវាយូរ ភ្លេចអស់ បាទ។

**ស៖** ចុះនៅក្នុងកិច្ចប្រជុំហ្នឹង គេមានបានលើកអំពីផែនការនៅក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** អត់ដឹង មិនឃើញពួគេលើក។

[១១:៣៩:៥៥]

**ស៖** ខ្ញុំសូមបន្តសំណួរប្តូរទៅ-- ដោយធ្វើសំណួរចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយពីបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យចាប់ៗទទួលបានជ័យជម្នះនៅឆ្នាំ-- នៅថ្ងៃ១៧ មេសា ១៩៧៥ ហ្នឹង ខ្ញុំចង់សួរថាចាប់ពីអំឡុងពេលហ្នឹងមក ខ្ញុំចង់សួរសំណួរទៅលោកថា តើលោកមានបានដឹងពី គេមានបានបង្រៀនលោក ឬក៏ក៏បានពន្យល់ប្រាប់លោកពីគោល-- ពីគោលនយោបាយរបស់បក្ស ដូចជាការរៀបចំរចនាសម្ព័ន្ធរបស់បក្ស ដូចជាឋានានុក្រមរបស់បុគ្គលអីនីមួយៗនៅក្នុងជួរបក្សអីដល់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺអត់ដឹងតែម្តង គឺរៀបយ៉ាងម៉េចៗ អត់ដឹងបាទ។

**ស៖** កាលនោះលោកក៏បានធ្លាប់បានឆ្លើយជាមួយនឹងព្រះរាជអាជ្ញាកាលពីសប្តាហ៍មុនដែរ

ទាក់ទងនឹងការចូលរៀនវគ្គនយោបាយផ្សេងៗ។ លោកបានចូលរៀន-- តើលោកចាំបានទេ លោកមករៀនវគ្គនយោបាយហ្នឹងចំនួនប៉ុន្មានដងដែរ?

[១១:៤១:១៩]

**ឆ៖** បាទ ក្រោយរំដោះឆ្នាំ១៩៧៥ ហ្នឹង គឺខ្ញុំមកម្តង មករៀននៅភ្នំពេញបាទ។

**ស៖** តើលោកមានដឹងមូលហេតុអ្វី ថាតើបានជាគេឲ្យលោកមករៀនវគ្គនយោបាយហ្នឹងដែរឬទេ?

**ឆ៖** អត់ដឹងមូលហេតុអីទេ ឃើញតែគេតែហៅមករៀន រំដោះភ្នំពេញរួចហើយ គេហៅមករៀនបាទ។

**ស៖** ក្រោយពីលោករៀនវគ្គនយោបាយរួចហើយ តើគេមានប្រាប់លោកថា រៀនហើយគឺយកទៅអនុវត្តនៅថ្នាក់តំបន់ដែលលោករស់នៅដែរឬទេ?

**ឆ៖** បាទ អាហ្នឹងយល់ គេថាឲ្យយកទៅអនុវត្ត ដើម្បីអប់រំប្រជាជនឲ្យគេយល់ដឹង ពីព្រោះអាហ្នឹងយើងរំដោះភ្នំពេញទាំងស្រុងហើយបាទ។

**ស៖** កាលពីសប្តាហ៍មុនលោកក៏បានឆ្លើយជាមួយនឹងខាងព្រះរាជអាជ្ញាថា ឃុំរាយការណ៍មកឲ្យលោកមួយខែម្តងកលើបញ្ហាបង្កបង្កើនផល និងការរៀបចំផ្ទះសម្បែងប្រជាជន។ តើការបង្កបង្កើនផលនាពេលនោះយ៉ាងម៉េចដែរ? លោកអាចជម្រាបជូនអង្គសវនាការបានទេ?

[១១:៤៣:១៩]

**ឆ៖** បាទ អាហ្នឹងគឺពិត ភូមិឃុំគឺយក-- បានយល់ជ្រួតជ្រាបបញ្ហាបង្កបង្កើនផលហ្នឹងគឺសំខាន់គឺដោះស្រាយជីវភាពប្រជាជនមិនឲ្យអត់មិនឲ្យឃ្លានបាទ។ ឲ្យប្រជាជនមានបាយហូប មានផ្ទះរស់នៅអីសមរម្យ ពីព្រោះប្រទេសជាតិយើងរំដោះហើយ។ អាហ្នឹងបានបញ្ជាក់មែន។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ជាមួយលោកបន្ថែមបន្តិចត្រង់ចំណុចនេះ។ ខ្ញុំចង់សួរថា ដើម្បីជៀសវាងកុំឲ្យមានការភ័ន្តច្រឡំ ហើយនិងជាជំនួយដល់លោកក្នុងការចងចាំឡើងវិញ ខ្ញុំចង់សួរថា ជំនាន់ហ្នឹង មិនលោកលើកឡើងកាលពី១សប្តាហ៍មុន លោកថាសម័យហ្នឹងគឺ ឡាំង ជាអ្នកកាន់កាប់ ហើយលោកគ្រាន់តែជាលេខាស្រុកទេ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរថា សម័យដែល ឡាំង គាត់កាន់កាប់ហ្នឹង ពេលនុ៎ង ការបង្កបង្កើនផល ហើយនិងជីវភាពរបស់ប្រជាជនយ៉ាងម៉េចដែរ លោក?

[១១:៤៤:២៨]

**ផ៖** បាទ កាលហ្នឹង សម័យហ្នឹងគឺ តាឡាំង គាត់កាន់កាប់ហ្នឹងជីវភាព ការរស់នៅប្រជាជនក៏សមរម្យដែរ អត់មានបាត់ អត់បាយក្រហាយទឹកអីទេបាទ។

**ស៖** ចុះស្ថានភាពផ្ទះសម្បែងរបស់ប្រជាជនយ៉ាងម៉េចដែរ? លោកអាចរៀបរាប់ពីស្ថានភាពជាក់លាក់ជូនអង្គសវនាការបានដែរឬទេ ថាតើភិនភាគនៃផ្ទះហ្នឹងយ៉ាងម៉េចដែរ?

[១១:៤៥:00]

**ផ៖** បាទ គឺខ្ញុំសូមបញ្ជាក់ ភិនភាគផ្ទះសម្បែងប្រជាជន ធម្មតាយើងចេញពីសង្គ្រាម គឺផ្ទះកាប់ឈើមូលៗបាទ។ អាហ្នឹង កាប់ឫស្សី សាប់ធ្វើជាបន្ទាំក្រាលបាទ និងប្រក់ស្បូវ។

**ស៖** សូមអរគុណ។ ចុះទំហំនៃផ្ទះយ៉ាងម៉េចដែរ? តើពេលនុ៎ង ខាងកម្មាភិបាល ឬក៏ខាងគណៈតំបន់ ឬក៏គណៈស្រុកអី គេជាអ្នករៀបចំឲ្យប្រជាជនរស់នៅ ឬមួយក៏ប្រជាជនជាអ្នកធ្វើដោយខ្លួនឯង ឬក៏យ៉ាងម៉េចដែរ?

**ផ៖** បាទ គណៈតំបន់ បញ្ជាទៅស្រុក ស្រុកបញ្ជាទៅឃុំ គឺឲ្យរៀបចំផ្ទះសម្បែង ភូមិករណ៍របស់ប្រជាជនបាទ។

[១១:៤៦:០៤]

**ស៖** អ៊ីចឹងមានន័យថា គាត់ជាអ្នកសាងសង់ផ្ទះហ្នឹងទុកជាស្រេច ប្រជាជននៅពេលដែលគាត់ទៅ គាត់ចាំតែនៅ ឬក៏យ៉ាងម៉េច?

**ផ៖** បាទ គឺប្រជាជនជាអ្នកសាងសង់ យើងគ្រាន់ណែនាំទេ កម្លាំងធ្វើគឺប្រជាជនខ្លួនឯងធ្វើបាទ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់លោកបន្ថែមទៀត អ្វីដែលលោកលើកឡើងហ្នឹង គឺលោកសំដៅទៅលើប្រជាជនដែលនៅក្នុងតំបន់១០៥ទាំងមូល ឬក៏គ្រាន់តែប្រជាជនដែលស្ថិតនៅក្នុងស្រុកដែលលោកកាន់កាប់?

**ផ៖** បាទ ប្រជាជននៅក្នុងខេត្តទាំងមូលបាទ គេបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំសូមបន្តសំណួរ ខ្ញុំចង់សួរលោកថា តើពេលដែលលោកនៅជាលេខាស្រុកពេជ្រចិន្តាហ្នឹង ខ្ញុំចង់សួរថា តើលោកឧស្សាហ៍ឡើងចុះស្រុកកោះញែកដែរឬទេ? ដែលស្រុកកោះញែកហ្នឹង គឺ-- ខ្ញុំសូមបញ្ជាក់បន្ថែម ស្រុកកោះញែកហ្នឹង ដែលលោកធ្លាប់បានបញ្ជាក់ជូនខាងសហព្រះរាជអាជ្ញាហើយថា ជាការ-- អ្នកដែលគ្រប់គ្រងស្រុកកោះញែកហ្នឹង គឺឈ្មោះ គី។ អ៊ីចឹងខ្ញុំចង់សួរថា ពេលនុ៎ង លោក

មានឧស្សាហ៍ឡើងចុះទៅស្រុកកោះញែក ដើម្បីធ្វើការកោះប្រជុំ ចូលរួមប្រជុំអីផ្សេងៗដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ម្តងទៀតបាទ បញ្ហានេះ ខ្ញុំអត់ច្បាស់។

[១១:៤៨:២៣]

**ស៖** ខ្ញុំសូមសួរលោកថា លោកឧស្សាហ៍ឡើងចុះទៅស្រុកកោះញែកដែរឬទេ?

**ឆ៖** បាទ មួយខែម្តង បើគេហៅ មកប្រជុំគឺមួយខែម្តង។ បើក្រៅពីហ្នឹង ក៏មិនបានមកដែរ បើគេមិនហៅ ក៏មិនបានមកបាទ។

**ស៖** តើនរណាគេហៅលោកទៅស្រុកកោះញែកហ្នឹង?

**ឆ៖** បាទ តា ឡាំង។

**ស៖** តើមូលហេតុអីបានជាមានការប្រជុំនៅស្រុកកោះញែកហ្នឹងទៅវិញ?

**ឆ៖** បាទ ពីព្រោះកន្លែងតំបន់ គេនៅស្រុកកោះញែក នៅភ្នំក្រោលហ្នឹងបាទ។

**ស៖** ខ្ញុំសូមបញ្ជាក់លោកម្តងទៀត អ៊ីចឹងមានន័យថាមន្ទីរតំបន់ គឺនៅភ្នំក្រោលហ្នឹង ឬក៏យ៉ាងម៉េចលោក?

**ឆ៖** បាទ មន្ទីរតំបន់ គឺនៅភ្នំក្រោលបាទ។

[១១:៤៩:៥២]

**ស៖** មន្ទីរដែលលោកសំដៅហ្នឹង គឺមន្ទីរ១០៥ ឬក៏ជាមន្ទីរអ្វី?

**ឆ៖** បាទ ១០៥ ហ្នឹងគឺជា ហៅរួមទេ ១០៥ បាទ។

**ស៖** អ៊ីចឹងមន្ទីរដែលលោកសំដៅហ្នឹង គឺមន្ទីរផ្សេងពីមន្ទីរ១០៥ ឬក៏ជាមន្ទីរកន្លែងយ៉ាងម៉េចដែរ លោកអាចពន្យល់ជូនអង្គសវនាការបានឬទេ?

**ឆ៖** ១០៥ ហ្នឹងគឺថា គឺក្នុងខេត្តមណ្ឌលគិរីទាំងមូលហ្នឹងគេហៅថា ១០៥អ៊ីចឹងបាទ។ គេដាក់លេខវិញអ៊ីចឹង។

**ស៖** ខ្ញុំសូមឲ្យលោក-- ខ្ញុំសូមលើកជាសំណួរឡើងវិញ ក្រែងលោលោកអត់ស្វរយល់ជាសំណួររបស់ខ្ញុំ។ ខ្ញុំចង់សួរថា មន្ទីរដែលលោកនិយាយថា លោកទៅប្រជុំនៅភ្នំក្រោលហ្នឹង ហើយលោកថាភ្នំក្រោលហ្នឹងស្ថិតនៅកោះញែក អ៊ីចឹងហើយខ្ញុំគ្រាន់ចង់សួរថា មន្ទីរដែលលោកសំដៅហ្នឹង លោកសំដៅទៅលើមន្ទីរអ្វី? តើជាមន្ទីរកន្លែងសម្រាប់ពីណាគេធ្វើការដែរ?

**ឆ៖** បាទ មន្ទីរតំបន់ហ្នឹងគេហៅថា ក-១៧ បាទ។ នៅក្នុងភ្នំក្រោលនោះឯង។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់លោកបន្ថែមទៀត ដោយសារតែកាលពីសប្តាហ៍មុនលោកបានជម្រាបជូនទៅខាងសហព្រះរាជអាជ្ញាថា មន្ទីរ ក-១៧ ក៏ដូចជាមន្ទីរ ក-១១ ក៏ដូចជាមន្ទីរអប់រំកែប្រែគឺមានទីតាំងស្ថិតនៅភ្នំក្រោល តើអ៊ីចឹងមែនឬ?

[១១:៥២:០៨]

**ឆ៖** បាទ ដូចខ្ញុំជម្រាបបញ្ជាក់រួចហើយ។ សូម-- ត្រឹមត្រូវបាទ។

**ស៖** តើមន្ទីរទាំងនុំងមានចម្ងាយឆ្ងាយពីគ្នាដែរឬទេ?

**ឆ៖** បាទ ពីមន្ទីរតំបន់គេហៅថាមន្ទីរ ក-១៧ ទៅមន្ទីរ ក-១១ ហ្នឹង ប្រហែលជាមួយរយម៉ែត្រជាង។

**ស៖** តើលោកអាចជម្រាបជូនអង្គសវនាការបានដែរឬទេ ថាតើរបៀបរបបនៅក្នុងការទំនាក់ទំនងរវាងមន្ទីរនីមួយៗ ដែលលោកបានលើកឡើងពីខាងដើមកាលពីសប្តាហ៍មុន ឧទាហរណ៍ដូចជាមន្ទីរ ក-៧ ធ្វើការទំនាក់ទំនងជាមួយនឹងមន្ទីរ ក-១ យ៉ាងដូចម្តេច? ហើយមន្ទីរ ក-១១ ធ្វើការទំនាក់ទំនងជាមួយនឹងមន្ទីរអប់រំកែប្រែអីយ៉ាងដូចម្តេចដែរ? លោកអាចជម្រាបជូនថា តើនៅក្នុងរបបហ្នឹងរបៀបរបបនៅក្នុងការទំនាក់ទំនងគ្នាគេធ្វើយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ។ ដឹងគេទំនាក់ទំនងយ៉ាងម៉េច ខ្ញុំអត់យល់ អាហ្នឹងគឺខ្ញុំជម្រាបដោយស្មោះត្រង់បាទ។

[១១:៥៣:៥០]

**ស៖** ចុះពេលលោកឡើងចុះទៅភ្នំក្រោល ភ្នំក្រោលហើយនិងកោះញែកហ្នឹង ទីតាំងវាតែមួយឬក៏ម៉េចលោក?

**ឆ៖** បាទ កោះញែកអាហ្នឹងគេហៅថា ស្រុកកោះញែក បើទីតាំងនោះភ្នំក្រោលហ្នឹង គេអាហ្នឹងវាបង្កើតថ្មីទេ ក្រោយរំដោះខេត្តហ្នឹង អាហ្នឹងគេហៅថា ភ្នំក្រោលហ្នឹង គេហៅថា ក-១៧ បាទ។ អ៊ីចឹង។

**ស៖** តើនៅ--

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីគួរគិតឲ្យបានច្បាស់លាស់ កោះញែកជាស្រុកមួយ។ ប៉ុន្តែតំបន់មិនអាចនៅក្រៅស្រុកបានទេ។ ដូចជាសាលាខេត្តរាល់ថ្ងៃនេះ នៅក្នុងស្រុកមួយរបស់ខេត្ត ដែលបច្ចុប្បន្នគេដូរទៅជា

ក្រុង។ ដូច្នេះសូមឲ្យយល់អំពីបញ្ហានេះឲ្យច្បាស់ចៀសវាងសួរច្រំដែល ដែលមិនមែនជាសំណួរសក្តានុពលដែលនាំឲ្យឈានទៅរកការស្វែងរកការពិតទេ។ សំណួរដដែលៗរបៀបនេះ ដែលថាតាំងសំណួរទំនងជាមិនយល់ច្បាស់អំពីភូមិសាស្ត្រទេ មិនបានសិក្សាជាមុនអំពីភូមិសាស្ត្រនេះទេ។ ដូច្នេះ មន្ទីរតំបន់ស្ថិតនៅក្នុងទីតាំង-- មានទីតាំងស្ថិតនៅក្នុងស្រុកកោះញែក។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ឲ្យខាងសាក្សីធ្វើការបញ្ជាក់ដូច្នេះ ពីព្រោះម្សិលនោះ អឺ! កាលពីសប្តាហ៍មុនដូចជាមិនទាន់មានភាពច្បាស់លាស់ ដូច្នេះខ្ញុំសូមធ្វើការបញ្ជាក់ត្រង់ចំណុចនេះ។

[១១:៥៥:៤៨]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយច្បាស់លាស់ច្រើនហើយ។ គ្រាន់តែសំណួរភ្ជំក្រោលអំមិញនេះ គឺសាក្សីឆ្លើយច្បាស់លាស់ណាស់ ហើយគាត់ប្រកាន់ជំហរដដែល មកពីការស្តាប់ទេ មិនយល់ពីស្រុក និងតំបន់ប៉ុណ្ណោះ។ មិនដឹងថា តំបន់ហ្នឹងវាអាចនៅក្រៅស្រុកដែរឬអត់។ វាមានតំបន់វានៅក្នុងស្រុកណាមួយនៅក្នុងចំណោមស្រុកទាំងឡាយនៅក្នុង-- នៃតំបន់នុ៎ង។ គេកំណត់ថា ទីតាំងត្រង់ណាមួយដែលសមស្របគេចាត់តាំងជាមន្ទីរតំបន់មួយសម្រាប់គ្រប់គ្រងទាំងស្រុក ដែលតំបន់តាំងនៅផង ហើយទាំងស្រុកផ្សេងទៀតផង។

[១១:៥៦:៣៨]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការបន្តសំណួរ។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ពេលដែលលោកឡើងចុះធ្វើការប្រជុំហ្នឹង តើម្តុំកន្លែងមន្ទីរហ្នឹងមានប្រជាជនរស់នៅច្រើនទីនោះដែរ ឬក៏មានតែកន្លែងការងារធ្វើការរបស់ខាងសមាជិករបស់បក្ស?

**លោក សៅ សារុន៖**

**ឆ៖** បាទ មានប្រជាជនច្រើនជុំវិញ។

**ស៖** តើពេលដែលលោកចេញចូលហ្នឹងមានដែលសង្កេតមើលថា តើមានវត្តមានមនុស្សថ្មីចេញចូលប្លែកៗមុខចេញចូលទៅស្រុកនោះដែរឬទេ?

**ឆ៖** បាទ អត់មានទេ។ មានតែប្រជាជននៅក្នុងស្រុកហ្នឹងបាទ។

**ស៖** ខ្ញុំសូមឈានដល់ពេលដែលលោកចូលធ្វើការ ៗជាលេខាតំបន់១០៥ អ៊ីចឹងខ្ញុំចង់សួរថា តើ -- ខ្ញុំសូមឲ្យលោកបញ្ជាក់ជាមុនសិនមុននឹងខ្ញុំបន្តសំណួរ ឲ្យលោកបញ្ជាក់ថា តើពាក្យថា លេខាតំបន់ ប្រធានតំបន់ តើគេសំដៅទៅលើយ៉ាងម៉េចដែរ? សូមលោកជួយពន្យល់ពាក្យហ្នឹងបន្តិចពីព្រោះកាលពីសប្តាហ៍មុនខ្ញុំឮលោកលើកឡើងថា ម្តងជាលេខាតំបន់ ម្តងជាប្រធានតំបន់ តើអាហ្នឹង-- តើគេសំដៅយ៉ាងម៉េចដែរលោក?

[១១:៥៩:១០]

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ ជួនកាលហៅថា លេខាតំបន់ ជួនកាលថា ប្រធានតំបន់។ ពាក្យពីរហ្នឹងតែមួយទេ ដូចយើងហៅ សព្វថ្ងៃនេះ អភិបាលស្រុក ប្រធានស្រុក តែមួយទេ បាទ។

**ស៖** ខ្ញុំសូមសួរលោកបន្តទៀតថា ពេលដែលលោកមកកាន់តំណែងជាលេខាតំបន់១០៥ ពេលនុ៎ងលោកទៅធ្វើការនៅមន្ទីរ តើលោកមានបានទៅធ្វើការនៅកន្លែងដែល ឡាំង ធ្លាប់កាន់កាប់លើកមុនដែរឬទេ?

**ឆ៖** បាទ ដល់ខ្ញុំកាន់តំណែងជាប្រធានតំបន់ហ្នឹង គឺមកនៅកន្លែងចាស់គាត់ហ្នឹងបាទ។ អត់បានធ្វើថ្មីទេ នៅកន្លែងចាស់។

**ស៖** តើពេលនុ៎ង ឡាំង មានបន្សល់ទុកនូវឯកសារ ដែលគាត់ធ្លាប់កាន់កាប់ និងគ្រប់គ្រងតំបន់១០៥ នៅក្នុងកន្លែងនុ៎ងដែរឬទេ? ហើយលោកមានបានធ្វើការពិនិត្យ ទៅលើឯកសារទាំងនោះឬក៏អត់?

**ឆ៖** បាទ អត់ឃើញឯកសារអីទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អរគុណមេធាវី អរគុណសាក្សី។ ឥឡូវកិច្ចដំណើរការសវនាការពិភាក្សាដេញដោលសាក្សីរូបនេះ សម្រាប់ព្រឹកនេះដល់ពេលត្រូវសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ ចាប់បន្តកិច្ចដំណើរការសវនាការ។

[១២:០១:២២]

អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា កិច្ចដំណើរការសវនាការសម្រាប់ស្តាប់សក្ខីកម្មឈ្មោះ សៅ សារុន ត្រូវផ្អាកត្រឹមនេះសិន ហើយអង្គជំនុំជម្រះកំណត់ពេលវេលាធ្វើសវនាការស្តាប់សក្ខីកម្មរូបនេះ ដោយលើកបន្តទៅធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១២ ខែមិថុនា ឆ្នាំ

២០១២ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ខឹម ងន ដែលនឹងបន្តការតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញា។ បញ្ហានេះអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ រក្សាសិទ្ធិក្នុងការស្តាប់សក្ខីកម្មផ្លាស់គ្នាដោយសារមូលហេតុនៃបញ្ហាសុខភាពរបស់សាក្សី ដែលនឹងត្រូវចូលរួមផ្តល់សក្ខីកម្មមានបញ្ហាខាងសុខភាព។ ក្នុងន័យល្បឿនដើម្បីបង្កើនល្បឿន ហើយនិងទុកលទ្ធភាពឲ្យគាត់សម្រាក ដើម្បីឲ្យមានសុខភាពល្អ និងអាចផ្តល់សក្ខីកម្មបានច្បាស់លាស់។

[១២:០២:១៧]

ហើយលោក សៅ សារុន ដំណើរការសវនាការពិភាក្សាស្តាប់សក្ខីកម្មសាក្សីរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះត្រូវធ្វើបន្តនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទី១២ ខែមិថុនា ឆ្នាំ២០១២ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ដូចគ្នានេះដែរអញ្ជើញ-- អង្គជំនុំជម្រះអញ្ជើញលោកមេធាវីប្រឹក្សាសាក្សី ដើម្បីចូលរួម ដើម្បីប្រឹក្សាសាក្សីនៅសវនាការនៅថ្ងៃអង្គារ ទី១២ ខែមិថុនា ឆ្នាំ២០១២ និងថ្ងៃបន្តបន្ទាប់ទៀត។

[១២:០២:៤៩]

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារ និងសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនលោក សៅ សារុន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យនាំខ្លួន-- ឲ្យនាំគាត់ត្រឡប់មកកាន់ទីកន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

ហើយនៅរសៀលនេះ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីឈ្មោះ ខឹម ងន និងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម ក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោង-- នៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

ហើយអង្គជំនុំជម្រះ ក៏សូមជម្រាបជូនបន្ថែមដែរថា ដោយបញ្ហាសុខភាពរបស់សាក្សី ខឹម ងន ស្ថិតក្នុងស្ថានភាពមួយជួបប្រទះនូវជំងឺធ្ងន់ធ្ងរ ប្រសិនបើលទ្ធភាពក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះមិនអាចប្រព្រឹត្តិទៅបានទេនៅរសៀលនេះនោះ អង្គជំនុំជម្រះនឹងគ្រោងកំណត់កាលបរិច្ឆេទផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-488 ជំនួស។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោះ**

សូមគោរពលោកប្រធាន កូនក្តីរបស់ខ្ញុំលោក នួន ជា សូមអនុញ្ញាតទៅតាមដានសវនាការពីខាងក្រោមនេះ ហើយខ្ញុំនឹងដាក់ជូននូវលិខិតបោះបង់សិទ្ធិរបស់គាត់ជូនតុលាការបាទ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

[១២:០៥:១៨]

អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់លោក នួន ជា ដោយមានចុះហត្ថលេខា ស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទផង។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ពេញមួយរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកស្រេច នូវឧបករណ៍សោតទស្សន៍សម្រាប់រូបគាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សី ខឹម ងន ដែលនឹងត្រូវបន្តការតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រមជាទីគោរព និងសហការីទាំងអស់ជាទីគោរព។ សូមជម្រាបសួរលោកសាក្សីផងដែរ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

កាលពីលើកមុនលោកក៏បាននិយាយថាលោកមានការភ័យខ្លាចមុននឹងផ្តល់សក្ខីកម្ម ហើយខ្ញុំសូមសួរលោកថាតើថ្ងៃនេះ សុខសប្បាយលេងភ័យអីហើយ? ហើយកាលលើកមុននោះ លោកបានជួយយើងច្រើនណាស់ ហើយខ្ញុំសង្ឃឹមថាថ្ងៃនេះលោកក៏លោកបន្តជួយយើងផងដែរ ហើយនិងព្យាយាមផ្តល់ចម្លើយច្បាស់លាស់ទៅនឹងសំណួរ ដែលខ្ញុំនឹងសួរខាងមុខនេះ។

**ស៖** កាលពីលើកមុន លោកថា លោកបានធ្វើការនៅផ្ទះលេខ៧៦ នៅស្ថានទូតចិន។ តើលោកធ្លាប់បម្រើអ្នកដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងពេលប្រជុំ ឬក៏ក្នុងពេលស្រស់ស្រូបអាហារពេលល្ងាចដែរឬទេ?

**លោក ខឹម ងន៖**

**ឆ៖** កាលខ្ញុំនៅផ្ទះលេខ៧ ខ្ញុំបានបម្រើភ្ញៀវចិន ហើយនិងអ្នកដឹកនាំខ្មែរឈ្មោះគេ បងហុង។ ខ្ញុំនៅក្រោមរបបគេដែរ អាហ្នឹងធ្វើម៉េច ពីព្រោះអ្នកដឹកនាំ បងហុង ក្រសួងការបរទេស។ ចប់ហើយ។

[១៣:៣៣:៥២]

**ស៖** លោកដឹងថា លោកបម្រើថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនៅផ្ទះលេខ៧ ហ្នឹង ថ្នាក់ដឹកនាំណាខ្លះ? សូមជម្រាប។

**ឆ៖** កាលពីសម័យហ្នឹង អ្នកដឹកនាំនៅក្រសួងការបរទេស មើល៍! មានឈ្មោះនៅប្រធានមន្ទីរមានតែ បងហុង និង អៀង ឃើញគេមកប្រជុំអ្នកធំៗដែរ ប៉ុន្តែខ្ញុំជាយុវជន ខ្ញុំក៏មិនដែលតាមដានមើលគេដែរ លោកពូ។ សូមអស់ហើយ។

**ស៖** នៅក្នុងរបបកម្ពុជាធិបតេយ្យ លោកមិនដែលធ្លាប់ជួបលោក អៀង សារី ទេឬ?

[១៣:៣៥:០២]

**ឆ៖** អង្កាល់ពីសម័យអង្កាល់ហ្នឹង កាលខ្ញុំនៅក្រសួងការបរទេស ឮថា អៀង សារី មកប្រជុំនៅមហោស្រពដែរ ប៉ុន្តែខ្ញុំអត់មានបានទៅទេថ្ងៃហ្នឹង។ ទៅតែ អាភឿង និងប្រធាន បងហុង ហ្នឹង ហើយនិងគេផ្នែកខាងធ្វើការក្រុមស្នូលរបស់គេប៉ុន្មាននាក់ទេ ខ្ញុំភ្លេចឈ្មោះគេ វាយូរពេក លោកពូ។ ដូច អាភឿង អំ! ដូច អាធឿន ដែរ មិនដឹងដែលអង្កាល់ហ្នឹង ហើយបែកទៅ។ សូមអស់លោកពូ។

**ស៖** បាទ សូមអរគុណ។ លោកបានឆ្លើយកាលពីសុក្រមុននេះ គឺថាលោកត្រូវបានគេទិតៀននៅក្នុងពេលប្រជុំនៅក្រសួងការបរទេស ហើយថ្ងៃបន្ទាប់មកលោកត្រូវសរសេរប្រវត្តិរូប។ តើលោកចាំទេ ថាការរិះគន់មកលើលោកនោះមានអ្វីខ្លះ?

[១៣:៣៦:០២]

**ឆ៖** ការរិះគន់មកលើខ្ញុំឲ្យមានកំហុសរបស់ខ្ញុំមានតែ អាភឿង គេអនុមន្ទីរហ្នឹង ហើយគេរាយការណ៍ខ្ញុំ ថាខ្ញុំនេះវាខាងផ្នែកនយោបាយបម្រើភ្ញៀវខុសខាងផ្នែកសីលធម៌។ ហើយគេដកខ្ញុំទៅនៅក្រុងតាខ្មៅរយៈពេលបានចំនួនបីខែ លោកពូ។ សូមចប់ហើយ។

**ស៖** តើបញ្ហាសីលធម៌នោះជាអ្វី? ហើយផលវិបាកភ្លាមៗនោះអ្វីដែរ?

**ឆ៖** ខាងផ្នែកសីលធម៌ ដូចរស់នៅជាមួយបម្រើភ្ញៀវ ជាមួយ-- កាលហ្នឹង គេហៅនារីៗនោះលោកពូ ប៉ុន្តែដល់ហើយយើងខុសការលែងសើចជាមួយគ្នាបន្តិចបន្តួច គេណែនាំយើង។ ជួនណាគេរាយការណ៍សម្ងាត់ទៅ ក៏យើងអត់ដឹង។ ដូចឧទាហរណ៍មួយឈ្មោះ អាជើង គេរាយការណ៍ទៅ ដកគ្នា មិនដឹងដកទៅត្រង់ណា។ ខ្ញុំក៏បានដឹង វាដកទៅក្រុមភ្ញៀវរបស់គេហ្នឹង។ មិនដឹងដកទៅទីណា។ ចង់ហើយលោកពូ។

[១៣:៣៧:៣៥]

**ស៖** តើគេហាមមិនឲ្យយើងនិយាយជាមួយនារីទេឬ នៅរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** អាហ្នឹង តាមខ្ញុំយល់ តាមមើលវា ឧទាហរណ៍ ដូចបិទសិទ្ធិដែរតាមមើល។ តែយើងនិយាយទាក់ទងគ្នាខ្លាំងទៅ ថាយើង ចោទយើងខុសខាងសីលធម៌ ប៉ុន្តែវាចោទហ្នឹង មិនដឹងគំនិតវាម៉េចក៏ខ្ញុំអត់ដឹងលោកពូ។ ហើយរស់នៅជាមួយភ្ញៀវ ដូច បងហុង គេណែនាំរាល់ថ្ងៃអ៊ីចឹង គេថាប្រយ័ត្នខុសក្រមសីលធម៌។ អស់ហើយលោកពូ។

**ស៖** តើបន្ទាប់មកទៀតហ្នឹង លោកបានរៀបការជាមួយនារីដែលលោកបាននិយាយជាមួយដែរឬទេ ពេលក្រោយមកនោះ?

[១៣:៣៨:៣៥]

**ឆ៖** ពេលក្រោយ អត់មានលោកពូ អត់មានបានគ្នាផង មិនបានផងហ្នឹងណា។ ឯជាការលែងសើចហ្នឹង គេចាត់តាំងទុកជាខ្មាំងទៅ គេដកខ្ញុំមក ដូចខ្ញុំនិយាយពីមុនថា ដកមកនៅក្រុងតាខ្មៅ ដាំស្ពៃទៅ។ អស់ហើយលោកពូ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីការសរសេរប្រវត្តិរូបបន្តិច។ តើលោកស្គាល់អ្នកផ្សេងទៀត នៅក្រសួងការបរទេស ដែលគេសុំឲ្យសរសេរប្រវត្តិរូប ដូចលោកដែរ បន្ទាប់ពី-- ពេលដែលពួកគាត់ទាំងអស់គ្នា ត្រូវបានគេរិះគន់?

**ឆ៖** កាលហ្នឹង គេឲ្យខ្ញុំសរសេរប្រវត្តិរូប ឲ្យសរសេរយកទៅថ្នាក់លើ ដឹងគេដាក់ គេយកដល់ត្រឹមប៉ុន្មានពូ បើខ្ញុំអត់ដឹង គេឲ្យយកទៅ គេថា ថ្ងៃហ្នឹងអ្នកឯងសរសេរឲ្យរួចនៅមុន។ ហើយខ្ញុំក៏បានសរសេរយកឲ្យគេ ដូចខ្ញុំនិយាយពីថ្ងៃមុននោះ ថាម្តងខុស ពីរដងខុស ដល់បីដងស្ងាត់ គេឲ្យយកទៅរូតៗ មិនដឹងគេយករូតម៉េច។ ហើយខ្ញុំម្យ៉ាង ស្រម៉ៃឃើញ នឹកឃើញថាបងប្អូននៅនោះ នៅស្រុកកំណើតនោះ ក្រែងលោគេយកវ៉ៃចោលទៅ បានថា-- ខ្ញុំមិនដឹងដែរ អាហ្នឹង។ បានជានឹកឃើញចាប់អារម្មណ៍ក្នុងចិត្តព្រោះខ្ញុំគេមិនឲ្យដើរដែរ ឲ្យនៅតែជាមួយភ្ញៀវហ្នឹង។ សូមអស់ហើយពូ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណលោកប្រធាន មុននឹងចូលទៅប្រធានបទមួយទៀត ខ្ញុំសូមការអនុញ្ញាតបង្ហាញរូបថតមួយទៅលោកសាក្សី។ នេះគឺជារូបថតពេលទទួលគណៈប្រតិភូបរទេសនៅពោធិ៍ចិនតុង លេខរូបថតនេះ គឺថា E190.1.194។ បាទ ខ្ញុំសូមអានម្តងទៀត គឺថា E190.1.194 ហើយនិងលេខ

ERN គឺ P00513612។ បាទ ខ្ញុំសូមអនុញ្ញាតបង្ហាញ-- បញ្ចាំងឯកសារនេះនៅលើកញ្ចក់អេក្រង់ផងដែរ លោកប្រធាន។

[១៣:៤១:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ខ្ញុំសូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីខ្ញុំសូមឱ្យលោកមើល ពិនិត្យមើលរូបថតនេះ ហើយជាពិសេសរូបមនុស្សពីរនាក់ៗ ដែលនៅខាងស្ដាំនៃរូបថតនេះ ដែលចាប់ពីរូបមនុស្សដែលនៅខាងស្ដាំគេបំផុត ហើយដែលរូបគាត់ដាច់ពាក់កណ្ដាល យើងឃើញមុខគាត់ ហើយនិងខ្លួនគាត់ពាក់កណ្ដាល។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើលោកស្គាល់បុគ្គលរូបនេះដែរឬក៏អត់? បាទ រូបថតនេះនឹងចេញមកលើអេក្រង់ឥឡូវហើយ។ បាទ លោកសាក្សី តើលោកស្គាល់បុគ្គលដែលនៅខាងស្ដាំដែគេទាំងអស់ ហើយខ្ញុំបានដាក់សញ្ញាព្រួញនៅលើរូបគាត់ហើយ?

[១៣:៤២:២៧]

**លោក ខឹម ងន៖**

**ឆ៖** អត់ស្គាល់ទេពូ អត់ស្គាល់សោះខ្ញុំ មិនដែលឃើញផងហ្នឹង។ អត់ស្គាល់ទេពូ អត់ស្គាល់។

**ស៖** បាទសូមអរគុណៗ។ ហើយបុគ្គលទីពីរ ដែលយើងចាប់ផ្ដើមពីរូខាងស្ដាំដដែល គឺថារូបមនុស្សដែលនៅខាងប្ដង់ខាងក្រោយ មិនដឹងថាយើងអាចឃើញរូបគាត់ដែរឬក៏អត់ទេ នៅលើរូបហ្នឹង ខ្ញុំសង្ឃឹមថារូបដែលលោកមើលហ្នឹងច្បាស់ហើយ។ តើលោកស្គាល់រូបគាត់ទេ មនុស្សទីពីរនៅខាងក្រោយនេះ?

**ឆ៖** គ្មានទេពូ គ្មាន-- ដូចមិនឃើញផង។

**ស៖** បាទ សាក្សីតើលោក-- សូមមើលៗ-- លោកអាចមើលក្រដាសដែលយើងព្រីនឱ្យនោះ ខ្ញុំគិតថាប្រហែលជាលោកមើលច្បាស់ជាងជាក្រដាសនោះ។ លោកឃើញដូចគ្នាទេ?

**ឆ៖** ដូចមិនឃើញខ្ញុំផងហ្នឹង។

**ស៖** បាទ សូមអរគុណលោកសាក្សី។ ខ្ញុំមិនមែនសួរថាលោកនៅរូបថតហ្នឹងអត់ទេ ប៉ុន្តែខ្ញុំចង់សួរលោកថាតើលោកស្គាល់រូបដែលថាគេបាញ់ព្រួញទៅលើហ្នឹងទេ? លោកស្គាល់បុគ្គលនុ៎ងទេ?

**ឆ៖** អត់ទេពូ អត់ៗ ស្គាល់ទេខ្ញុំ មិនស្គាល់ថាមិនស្គាល់ ខ្ញុំច្បាស់ខ្លួនដែរថាមិនស្គាល់។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងរយៈពេលដែលលោកធ្វើការនៅក្រសួងការបរទេសនោះ តើធ្លាប់មានការបោសសម្អាតដែរឬទេ?

**ឆ៖** អង្កាល់នៅក្រសួងការបរទេស គេមានក្រុមនៅផ្ទះ ប-១ នោះ គេមាននារីៗ អ្នកខាងបោសសម្អាតផ្ទះ បោសសម្អាតអីហ្នឹង។ តែចំពោះខ្លួនខ្ញុំ នៅខាងក្រសួង-- នៅបម្រើភ្ញៀវ។ អស់ ហើយលោកពូ អស់ហើយ។

[១៣:៤៥:១៩]

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំទទួលចម្លើយរបស់សាក្សីទាំងស្រុងបានទេ ទាំងអស់ទេ។

**សួរដោយលោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីសូមឆ្លើយម្តងទៀត។ តើលោកធ្លាប់ដឹងថាមានការបោសសម្អាត ឬការចាប់ខ្លួននៅក្នុងក្រសួងការបរទេសដែរឬទេ?

**លោក ខឹម ងន៖**

**ឆ៖** អេ អាការចាប់ខ្លួនៗខ្ញុំក៏វាមិនបានឃើញទេ ប៉ុនគ្រាន់តែថាដក ដូចខ្ញុំនិយាយលើកមុនហ្នឹងណ៎ា។ គេដកកម្លាំង ដូរចុះដូរឡើង ដកបាត់ៗ មិនដឹងដកទៅណា។ ដូចខ្ញុំនិយាយលើកមុនអ៊ីចឹង។ អាហ្នឹងតាមខ្ញុំដឹងណ៎ា។ ចប់ហើយលោកពូ ខ្ញុំមិនមានអី។

[១៣:៤៦:០៦]

**ស៖** តើមានមនុស្សដែលលោកស្គាល់ ដែលធ្វើការជាមួយលោក ហើយត្រូវបានគេចាប់ខ្លួននៅក្រសួងការបរទេសដែរឬទេ នៅពេលដែលលោកធ្វើការនៅទីនោះៗ? គឺសហការីជិតស្និទ្ធជាមួយលោកនោះ តើធ្លាប់មានអ្នកដែលត្រូវគេបានគេចាប់ខ្លួនទេ?

**ឆ៖** ពេលហ្នឹងចាប់ឈ្មោះ ជ្រឹង ចាប់ថាយកមកក្រោយទៅ ខ្លះថាៗចាប់យកមកដូរកន្លែង ដូរមនុស្សនៅកន្លែងណ៎ា? អាហ្នឹងអាពួកម៉ាកខ្ញុំហ្នឹងគេចាប់ទៅៗថា គេថា អញលាហើយពួកម៉ាកអ៎ា អញដូរកន្លែងហ្នឹងហើយ។ ប៉ុណ្ណឹងពូ មិនដឹងដូរទៅប៉ុន្មាន មិនដឹងដែរអាហ្នឹង។ ព្រោះយើងគ្មានសិទ្ធិអីដូច

គេ។ អស់ហើយលោកពូ។

**ស៖** តើគេចោទប្រកាន់ ជ្រឹង អ្វីខ្លះដែរ?

**ឆ៖** គេចោទប្រកាន់ ជ្រឹង ថាមិនដឹងកាលហ្នឹងថា ខ្ញុំក៏ភ្លេចហើយ តាមមើលបែបជូនភ្ញៀវទៅ ដូចជូនភ្ញៀវទៅកំពត វាទៅកំពង់សោមមិនដឹង អីដឹង។ ដល់មកវិញ គេអាន បានណែនាំវាដែរ ហើយថា ដកចេញទៅពូ។ ឲ្យ-- ថ្ងៃហ្នឹងគេប្រជុំ មកវិញគេប្រជុំជីវភាពនៅក្នុងមន្ទីរហ្នឹងណ៎ា ដល់ប្រជុំហើយ ស្អែកឡើងគេដកអាន៎ុងទៅដែរ គេដក ដូរគេថាដូរកម្លាំង អាជ្រឹង ចេញ។ ប៉ុនមិនដឹងខុស-- ប្រហែលវា នៅជាមួយភ្ញៀវ កាលហ្នឹងវាមានទូត ពីណានៅពេញតែដីហ្នឹងកាលហ្នឹង យកចេញទៅ គេថាដកមិនដឹង ដកទៅណា ខ្ញុំក៏វានឹកឃើញម្យ៉ាងខ្ញុំនៅក្មេងជាងគេ ក៏វាមិនបាច់តាមដានគេដឹងអស់ទេ។ អស់ហើយពូ។

[១៣:៤៧:៥៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯលៈ**

បាទ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីរម្លឹកការចងចាំរបស់សាក្សី។ លោកប្រធាន ខ្ញុំសូម អនុញ្ញាតអានសម្រង់មួយនៃឯកសារ D280/18 ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីចំពោះ មុខចៅក្រមស៊ើបអង្កេត គឺទំព័រទីប្រាំពីរ ជាទំព័របារាំង ហើយអង់គ្លេសក៏ដូចគ្នាដែរ ទំព័រទីប្រាំពីរដែរ ហើយនៅចន្លោះទំព័រទីប្រាំពីរ និងទីប្រាំបីជាភាសាខ្មែរ។

តើខ្ញុំអាចអានសម្រង់នេះបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ប៉ុន្តែលោកស្នើសុំដាក់បង្ហាញឯកសារន៎ុងនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រដែរអត់?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯលៈ**

បាទ ខ្ញុំគិតថាដើម្បីឲ្យសាធារណជន ហើយនិងភាគីនោះ យើងជាការសំខាន់ដែរ គឺថាអាច បញ្ចាំង។ សូមការអនុញ្ញាតបញ្ចាំងលើអេក្រង់ដែរ។

[១៣:៤៩:១៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយលើកក្រោយ ដើម្បីសន្សំពេលវេលា លោកសុំតែម្តងទៅ ព្រោះ លោកបានធ្វើតាំងពីរព្រឹកមក វាដូចជាទំនងល្អហើយ។ បើលោកត្រូវការសុំ លោកសុំផ្ទាល់ទាំងអស់

សរុបតែម្តងទៅ អង្គជំនុំជម្រះសម្រេចតែម្តង វាទៅលឿនអ៊ីចឹងទៅ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោក១បានផ្តល់ចម្លើយវែងនៅក្នុងឯកសារនេះទាក់ទងទៅនឹងលោក ជ្រឹង ដែលជាសហការីរបស់លោក។ បាទ ខ្ញុំសូមលើកសម្រង់របស់លោក៖ “នៅក្រសួងការបរទេស អ្នកដែលត្រូវបានគេចោទថាជាខ្មាំង ជា សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ត្រូវបានបោសសម្អាត។ អ្នកដែលត្រូវបានគេចោទប្រកាន់ថាជា ខ្មាំង គឺ ជ្រឹង និង ធឿន “T-H-O-E-U-N” ជាភាសាបារាំង។ ជ្រឹង ត្រូវបានគេចាប់យកទៅមន្ទីរស-២១ ហើយ ធឿន រត់គេចខ្លួនរួច។ មូលហេតុនៃការចាប់ខ្លួនរបស់ ជ្រឹង គឺ ជ្រឹង បានបើកឡានក្រឡាប់ ហើយធ្វើឲ្យមនុស្សស្លាប់ពីរនាក់និងរបួសម្នាក់។ អ្នកស្លាប់នោះ គឺជនជាតិចិនម្នាក់ និងខ្មែរម្នាក់ឈ្មោះ ធួន។ ហើយ ធឿន បានត្រូវរបួសបាក់ជើង។ គេចោទ ជ្រឹង ថាមិនគោរពច្បាប់ក្បត់ និងធ្វើការប៉ះពាល់ដល់គោលនយោបាយ។ នៅពេលដែលចាប់ខ្លួននោះ គេហៅតាមធម្មតា ដោយប្រាប់គាត់ថា ទៅប្រជុំ។ នៅពេលហៅ ជ្រឹង ទៅនោះ ខ្ញុំនៅទីនោះដែរ”។ បាទ សូមបញ្ចប់ការដកស្រង់។

លោកសាក្សី តើលោករក្សាចម្លើយ ដែលលោកបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតដែរឬទេ អ្វីដែលខ្ញុំទើបតែបានអានឲ្យលោកស្តាប់នេះ?

**ឆ៖** បាទ ត្រូវតាមហ្នឹងហើយ លោកពូ។ ស្របប៉ុណ្ណឹង ស្តាប់បានហើយ។

[១៣:៥១:៤៤]

**ស៖** នៅពេលដែលមានមនុស្ស ដែលគេកំណត់ថាជាខ្មាំង ជាជនក្បត់នៅក្នុងក្រសួងការបរទេស ដូចជា ជ្រឹង ជាដើមនេះ។ តើមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះ? តើលោកដឹងដែរឬទេ?

**ឆ៖** នៅក្នុងគ្នាខ្ញុំប្រាំមួយនាក់ហ្នឹង វាព្រួយបារម្ភ ចាប់អារម្មណ៍ដែរ លោកពូ! ចាប់អារម្មណ៍ត្រង់ថាអាកន្លែងការងារនយោបាយ គេដកអាមួយចេញហើយ ណេ៎! អាមួយវារាយការណ៍ស្ងាត់ទៀតក៏មិនដឹង។ កាលរស់នៅជាមួយភ្ញៀវ ក៏វានិយាយតែប៉ុណ្ណឹង ហើយខ្ញុំនៅក្មេងជាងគេ ចេះតែ អឺ!១ តាមគេទៅ។ អើ!វាមិនដែលបានទៅឆ្ងាយនឹងគេខ្ញុំ ទៅឆ្ងាយបានបីដងដែរ អាហ្នឹង។ ចប់ហើយលោកពូ។

**ស៖** តើ ជ្រឹង ហើយនិងអ្នកផ្សេងទៀត ដែលត្រូវបានគេនាំខ្លួននោះ តើលោកធ្លាប់បានឃើញគាត់វិញទេ ពេលក្រោយមកហ្នឹង?

**ឆ៖** បាត់សូន្យតែម្តង អត់ឃើញ។ អត់មានឃើញមកវិញទេលោកពូ បាត់ស្ងាត់តែម្តង។ ចប់ហើយលោកពូ។

**ស៖** តើលោកដឹងថា អ្នកណា អ្នកឲ្យ អ្នកចេញបញ្ជាឲ្យចាប់ខ្លួន ជ្រឹង និង ធឿន ឬទេ?

**ឆ៖** អ្ហែ បញ្ជា បើ បងហុង គេប្រធានមន្ទីរ មានតែ បងហុង ហើយដែលប្រធានពីលើមក ក៏ខ្ញុំមិនបានដឹង បើថានៅជាមួយខ្ញុំ ខ្ញុំអាចដឹង។ មានតែ បងហុង អ្នកបញ្ជានយោបាយហ្នឹង ការនិយាយ ដកចេញ ដកចូលលើគេអាហ្នឹង ព្រោះខ្ញុំ វាក៏គ្មានសិទ្ធិទៅ នេះមានសិទ្ធិតែដឹងពូ។ តែប៉ុណ្ណឹងលោកពូ មានតែ បងហុង ហ្នឹងគេអ្នកផ្លាស់កន្លែងទីលំនៅយុទ្ធជនម្នាក់ៗហ្នឹង។ ចប់ហើយលោកពូ។

[១៣:៥៣:៥៨]

**ស៖** បាទ សូមអរគុណ។ បើសិនជាលោកនៅទីនោះដែរ ហើយតើអ្នកណាជាទម្លាប់នោះ អ្នកណាជាអ្នកនាំ ជ្រឹង ចេញទៅ?

**ឆ៖** ថ្ងៃនាំ ជ្រឹង ចេញទៅ វាទៅជាមួយប្រធានហ្នឹងម្តង ជាមួយ បងហុង ហ្នឹងម្តង ហើយ អ្ហែមើលទៅ ដូចពីរនាក់ ដូចទៅៗជាមួយប្រធានពីរនាក់ ប៉ុន្តែមិនដឹងអ្នកណាមួយលោកពូ ខ្ញុំភ្លេចហើយខ្ញុំចងចាំ វាមិនបានចាំអស់ដែរ យូរហើយ។ ទៅពីរនាក់ថ្ងៃហ្នឹង ទៅជាមួយប្រធានគេហ្នឹង។ ហើយខ្ញុំក៏មិនបានដឹងដែរ។ ដឹង អាថ្ងៃក្រោយមកបាន តែសួរៗ ថាទៅពីរនាក់ បបួល អាជ្រឹង ទៅហ្នឹង។ អស់ហើយលោកពូ។

**ស៖** លោកបាននិយាយថា មានមនុស្សជាច្រើនត្រូវគេនាំខ្លួនចេញទៅ ហើយលោកមានការភ័យខ្លាច។ តើលោកអាចប្រាប់យើងទេថា មានចំនួនប៉ុន្មាននាក់ដែរនៅក្នុងចំណោមសហការីរបស់លោកនៅក្រសួងការបរទេសហ្នឹង ដែលត្រូវបានគេនាំខ្លួនចេញទៅ នៅពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** អង្កាល់ខ្ញុំនៅក្រសួងការបរទេស នៅមន្ទីរផ្ទះលេខ៧ មានប្រាំបីនាក់ទាំងតែកុងឡាន នារីបួននាក់ អ៎! នារីតែបីនាក់ទេ នារី។ នៅកន្លែងខ្ញុំតែក្រសួងការបរទេសវាចែកច្រើនប្រភេទ អាខ្លះនៅផ្ទះលេខមួយអ៊ីចឹងទៅ ខ្លះនៅប-១ អ៊ីចឹងទៅ មិនដឹងនៅ-- ដល់ពេលដែលមានផែនការបោះសម្អាត ដូចៗចាប់អ្នកណាៗមួយក៏ខ្ញុំមិនបានដឹងដែរពូ ព្រោះខ្ញុំដឹងតែកន្លែងខ្ញុំនៅហ្នឹង ខ្ញុំអាចដឹងខ្លះៗអាហ្នឹង។ ដូច បងហុង ខ្ញុំអាចដឹង ប៉ុន្តែបងហុង ប្រធានក្តាប់រួមនៅហ្នឹង នៅក្រសួងការបរទេស តែក្របខ័ណ្ឌលេខាគេឡើងលើទៀតក៏ខ្ញុំមិនបានដឹង ឮសួរថា អង្កាល់ហ្នឹងឮសួរតែ អើ ពីណាដូច-- ខ្ញុំវាមិនសូវស្គាល់មិនសូវនេះផង ម្យ៉ាងមិនហ៊ាននិយាយខ្លាចគេតាមដានទៅគេធ្វើបាបខ្ញុំអាដែល។ សូមអស់ហើយពូ។

[១៣:៥៦:៤១]

**ស៖** បាទ សូមអរគុណលោកសាក្សី។ បាទ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីរយៈពេលដែលលោកគេបញ្ជូនទៅតាខ្មៅ លោកបាននិយាយអំពីបញ្ហានេះច្រើនដងហើយ ហើយគឺថាលោកបញ្ជូន- - ត្រូវបានគេបញ្ជូនទៅទីនោះបន្ទាប់ពីពេលដែលលោកសរសេរប្រវត្តិរូបរបស់លោកហើយ។ តើលោកអាចជួយរៀបកំណត់ពេលវេលានៃព្រឹត្តិការណ៍នេះប្រាប់យើងបានដែរឬទេ ថានៅក្នុងរយៈកាលពេលណា? ពេលដែលគេបញ្ជូនលោកទៅតាខ្មៅហ្នឹង គឺនៅឆ្នាំណាឲ្យពិតប្រាកដទៅនោះ?

**ឆ៖** ពិតប្រាកដបែប៧៦ លោកពូ។ វាពាក់កណ្ដាល៧៦ យ៉ាង គេដកខ្ញុំទៅនៅតាខ្មៅ៧៦ហើយខ្ញុំវាមិនសូវដឹងអារឿងនេះ អង្គាល់ មិនបានចាប់អារម្មណ៍អារឿងឆ្នាំប៉ុន្មានៗ ប៉ុន្តែខ្ញុំដឹងក្នុង៧៦។ ដកខ្ញុំទៅនៅតាខ្មៅបីខែ ឲ្យទៅរែកដី រែកអាចម៍ ដាំស្ពៃហ្នឹង លត់ដំខ្ញុំនៅហ្នឹង។ នឹកឃើញម្យ៉ាងគេយក-- ដល់ហើយអីហើយបានរយៈពេលបីខែ គេយកខ្ញុំទៅក្រសួងការបរទេសវិញ។ គេអប់រំខ្ញុំអ៊ីចឹង បងហុង គេអប់រំខ្ញុំអ៊ីចឹងទៅ។ ខ្ញុំក៏មិនសូវហ៊ាននិយាយនឹកឃើញថា ខ្លាចតែគេយកទៅបាត់ដែរហ្នឹង ព្រោះធ្វើប្រវត្តិរូប ចាប់អារម្មណ៍ក្នុងចិត្តឯងថា ធ្វើប្រវត្តិរូបក្នុងមួយថ្ងៃបីដង ព្រួយបារម្ភដែរហ្នឹង។ អង្គាល់ហ្នឹងខ្ញុំ *(ឮមិនច្បាស់)* គេឲ្យខ្ញុំធ្វើប្រធានក្រុមដែរ ប៉ុន្តែដូចខ្ញុំនិយាយលើកមុនអ៊ីចឹង។ *(ឮមិនច្បាស់)* គេបញ្ជាដែរ គេបញ្ជាឲ្យនៅជាមួយភៀវ មើលការខុសត្រូវ មិនស្រួលយកឯងអាប្រធានក្រុមញ៉ុំងចេញដូច អាជ្រឹងទៀតឥឡូវ។ ចេះខ្ញុំមិនហ៊ាននិយាយ ពូប៉ុណ្ណឹង។ សូមចប់ហើយ។

[១៣:៥៨:៤៧]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកចេញទៅតាខ្មៅនោះ តើលោកដឹងថាអ្នកណាជាអ្នកចេញបញ្ជាបញ្ជូនលោកទៅតាខ្មៅនុ៎ងដែរឬទេ?

**ឆ៖** អង្គាល់ដកខ្ញុំទៅមានតែ បងហុង គេអ្នកបញ្ជាឲ្យដកទៅ ដល់ហើយឲ្យ អាភឿង អ្នកឲ្យនាំខ្ញុំទៅ។ ដល់កន្លែងមន្ទីរដាំស្ពៃ កន្លែងតាខ្មៅហ្នឹងមាន តាហួន គាត់អ្នកប្រធានមន្ទីរនុ៎ងទៀតលោកពូណ៎ា។ សូមចប់ហើយ។

**ស៖** បាទ សូមអរគុណ។ តើកន្លែងបង្កបង្កើនផលនៅតាខ្មៅនេះ នៅក្នុងចំណុះក្រសួងការបរទេសដែរឬទេ?

**ឆ៖** អ្អេ! ពីអង្គាល់នុ៎ងដូចនៅក្រោមក្រសួងការបរទេសដែរ តាមមើល នៅៗលោកពូនៅ ព្រោះតាមខ្សែរយៈបណ្ដាញក្រុមហ្នឹងនៅក្រសួងការបរទេសដែរ គេចាត់តាំងទៅហ្នឹងកន្លែងក្រសួងការដែរ

ហ្នឹង។ អស់ហើយលោកពូ។

[១៤:០០:០៤]

**ស៖** តើលោកស្គាល់ឈ្មោះកូដនៅកន្លែងបង្កបង្កើនផលនៅតាខ្មៅ ដែលលោកបានធ្វើការដែរឬទេ? តើមានឈ្មោះកូដទេកន្លែងហ្នឹង?

**ឆ៖** កូដណាអ៊ីចេះ។ អ្វេ ខ្ញុំដូចជាមិនស្គាល់ឈ្មោះ កូដ ទេលោកពូ ខ្ញុំមិនស្គាល់ទេ កូដ។

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែសូមកែប្រែ។ ឈ្មោះជាលេខបាទ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើលោកតា ដែលចេញបញ្ជាឲ្យលោកធ្វើការនៅតាខ្មៅនោះឈ្មោះអីដែរ?

**លោក ខឹម ងួន៖**

**ឆ៖** តាហ្នួន ឈ្មោះតាហ្នួន ដឹងសួរខ្ញុំដឹង តាហ្នួនៗ។ អ៊ីចឹងពូចប់ហើយ។

**ស៖** បាទ សូមអរគុណ។ តើនៅតាខ្មៅមានមនុស្សដូចជារូបលោកហ្នឹងធ្វើការនៅស្រែដែរឬទេ?

[១៤:០១:២២]

**ឆ៖** អង្កាល់ហ្នឹង វា-- កន្លែងហ្នឹង ដូចនៅជនបទដែរលោកពូ មានដាំកូនស្ពៃហ្នឹង ដូចមានវាលស្រែមានអីដែរ មានដើមត្នោតដែរនៅក្តុំហ្នឹង។ ចុះអង្កាល់ហ្នឹងខ្ញុំនៅក្មេង ដូចវង្វេង ចង់វង្វេង ដូចវង្វេងកាលហ្នឹង យើងនៅក្មេង យើងមិនសូវដឹងប៉ុន្មានដែរ។ ប៉ុន្តែដីហ្នឹងដូចវាលស្រែ ដាំស្ពៃនៅក្នុងរង្វង់ខ្ពង់គ្នាប្រហែល២០នាក់អីតាមមើល កាលហ្នឹង។ ហើយខ្ញុំបានមិនទាន់មានបានស្គាល់គេប៉ុន្មានដែរហ្នឹង។ អស់ហើយលោកពូ។

**ស៖** តើក្នុងចំណោមអ្នក២០ហ្នឹង មានអ្នកដែលលោកធ្លាប់ជួបនៅក្រសួងការបរទេសទេ ឬក៏សុទ្ធតែអ្នកមកពីកន្លែងផ្សេង?

**ឆ៖** អាន៎ុងសុទ្ធតែមកពីកន្លែងផ្សេងពូ ក្រសួងការបរទេសដកតែខ្ញុំមួយសិន អង្កាល់ហ្នឹងវាទើបនឹងបង្កើតដែរ វាទើបដកខ្ញុំចូលនៅបម្រើភ្ញៀវទើបបានប៉ុន្មានខែដែរ។ ហើយដល់ពេលខ្ញុំខុស គេដកខ្ញុំទៅហ្នឹង គឺខ្ញុំក៏មិនទាន់ស្គាល់គេដែរ។ ដូចទើបបានៗប៉ុន្មានថ្ងៃហ្នឹង។ ប៉ុន្មាន ថាបីខែចុះ ដល់យូរទៅស្គាល់ៗយូរភ្លេចឈ្មោះអស់ហើយ មិនដឹងពីណាៗខ្លះ។ អស់ហើយលោកពូ។

[១៤:០២:៤៨]

**សៈ** តើគេប្រាប់លោកទេថា ពួកនុំងមកពីណា? ពួកហ្នឹងធ្វើការនៅឯណាដែរមុនពេលមក តាខ្មៅហ្នឹង?

[១៤:០២:៥៦]

**ឆៈ** មុនមក អង្កាល់ហ្នឹងខ្ញុំសួរគេដែរ អាខ្លះដកមកពីកន្លែងកងចល័ត អាខ្លះដកមកពី--អើថា ខ្លះប្រវត្តិគេល្អ គេថាដកមកពីជនបទអ៊ីចឹងណ៎ាពូ ពីខេត្តអ៊ីចឹងទៅ មកចូលរួមកន្លែងហ្នឹង។ មុនដំបូង កន្លែងហ្នឹងជាកន្លែងលត់ដំគេ កន្លែងកសាងខ្លួន។ ដល់ពេលកសាងខ្លួនល្អអ៊ីចឹង គេយកមកចែកតាម ស្ថានទូតអី តាមមន្ទីរណាផ្សេងៗទៅ។ គេមានកន្លែងលត់ដំ កសាងខ្លួនដោយឡែកអាហ្នឹង។ អស់ហើយ លោកពូ។

**សៈ** ដោយសារតែពួកទាំងអស់ហ្នឹងត្រូវបានគេកសាង អ៊ីចឹងមានន័យថាអ្នកទាំងអស់ហ្នឹងត្រូវ បានគេបន្ទោសដោយសារមានប្រព្រឹត្តកំហុសអីដូចជាលោកអ៊ីចឹងមែនទេ?

[១៤:០៣:៥១]

**ឆៈ** ដូចតែគ្នា មានទោស មានខុស បានគេយកដាក់កន្លែងហ្នឹង។ យកមកនៅកន្លែងកសាងៗ ខ្លួនកន្លែងហ្នឹង គេថាអ៊ីចឹងតែប៉ុណ្ណឹងទេលោកពូ។ បើអាចខ្ញុំដឹង បើអាចខ្ញុំយល់ ថាកន្លែងកសាងខ្លួន កន្លែងលត់ដំ ហ្នឹងពេលគេប្រជុំជីវភាពមួយអាទិត្យគេប្រជុំម្តង អាហ្នឹងគេណែនាំនៅកន្លែង។ ចប់ហើយ លោកពូ។

**សៈ** តើអ្នកដែលនៅទីនោះជាមួយលោកហ្នឹងមានអ្នកណាខ្លះបាត់ខ្លួនទេនៅក្នុងអំឡុងពេលដែល លោកធ្វើការនៅតាខ្មៅហ្នឹង?

**ឆៈ** កាលខ្ញុំនៅរយៈពេលមិនដល់បីខែមិនទាន់មានមិនឃើញទេ មិនទាន់មានអ្នកណាបញ្ជូនណា នៅ-- មានតែគេហៅប្រជុំ និងកសាង គេមិនទាន់ បាត់ខ្លួនមិនទាន់មានទេអាហ្នឹង។ ដល់ពេលខ្ញុំចេញផុត មកទៀត មិនដឹងម៉េចទៀត ដកខ្ញុំមកក្រសួងការបរទេសនៅភ្នំពេញវិញមក។ ខ្ញុំក៏អត់បានឃើញទេ ពូណ៎ា។ ចប់ពូ។

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកបំភ្លឺចំណុចមួយ ពីព្រោះថា នៅក្នុងចម្លើយ របស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ គឺឯកសារលេខ D280/18 នៅទំព័រទីប្រាំបួន ជាភាសាខ្មែរ, ទីប្រាំបួន ជាភាសាបារាំង និងប្រាំបី ជាភាសាអង់គ្លេស។ លោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “បាទ ពិតមែនហើយ ពួកហ្នឹងបានប្រព្រឹត្តកំហុស ហើយគេដាក់ទណ្ឌកម្មឲ្យដាំស្ពៃ។”

ហើយឥឡូវនេះ លោកនិយាយថា មិនមានអ្នកណាបាត់ខ្លួនទេ តើលោកកែប្រែអ្វីដែលលោកឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬក៏លោកនៅរក្សាចម្លើយដដែល? ហើយមានគេសម្លាប់ទៀតនៅក្នុងនុំងលោកបានឆ្លើយថា "ពួកទាំងនុំង អ្នកខ្លះត្រូវបានសម្លាប់ចោល"។

[១៤:០៦:០២]

**ឆ៖** អាហ្នឹងចម្លើយខ្ញុំកាលខ្ញុំថា ដក អាជ្រឹង ទៅខ្ញុំវាអត់ដឹង មិនដឹងដកទៅកន្លែងណា ប៉ុន្តែដល់ពេលខ្ញុំមកដល់តាខ្មៅវិញ នៅកន្លែងតាខ្មៅ ក៏ខ្ញុំ-- នៅជាមួយខ្ញុំ គេលត់ដំកន្លែងហ្នឹង ក៏ខ្ញុំវាមិនបានតាមដានគេទៀតដែរកន្លែងហ្នឹង។ ប៉ុន្តែដល់ អាជ្រឹង ដឹងតែដកទៅហើយហ្នឹង ប៉ុន្តែដឹងតែដកទៅពូ មិនដឹងដកទៅត្រង់ណា ដូចនិយាយលើកមុនអ៊ីចឹងណ៎ា ព្រោះខ្ញុំមិនសូវដឹង សូវយល់ ពិបាកពេកពូណ៎ា។ សូមចប់ពូ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងគណៈប្រតិភូបរទេសគឺភ្ញៀវបរទេស លោកបាននិយាយថា លោកបានជូនភ្ញៀវទៅទស្សនកិច្ចក្នុងប្រទេសគឺ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ តើភ្ញៀវទាំងអស់មកពីប្រទេសណាខ្លះ ដែលលោកបានជូនទៅធ្វើទស្សនកិច្ចនោះ?

**ឆ៖** ខ្ញុំបានជូនភ្ញៀវមើល៍ ទៅលេងនៅតាកែវម្តង ដូចទៅអីដូច កំពង់សោមដូចទៅម្តងដែរយ៉ាង។ ខ្ញុំទៅបានតែបីដងទេ ស្របក់ខ្ញុំជូនភ្ញៀវលោកពូ ខ្ញុំនៅបានប៉ុន្មានខែប៉ុន្មានឆ្នាំហ្នឹង បានបីដងជូនភ្ញៀវទៅលេងតាកែវ ទៅជាមួយគេអ្នកបើកឡានជាមួយភ្ញៀវហ្នឹង យើងទៅបម្រើគេអាហ្នឹងណ៎ា។ អស់ហើយលោកពូ។

[១៤:០៧:៤៤]

**ស៖** ខ្ញុំចង់សួរថា ភ្ញៀវដែលលោកបានជូនហ្នឹង តើគាត់មកពីប្រទេសណា? ហើយមានសញ្ជាតិអ្វីខ្លះ?

**ឆ៖** កាលខ្ញុំជូនទៅ កូរ៉េផង ចិន គុយបា វៀតណាមនេះក៏មានដែរ ហ្នឹងដាក់ទូត ដាក់ប៉ុន្មានទូតប្រាំពីរប្រាំបីទូត ឬក៏ដប់ទូត ប្រាំពីរទូតនោះ ព្រោះខ្ញុំវាមិនបានដើរដែរលោកពូ។ ប៉ុន្តែតាមខ្ញុំស្គាល់ខ្ទង់ប្រាំមួយប្រាំពីរទូត ដូច គុយបា ទូតវៀតណាម ចិន កូរ៉េ ដឹងប៉ុន្មានទៀតទេ ដាក់ខ្ញុំស្គាល់មិនអស់។ ចប់ហើយលោកពូ។

**ស៖** នៅពេលដែលលោកជូនភ្ញៀវគណៈប្រតិភូ តើអ្នកណាដែលមានឋានៈធំជាងគេនៅក្រសួង

ការបរទេស ដែលជូនដំណើរគណៈប្រតិភូទាំងអស់នេះដែរ? លោកបានជូនភ្ញៀវ ប៉ុន្តែខ្ញុំចង់ដឹងថាតើអ្នកណាខ្លះផ្សេងទៀត ដែលជាកម្មាភិបាលជាន់ខ្ពស់របស់ក្រសួងការបរទេស ដែលជូនដំណើរផងនោះ តើលោកដឹងទេមានអ្នកណាខ្លះ?

[១៤:០៩:១០]

**ឆ៖** អង្គាល់ហ្នឹង បងហុង ជូនទៅ ប៉ុន្តែតាម អាភឿង វានិយាយថា ដូចអង្គាល់ទៅអង្គាល់ហ្នឹង ដូច ខៀវ សំផន ទៅដែរក៏មិនដឹងលោកពូ ព្រោះខ្ញុំដូចអត់បានទៅអាថ្ងៃហ្នឹង អាថ្ងៃទៅហ្នឹង ខ្ញុំអត់បានទៅខ្ញុំ តែបើ បងហុង ដឹងតែទៅហើយ មិនដឹងទៅប៉ុន្មាននាក់។ គេទៅទស្សនកិច្ចលោកពូអ្នំា ឲ្យខ្ញុំនៅចាំកន្លែងថ្ងៃហ្នឹង។ ដល់ថ្ងៃមួយនោះ ខ្ញុំជូនភ្ញៀវទៅទៀត ទៅដល់ទៅៗ អេ៎ ទៅកំពង់ធំ អ្អែទៅណាមិនដឹង។ ទៅដល់ហ្នឹងភ្ញៀវគេឈប់ដេកនៅហ្នឹង ហើយភ្ញៀវគេសួរពីសហករណ៍ប្រជាជន ឲ្យហូបបាយហូបអីហ្នឹង ហូបបបរហ្នឹងលោកពូអ្នំា ដល់ហើយខ្ញុំក៏វាមិនប៊ានឆ្លើយដែរ នឹកឃើញម៉្យាងអាពួកម៉ាកឯងក៏មិនទុកចិត្ត ខ្លាចលោគេរាយការណ៍ធ្វើបាបខ្លួនឯងទៅ។ ប្រាប់ភ្ញៀវ ក៏គ្រាន់ងក់ក្បាល គ្រាន់ធ្វើដៃអ៊ីចឹង ខ្ញុំអង្គាល់នុ៎ងវាយើងមិនចេះភាសាគេនោះ ប៉ុន្តែអាមួយបកប្រែគេថា សួរពីសហករណ៍ហូបបាយបបរ ឬក៏ហូបបាយអី? ប៉ុន្តែខ្ញុំក៏ងក់តែក្បាល ខ្ញុំក៏អត់ប៊ាននិយាយដែរ។ នឹកឃើញខ្លាចមិនទុកចិត្តគ្នា ខ្លាចគេរាយការណ៍ប្រាប់ តែខ្ញុំនិយាយទៅ លោរាយការណ៍ប្រាប់អ្នកធំទៀតហ្នឹង មិនងាប់ខ្ញុំ។ អស់ហើយពូ។

**ស៖** សំណួរពីរចុងក្រោយ លោកសាក្សី ពាក់ព័ន្ធនឹងចំណុចនេះ។ តើលោកដឹងទេថា ភ្ញៀវបរទេសនុ៎ងមកធ្វើអីនៅប្រទេសកម្ពុជា ក្នុងអំឡុងពេលទស្សនកិច្ចរបស់ភ្ញៀវទាំងនោះៗ?

[១៤:១០:៥៦]

**ឆ៖** ទេ អង្គាល់ហ្នឹងខ្ញុំនៅក៏មិនយល់ដែរ។ មិនដឹងជានៅប្រទេសកម្ពុជាហ្នឹង គេដាក់ទូតមិនដឹងមូលហេតុអី ក៏គេមិនទាន់ពន្យល់ខ្ញុំឲ្យដឹងទេ នៅទេអង្គាល់ហ្នឹង។ មិនដឹងទិសដៅដាក់ទូតនៅខ្មែរ ក៏មិនដឹងអាម៉េច ក៏ខ្ញុំមិនយល់។ ខ្ញុំជាយុទ្ធជនក៏មិនប៊ានសួរដេញដើងគេ អាម៉េចៗក៏មិនប៊ានសួរទេពូ អត់ប៊ាន។ ចប់ហើយពូ។

**ស៖** ចំពោះអ្នកដែលលោកជូនទៅនោះ ថាជាអ្នកដែលធ្វើការនៅក្នុងស្ថានទូតបរទេស ឬក៏ជាអ្នកមកពីបរទេស ដែលមកទស្សនកិច្ចនៅកម្ពុជាហ្នឹងគឺថា ដូចជាមានរយៈពេលខ្លីអីអ៊ីចឹង?

**ឆ៖** ទៅម្ល៉ៃហ្នឹង ទៅបរទេស ទៅតែភ្ញៀវបរទេសហ្នឹង ហើយយើងអ្នកបម្រើ ដូចនារីទៅពីរនាក់អ៊ីចឹងទៅ ខ្ញុំទៅមួយទៅ។ អាហ្នឹងគេរើសនរណាគេដូចជាការងារគេល្អ មានគេចូលបក្ខជនអីអ៊ីចឹង

គេដកទៅអ៊ីចឹងទៅ។ ទៅតាមបម្រើភ្ញៀវបាយអីអ៊ំណា-- លោកពូណា។ សូមចប់។

[១៤:១២:២០]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកទៅទស្សនកិច្ចនៅតាកែវ ឬទៅកំពង់សោម ឬក៏ទៅខេត្តផ្សេងៗទៀត តើលោកមានឈប់ទេ? មានឈប់នៅកណ្តាលផ្លូវទេ? ឧទាហរណ៍ដូចទៅពីភ្នំពេញទៅកំពង់សោម ទៅតាកែវ អីអ៊ីចឹង លោកមានឈប់នៅពាក់កណ្តាលផ្លូវ ដើម្បីធ្វើទស្សនកិច្ចរោងចក្រ ឬក៏ការដ្ឋាន ឬក៏អត់មានឈប់ទេ គឺលោកទៅពីខេត្តមួយទៅខេត្តមួយ ទៅជាប់រហូតអត់មានឈប់សម្រាកទេ?

**ឆ៖** ដូចភ្ញៀវចេញទៅពី-- អ៎! ទស្សនកិច្ចទៅតាកែវ ចេញពីភ្នំពេញទៅតាកែវអ៊ីចឹង អត់មានឈប់ទេពូ អត់មានឈប់ទេ។ ម្យ៉ាងឈប់ទៅក្រែងលោវា-- ភ្ញៀវតែឈប់គេសួរហើយភ្ញៀវ។ ភ្ញៀវតែឈប់សួរហើយ សួរកន្លែងនេះអីៗ ធ្វើអីៗ សួរហើយ តែៗវាអត់ឈប់ទេ វាទៅដល់ទិសដៅវា។ ដូចដល់តាកែវឈប់តែម្តងអាហ្នឹង។ ដល់កន្លែងលេងឈប់តែម្តង។ អស់ហើយលោកពូ។

[១៤:១៣:៣៣]

**ស៖** សូមអរគុណលោកសាក្សី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ខ្ញុំគិតថា ឥឡូវនេះដល់វេនសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅមេធាវីតំណាងឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក ឡោ ជុនធី៖**

បាទសូមជម្រាបសួរអង្គជំនុំជម្រះ ហើយសូមជម្រាបសួរសហភាតាទាំងអស់ សូមជម្រាបសួរបងប្អូនដែលបានទស្សនានៅទីនេះ ហើយក៏ជម្រាបសួរដល់លោកសាក្សីផងដែរ។ ខ្ញុំបាទឈ្មោះ ឡោ ជុនធី ដែលជាមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណី។ ពេលនេះខ្ញុំបាទ សូមសួរទៅលោកតិចសំណួរទេ ព្រោះខាងសហព្រះរាជអាជ្ញា បានសាកសួរប្រហែលជាចង់អស់ហើយ។ ជាពិសេសគឺ ខ្ញុំចង់ដឹងពីបរិបទមួយចំនួនដែលហាក់បីដូចជា កាលពីខាងសហព្រះរាជអាជ្ញាបានសួរនោះ ហាក់បីដូចជាវាមិន

ទាន់បានច្បាស់។

**ស៖** អ៊ីចឹង ខ្ញុំសូមបញ្ជាក់ថា តើនៅពេលដែល នៅក្នុងឆ្នាំ១៩៧៥ហ្នឹង បានន័យថា នៅពេលដែលមុននឹងបែកឆ្នាំ៧៥ហ្នឹង តើលោកៗបាន លោកនៅកន្លែងណា? មុនបែក៧៥ តើលោកនៅៗកន្លែងណាដែរ?

**លោក ខឹម ងួន៖**

**ឆ៖** មុនឆ្នាំ៧៥ លោកពូ ខ្ញុំហ្នឹងនៅមិនទាន់បែក ខ្ញុំនៅភូមិភាគនិរតី-- អ៊ំ នៅនោះ នៅខេត្តតាកែវ នៅឈរជើង នៅធ្វើយុទ្ធជន ធ្វើឈ្លបនៅខេត្តតាកែវ លោកពូ។ ធ្វើប្រធាននៅហ្នឹង បាទ។

**ស៖** បាទ អរគុណ។ អ៊ីចឹង បានន័យថា មុន៧៥ គឺនៅតាកែវ ហើយខ្ញុំចង់ដឹងថា មុន៧៥ នៅតាកែវហ្នឹង បងធ្វើជាឈ្លប ឬមួយធ្វើជាទ័ព នៅពេលនុ៎ង?

[១៤:១៦:១៩]

**ឆ៖** ខ្ញុំនៅឈ្លបបានប្រហែលមួយខែ គេបញ្ជូនខ្ញុំមកទ័ពស្រុក លោកពូ មកនៅឈរជើងនៅខាងកើតតាកែវ ខាងកើតទីក្រុងរួមខេត្តតាកែវហ្នឹង នៅភូមិធន់មន់។ ចប់ហើយលោកពូ។

**ស៖** ហើយចំណុចមួយនោះដែលវាមិនច្បាស់គឺថា លោកថាពេលដែលបែកភ្លាម គេបានឲ្យប្រជាជនចេញពីក្រុងតាកែវ ហើយចេញពីក្រុងតាកែវ បានន័យថាចេញទៅក្រោយ។ ទៅក្រោយហ្នឹងទៅយ៉ាងម៉េច ទៅក្រោយហ្នឹង?

**ឆ៖** អង្កាល់បែកពីក្រុងតាកែវ ប្រជាជនជម្លៀសទៅក្រោយ ដូចខ្ញុំប្រាប់លោកពូ កាលពីថ្ងៃមុនអ៊ីចឹងថា ខ្ញុំបានឃើញដែរ-- អ្ហេះ! មិនបានឃើញទេ ឃើញអាពួកម៉ាកវាឃើញ ព្រោះខ្ញុំនៅខាងកើត គេបញ្ជូនមួយច្រកនៅខាងលិច អាជ្រុងអ៊ីចេះ គេបញ្ជូនមក គេចាប់ចង ចាប់អី បញ្ជូនមកច្រកហ្នឹងពូ តែខ្ញុំនៅខាងកើតនេះ ពួកម៉ាកខ្ញុំវានៅខាងលិច ឈ្មោះ អាធឿនៗ ហ្នឹង គេនៅខាងលិច នៅក្បែរខ្សែត្រៀមហ្នឹង។ ដល់ពេលវ៉ៃបែកហើយ គេដកមនុស្សមកក្រោយ ខ្ញុំក៏មិនបានឃើញចង ឬមួយដាក់ឡាន ក៏ខ្ញុំមិនទាន់បានឃើញ ប៉ុន្តែតាមចេញរយៈពេល-- ចេញពីទីក្រុងតាកែវ តាមខ្ញុំមើលឆ្ងាយបំផុតប្រហែលកន្លះគីឡូ បែបមានដាក់ឡាន តាមពួកហ្នឹងនិយាយចុងក្រោយដាក់ឡាន ប៉ុន្តែមិនដឹងឡានដល់ត្រឹមប៉ុន្មានខ្ញុំអត់ដឹងលោកពូ ពីព្រោះខ្ញុំៗនៅខាងខ្សែត្រៀមមុននេះ។

[១៤:១៧:៥១]

ដល់ពេលវ៉ៃហើយៗ គេដកខ្ញុំមកចូលនៅមន្ទីរស្រុកវិញ ហ្នឹងដូចខ្ញុំឆ្លើយពីលើកមុនអ៊ីចឹងថា ដកខ្ញុំ

មកមន្ទីរស្រុកវិញ។ គេ-- ដល់ដកខ្ញុំហ្នឹងហើយហើយ បានប្រហែលបានមួយខែ ហ្នឹងបានមួយខែ គេហៅខ្ញុំប្រជុំ ដកខ្ញុំឡើងមកទីក្រុងភ្នំពេញ លោកពូ។ ខ្ញុំសូមអស់តែប៉ុណ្ណឹង។

**ស៖** បាទ ចំណុចនេះ ខ្ញុំចង់ដឹងអ៊ីចេះ ព្រោះតាមចម្លើយរបស់បង គឺបានលើកឡើងថា នៅពេលជម្លៀសហ្នឹង ចេញហ្នឹងគឺមានការចាប់ ដូចជាទាហាន លន់ នល់ ចាប់អីអ៊ីចឹង ដាក់ឡើងឡានអី ថយក្រោយអ៊ីចឹង។ តើអាចំណុចដែលបងបានលើកឡើងហ្នឹង មានន័យថាម៉េច? គេចាប់ដាក់ ចងដាក់ឡានហ្នឹង ទាហាន លន់ នល់ ហ្នឹង?

[១៤:១៨:៤១]

**ឆ៖** អាហ្នឹង លោកពូ តាមខ្ញុំយល់ ខ្ញុំ-- តាមខ្ញុំយល់ទៅ តាមមើល មកពីអ្នកដឹកនាំធំៗហ្នឹងតាមមើល ព្រោះខ្ញុំវានៅក៏មិនដឹងអីដែរ ព្រោះខ្ញុំនៅក្មេង អើ! វាអង្កាល់វានៅ ច្រើនអាយុប្រាំមួយប្រាំពីរដណ្តប់ ប្រាំមួយដណ្តប់ទេ មិនទាន់ដឹង-- បានតាមខ្ញុំយល់ ឃើញថា តាមមើលដកថយក្រោយប្រជាជនបែបគេយកទុកមួយដុំអីតាមមើល។ ហើយគេចែកភាគ យកទៅក្រោយ ហើយខ្ញុំក៏មិនបានដឹងដែរ មិនបានដឹងតែឃើញទៅ ប៉ុន្តែតាមវិភាគក្នុងចិត្តថា បែបរឿងហ្នឹងប៉ុណ្ណឹងហើយ វាយកទៅទុកមួយដុំហើយ។ បាទ ចប់ហើយលោកពូ។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ដែលចំណុចសំខាន់ដែរ នៅពេលដែលព្រឹត្តិការណ៍ជម្លៀសហ្នឹង តាមចម្លើយរបស់បងបានថា នៅពេលជម្លៀស បើអ្នកណារឹងទទឹងអី គឺថាអាចគេបាញ់សម្លាប់ ឬមួយយ៉ាងម៉េច តើអាចំណុចហ្នឹង បងបានឃើញ ឬមួយយ៉ាងម៉េច?

**លោក សុន អរុណ៖**

សូមកាត់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! សាក្សីកុំអាល់ទាន់ឆ្លើបតបនឹងសំណួរ។ សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ សំណួរទាំងអស់នេះ សុទ្ធតែសំណួរនាំមុខ ពីព្រោះអី សាក្សីអត់ដឹងរឿងហ្នឹងទេ។ សាក្សីនៅទិសផ្សេង ហើយគេជម្លៀសទៅទិសផ្សេង។ ម្ល៉ោះហើយនាំមុខហ្នឹង សូមប្រឆាំង។

**លោក ឡោ ជុនធី៖**

ខ្ញុំៗសូមបញ្ជាក់លោកចៅក្រមបន្ថិច សំណួរនេះខ្ញុំមិនបាននាំមុខទៅលើសាក្សីនេះទេ ព្រោះដោយសារមានចម្លើយរបស់គាត់ បានឆ្លើយនៅក្នុងកំណត់ហេតុថា ពេលដែលជម្លៀសហ្នឹងគឺមានការចាប់ប្រជាជនដាក់ឡាន-- អំ ចាប់ទាហាន លន់ នល់ ដាក់ឡាន។ អ៊ីចឹងអានេះ គឺសំណួរហ្នឹងថាតើអាសំណួរហ្នឹងគាត់បានដឹងបានឃើញ ឬមួយយ៉ាម៉េច? មិនមែនជានាំមុខឲ្យគាត់ឆ្លើយនោះទេ។

[១៤:២០:៤២]

**ប្រធានអង្គជំនុំ៖**

ប្រសិនបើជាសំណួរដែលមានសំណួរចម្លើយមាននៅក្នុងកំណត់ហេតុ ដែលបានធ្វើចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ គឺមិនមែនជាសំណួរនាំមុខទេ។ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព ប៉ុន្តែមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិត្រូវបង្ហាញអត្តសញ្ញាណឯកសារ និងខ្លឹមសារនៃកំណត់ហេតុដែលខ្លួនមាន ដែលបានដកស្រង់នោះចេញពីឯកសារនៃឯកសារណាជាក់ច្បាស់។ មិនមែនលើកមកព្រាវ ដោយអត់មានឯកសារធ្វើជាមូលដ្ឋានសំអាងដូច្នេះទេ។

**លោក ឡោ ជុនធី៖**

បាទ ខ្ញុំសូមបន្តសំណួរបាទ។

[១៤:២២:០៤]

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំសូមបន្តបន្តិច គឺនៅអ្វីដែលពេលដែលលោកបាន គេឲ្យលោកមកធ្វើការនៅក្រសួងការបរទេសវិញ។ ថាតើអ្វីដែលលោកមកធ្វើការនៅក្រសួងការបរទេសហ្នឹង ពេលដែលលោកមកដំបូងតើលោកជួបៗនរណាគេដែលជាមេរបស់បង?

**លោក ខឹម ងួន៖**

**ឆ៖** អង្កាល់ខ្ញុំមកពីខេត្ត មកអឹមកទីក្រុងភ្នំពេញ នៅជាមួយភ្ញៀវមុនដំបូង ខ្ញុំមកនៅ-- គេដកខ្ញុំរៀននៅសាលាបច្ចេកទេស រៀនបច្ចេកទេសខេត្តកណ្ដាលវិញ លោកពូ ខ្ញុំក៏មិនទាន់បានដឹងមេមួយណាដែរ។ ប៉ុន្តែដឹងថាគេបើកវគ្គហ្នឹង អង្កាល់គេដកមកប្រាំមួយនាក់ មកៗរៀនសូត្រនៅហ្នឹង។ រៀនបានមួយអាទិត្យគេចែកខ្ញុំទៅតាមក្រសួងការបរទេស ខ្ញុំទៅនៅផ្ទះលេខ៧ លោកពូ។ សូមអស់ហើយពូ។

[១៤:២២:៥៩]

**ស៖** ខ្ញុំចូលទៅសំណួរមួយទៀត ដែលពាក់ព័ន្ធនឹងថាតើលោកបាននាំភ្ញៀវ ថាមានភ្ញៀវចិន ភ្ញៀវកូរ៉េ ភ្ញៀវវៀតណាម ភ្ញៀវអីហ្នឹង សួរថាតើនាំទៅកន្លែងណាខ្លះ?

**ឆ៖** ខ្ញុំបានទៅជាមួយនឹងភ្ញៀវបីដង លោកពូ ទៅដល់ភូមិ អ៊េ្ហ ទៅហ្នឹងដូចទៅខេត្ត ទៅដូច-- អ៊េ្ហ ចង់ភ្លេច ដូចទៅកំពង់សោម ខេត្ត ប៉ុន្តែតាកែវ ដឹងថាទៅម្តងហើយ។ ខ្ញុំបានទៅតែបីពូ ទៅហ្នឹងទិស ដៅគេអត់ឲ្យឈប់តាមផ្លូវទេ ទៅដល់-- អ៊េ្ហ ភ្ញៀវទៅម្តង ទៅជួបតាមផ្លូវ គេសួរពីសហករណ៍ ដូច និយាយប្រាប់លោកពូអំមិញអ៊ីចឹងណ៎ា។ ហើយសហករណ៍គេសួរហូបបាយ ហូបបបរហ្នឹង ហើយខ្ញុំ ដូចនិយាយវាពីរបីសាហើយ ថាមិនប៉ានរាយការណ៍ប្រាប់ភ្ញៀវទេ គ្រាន់តែងក់ក្បាលដូចអ៊ីចឹង។ ហើយ ដែលអ្នកដឹកនាំកំពូលផ្ទាល់នៅហ្នឹងមានតែ បងហុង ហើយអ្នកទៅជាមួយមិនដឹងពីណាខ្លះ ព្រោះខ្ញុំក៏-- គេឡើងជិះឡានផ្សេង ដូចគេនៅកន្លែងមន្ទីរកន្លែងផ្ទៃក្នុងសម្ងាត់គេអ៊ីចឹង គេឡើងជិះឡានទៅតែគ្នាគេ យើងម៉េចនឹងដឹង។ ព្រោះយើងយុទ្ធជន អត់ដែលបានដឹងទេលោកពូ សម័យហ្នឹង។ សូមអស់លោកពូ។

[១៤:២៤:២១]

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំផ្តោតទៅលើចំណុចមួយនោះ គឺថានៅពេលដែលពាក់ព័ន្ធថា គេ សង្ស័យលើបងថាខុស ឬមួយយ៉ាងណាហ្នឹង គឺវាពាក់ព័ន្ធហ្នឹងពេលដែលបងបាននាំភ្ញៀវទៅតាកែវ។ តាកែវជាស្រុករបស់បង មិនអ៊ីចឹង! បាទនៅពេលដែលនាំភ្ញៀវទៅដល់នោះ ហើយពេលនោះបងបានជួប បងប្អូន ឬមួយយ៉ាងម៉េច ទៅតាកែវ?

[១៤:២៤:៥៨]

**ឆ៖** ថ្ងៃទៅតាកែវ ជូនភ្ញៀវទៅលោកពូ គេអត់ៗឲ្យមានប្រជាជនមកមើលទេ មានតែកងចល័ត ហើយនិងទ័ពទេ។ កងចល័ត មានកងចល័តច្រើនជាងគេ មានតែកងចល័តពូ ហើយនិងនៅមន្ទីរ តាម មន្ទីរគេហៅមកមើលលោកពូណ៎ា មានតែកងចល័តទេ មើលច្រើន តែប្រជាជន ដូចទៅដែរទៅតិច។ ហ្នឹងខ្ញុំនៅក្នុងឡាន នៅក្បែរឡាន មិនប៉ានដើរ ទៅជាមួយភ្ញៀវ អើតមើលគេហ្នឹង ប៉ុន្តែ-- ព្រោះយើង មិនប៉ាននិយាយពូ។ ព្រោះមានអ្នកផ្ទៃក្នុងរបស់វា តាមដានរបស់ថា វាថា គេថាគិញសម្ងាត់មួយទៀត ណ៎ា។ ត្រង់ហ្នឹងវាមិនប៉ានពូ ត្រង់ហ្នឹងណ៎ា។ សូមអស់ពូ។

**ស៖** ខ្ញុំចង់លើកឡើងថា ចំណុចអ៊ីចេះ-- ចំណុចដែលគេបានដកបងពីក្រសួងការបរទេសទៅ តាខ្មៅនោះណ៎ា វាជាកំហុសមួយ។ តើវាកំហុសហ្នឹងវាពាក់ព័ន្ធនឹងបង ឬមួយយ៉ាងម៉េច? ពេលដែល លោកបងទៅដល់ខេត្តតាកែវ បានជួបបងប្អូន ឬមួយអត់ជួប?

**ឆ៖** ថ្ងៃខ្ញុំជូនភ្ញៀវទៅតាមកែវ វាជួបដូចអ្នកស្គាល់ អំ!មនុស្សនៅភូមិ វាធ្វើកងចល័តលោកពូ ដល់ហើយៗលោកពូ ជីដូនមួយខ្ញុំ អាមួយនោះវានៅសហករណ៍។ វានិយាយប្រាប់ថា ឥឡូវ បងភិន គេយកវ៉ៃចោលបាត់ហើយ បងងន។ ខ្ញុំថា វ៉ៃចោលរឿងអីអ្នា? ខ្ញុំក៏បានសួរអ៊ីចឹងវិញ។ ដល់ហើយ រយៈពេលប្រហែលបីបួនខែ ព្រោះអាហ្នឹងខ្ញុំអត់ប៊ាននិយាយប្រាប់អាណាពូ ទុកក្នុងខួរក្បាល អត់ប៊ានប្រាប់ទេលោកពូ អត់ប៊ានប្រាប់អ្នកណាម្នាក់អត់ប៊ានទេ។ ខ្ញុំទុកក្នុងខួរក្បាលរបស់ខ្ញុំ រយៈពេលប្រហែលបីខែបួនខែ ថាបីខែចុះ ហើយបួនខែ ចូលបួនចុះ។ ធ្វើអីហើយៗ នឹកក្នុងចិត្តថា អ៊ូ!អញ រឿងពិត អញរឿងហើយ ប៉ុនមិនប៊ានប្រាប់អ្នកណាទេ។ ព្រោះមាន-- ហ្នឹងរឿងហើយ។ ព្រោះមានបងប្អូនស្លាប់ នៅឯភូមិស្រុក ព្រោះអានោះនិយាយអ៊ីចឹងហើយ ហើយស្លាប់ហើយ។ ហើយគេដកខ្ញុំទៅនៅតាខ្មៅលោកពូ។ សូមអស់។

[១៤:២៧:០៧]

**ស៖** បាទ អរគុណច្រើន។ ហើយខ្ញុំសូមមួយសំណួរទៀត គឺថានៅពេលដែលបងនៅក្រសួងការបរទេសហ្នឹងគឺ មេផ្ទាល់របស់បង គឺលោក ហុង ហ្នឹង ហើយតើបងស្គាល់អ្នកណាផ្សេងពីលោក ហុង ដែលធំជាងលោក ហុង ហ្នឹងដែរអត់ទេ?

**ឆ៖** ខ្ញុំអាចឮឈ្មោះដែលលោកពូ ប៉ុន្តែឲ្យខ្ញុំប៊ានស្បថមុនអំពូលភ្លើង បើខ្ញុំស្គាល់ម្នាក់នោះទៀត ប៉ុន្តែឮសូរតែគេនិយាយ គេថាទៅជួបប្រជុំនៅមហោស្រព អាហ្នឹងឃើញ បងហុង គេមាននីវសារគេជូនទៅ ថានៅប្រជុំមហាស្រព ប្រជុំឯណាៗ បែបវាមានអ្នកធំដែលនុំង បងហុង ជាអ្នកក្តាប់ខ្ញុំផ្ទាល់ ខ្ញុំមិនបានដឹងទេពូណ៎ា មិនដឹងគេប្រជុំណាអត់ដឹងទេ ប៉ុន្តែវាមានអ្នកធំលើហ្នឹងមាន ប៉ុន្តែថាឮថា ខៀវសំផនៗ ប៉ុន្តែក៏ខ្ញុំមិនបានចាប់អារម្មណ៍សួរដេញដើងច្រើនអី បម្រើបានរយៈពេលបានប៉ុន្មាន វៀតណាមបុកចូល វាបែកត្រឹមហ្នឹង។ ចប់ត្រឹមហ្នឹងតែម្តង។ ខ្ញុំស្បថមុខភ្លើងនេះ ចប់ត្រឹមហ្នឹងតែម្តង។ ខ្ញុំឡើងភ្នំ ចប់ត្រឹមហ្នឹងតែម្តងលោកពូ។ ចប់ត្រឹមហ្នឹងតែម្តង។

[១៤:២៨:១៤]

**ស៖** បាទ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរ លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ លោកប្រធាន ខ្ញុំយល់ថាយើងពិបាកក្នុងការតាមដាន គឺសួរ ហើយឆ្លើយ ហើយសួរសំណួរ ហើយដែលបានសួរនេះ ដោយមេធាវី គឺសហព្រះរាជអាជ្ញាបានសួរអស់ទៅហើយ។ វាហាក់ដូចជាខាតពេលវេលាទេការបែបនេះ ហើយប្រហែលថាលោកមេធាវីប្រហែលមើលសួរសំណួរណាដែលទាក់ទងផ្ទាល់ចំពោះសាក្សីរូបនេះ ដែលជាផ្នែកសហព្រះរាជអាជ្ញាមិនបានសួរ។ ដោយសារថា សំណួរចុងក្រោយនេះ គឺសហព្រះរាជអាជ្ញាបានសួររួចហើយ គឺកាលពីថ្ងៃព្រហស្បតិ៍មុន។ ហើយៗយើងសួរបែបនេះមិនមានផលប្រយោជន៍នោះទេ ប្រសិនបើយើងធ្វើឱ្យមានប្រសិទ្ធភាព គឺថាអាចបញ្ចប់សាក្សីនេះថ្ងៃនេះបានបើសិនជាសួរទៅតាមនីតិវិធីដែលច្បាប់តម្រូវនោះបាទ។

[១៤:២៩:១៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ប៉ុន្តែលោកមេធាវីគប្បីធ្វើការជំទាស់ភ្លាមៗ ហើយបង្ហាញពីមូលហេតុខ្លីៗទៅបានហើយ ដើម្បីឱ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានពិចារណាសម្រេច។ យើងទទួលស្គាល់ការគ្រប់គ្រងសវនាការដ៏ធំធេងរបៀបនេះ ការគ្រប់គ្រងសំណួរច្រំដែល នេះគឺជារឿងមួយលំបាក មិនមែនជាការងាយទេ ដោយការសួរដេញដោលច្រើន វែង ហើយនិងប្រើប្រាស់ពេលវេលាឆ្លាស់គ្នាច្រើនពេល ច្រើនថ្ងៃទៀតនោះ។ អ៊ីចឹង ភាគីដែលមានសិទ្ធិតាមបទវិធានដែលចែងជាក់ច្បាស់អំពីសិទ្ធិជំទាស់ទៅនឹងការតាំងសំណួរចំពោះភាគីដទៃទៀត គឺអង្គជំនុំជម្រះនឹងត្រៀមស្ដាប់នូវការលើកឡើងការជំទាស់ ប៉ុន្តែគប្បីការជំទាស់នោះ គឺបង្ហាញអំពីមូលហេតុខ្លីៗដែលសមស្រប និងអាចឱ្យតុលាការ ឱ្យអង្គជំនុំជម្រះនោះទទួលយកមកវិនិច្ឆ័យបានភ្លាមៗតែម្ដង។ នេះជាការអរគុណណាស់ ទន្ទឹមហ្នឹងក៏អង្គជំនុំជម្រះក៏បានគិតគូរអំពីបញ្ហានេះ ដោយឆន្ទានុសិទ្ធិដែរ ប៉ុន្តែហេតុផលគឺវាមានបញ្ហាស្រដៀងគ្នា ទីមួយ។

ទីពីរ អង្គជំនុំជម្រះបានរម្លឹកភាគីញឹកញាប់ហើយ ថាគប្បីប្រើប្រាស់នូវការតាំងសំណួរដែលមានសក្ដានុពល ពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ចំពោះជនជាប់ចោទ នៅក្នុងដីកាដំណោះស្រាយ ហើយសូមឱ្យវែកញែកឱ្យច្បាស់លាស់ក្នុងការតាំងសំណួរសាក្សី កុំដាក់ថាសាក្សីជាជនជាប់ចោទ។ សាក្សីគឺជាផ្ដល់សក្ខីកម្មចំពោះអង្គហេតុទាំងឡាយណាដែលមានប្រយោជន៍ មានព័ត៌មានពាក់ព័ន្ធទៅនឹងអំពើទៅនឹងបទល្មើស ទៅនឹងអង្គហេតុដែលចោទប្រកាន់ចំពោះជនជាប់ចោទ។ រំឭកច្រើនលើក ច្រើន

សារួចហើយ ប៉ុន្តែនៅតែមានបញ្ហាដដែល។

[១៤:៣១:០២]

អង្គជំនុំជម្រះក៏ព្យាយាមដែរ មិនចង់កាត់មិនចង់អីទេ ប៉ុន្តែគួរតែត្រូវបានគិតគូរដោយខ្លួនឯងនៅក្នុងបច្ចេកទេសនៅកិច្ចដំណើរការតាំងសំណួរដេញដោលចំពោះសាក្សី ឬក៏ចំពោះគោលដីនៃការតាំងសំណួរផ្សេងទៀត ដើម្បីឱ្យការសន្សំពេលវេលា និងការប្រើប្រាស់ពេលវេលាដែលបានចែកឱ្យ ដោយមានប្រសិទ្ធភាព។

បាទ ឥឡូវនេះអង្គជំនុំជម្រះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់-- អ៎! ម៉ោងបី ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឱ្យអញ្ជើញគាត់មកត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣២នាទី ដល់ម៉ោង ១៤:៥១ នាទី)*

[១៤:៥១:៤២]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយអម្បាញ់មិញនេះ គឺអង្គជំនុំជម្រះបានផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិពីមេធាវីនាំមុខរួចហើយ ហើយទំនងជាមិនមានសំណួរសួរទៀតទេ។ នៅមានទេ?

សូមអញ្ជើញលោកមេធាវី! ហើយចៀសវាងឱ្យផុតនូវការតាំងសំណួរឯណា ដែលច្បាប់ហាម

ឃាត់ សំណួរច្រំដែល សំណួរដឹកមុខ សំណួរឧបមាណវិធី សំណួរក្រៅអង្គហេតុនេះ ដើម្បីជំរុញល្បឿនកិច្ចដំណើរការនីតិវិធី គួរតែត្រូវគិតគូរ ចៀសវាងការជំទាស់ពីភាគីដទៃ ដើម្បីសន្សំពេលវេលា និងប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព។

[១៤:៥៣:២៨]

**លោក បាណាបេ ណេគ្រី៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំជាមេធាវីអាជីព ពេលដែលខ្ញុំក្រោកឡើងនោះ ខ្ញុំដឹងអំពីកាតព្វកិច្ចដែលយើងត្រូវធ្វើហើយ។ ដូច្នេះ ខ្ញុំសូមឲ្យភាគីទាំងអស់គ្នា កុំបារម្ភ ហើយនិងយើងខ្ញុំនិយាយឲ្យជាក់លាក់ ហើយយើងនឹងមិននិយាយនូវដដែលៗអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងហើយនោះទេ។

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សីខ្ញុំចង់ចោទសំណួររបស់លោក ពីរបីសំណួរជាបន្តទៀត។ សំណួរទីមួយ គឺថាតើនៅសម័យនោះ លោកស្គាល់នារីម្នាក់ដែលមានឈ្មោះថា ធី “T-H-Y” ជាភាសាបារាំង។ អ៊ីចឹងគាត់ជាមនុស្សភេទស្រី នៅក្រសួងការបរទេស តើលោកស្គាល់អ្នកស្រីធី នុ៎ងទេ?

**លោក ខឹម ងន៖**

**ឆ៖** ខ្ញុំបាទខ្ញុំស្គាល់ នៅជាមួយខ្ញុំ មកប្រាជ្ញគ្នាមុនហ្នឹង នៅជាមួយខ្ញុំហ្នឹង មិត្តធី ហ្នឹងនៅជាមួយខ្ញុំ។ ចប់ហើយលោកពូ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ តើលោកចាំអ្វីដែលគាត់និយាយប្រាប់លោកទាក់ទងទៅនឹងការបោសសម្អាត ដែលកើតមានឡើងនៅមន្ទីរ ប-១ នៅសម័យនោះដែរឬទេ?

**ឆ៖** កាលពីសម័យ ខ្ញុំនៅ ប-១ ហ្នឹងដូចខ្ញុំនិយាយពីលើកមុនអ៊ីចឹងលោកពូ អារឿងវាបោសសម្អាត ចោទប្រកាន់អីៗហ្នឹង ដូចថា វា-- ខ្ញុំដូចនិយាយលើកមុនអ៊ីចឹងមិនសូវយល់ មិនដឹងអាចម៉េចអាហ្នឹង។ សូមអស់ហើយបង។

**ស៖** បាទ លោកសាក្សី ខ្ញុំប្រើពាក្យបោសសម្អាត។ ខ្ញុំចង់សួរថា មានការចាប់ខ្លួនដែរឬទេ? តើលោកដឹងមានការចាប់ខ្លួននៅមន្ទីរប-១ ដែរឬទេ កាលពីសម័យនោះ?

**ឆ៖** កាលពីសម័យនុ៎ងខ្ញុំ ខាងផ្នែកប-១ ខ្ញុំអាចបើគេចាប់ខ្លួន ខ្ញុំមិនសូវដឹងទេ ព្រោះមន្ទីរខុសគ្នាប៉ុន្តែពួកខ្ញុំនៅផ្ទះលេខ៧នេះ។ ហើយគេនៅផ្ទះន៎ែ ប-១ ជួនណាវាមកធ្វើការជាមួយខ្ញុំទៅវាមិនសូវនេះ

ដល់ពេលគេដកអ្នកណាចេញ ក៏ខ្ញុំមិនបានដឹងណ៎ា លោកពូណ៎ា។ ដូចខ្ញុំនិយាយសាមុនអ៊ីចឹងអត់បានដឹងទេ អាហ្នឹងព្រោះដកទៅណា អត់បានដឹងទេ បើថានៅកន្លែងខ្ញុំអាចដឹងបានខ្លះ វាមិនសូវប៉ិនមានសិទ្ធិដើរអាហ្នឹង។ អស់ហើយលោកពូ។

[១៤:៥៦:២៥]

**ស៖** បាទ លោកសាក្សី ដើម្បីរំឭកការចងចាំរបស់លោក ខ្ញុំសូមអានចម្លើយរបស់លោកដែលឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៩។

**លោក បាណាបេ ណេគ្រី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានសម្រង់នេះ ទៅសាក្សីដែលមាននៅក្នុងឯកសារ D280/18 និងលេខ ERN ជាភាសាខ្មែរគឺ 00368622 ហើយជាភាសាបារាំង 00426456, ជាភាសាអង់គ្លេស 00375680។ បាទ ខ្ញុំសូមអនុញ្ញាតអានសម្រង់នេះ ហើយនិងសូមអនុញ្ញាតបញ្ចាំងទៅលើអេក្រង់ផងដែរ ដើម្បីជាជំនួយដល់-- អាចជួយឲ្យសាធារណជនអាចតាមដានបានល្អ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៤:៥៧:៣៥]

**លោក បាណាបេ ណេគ្រី៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី នៅក្នុងកិច្ចសម្ភាសន៍នេះលោកបាននិយាយថា គេសួរលោកដូចតទៅនេះ៖ “ក្រៅពី ជ្រឹង ហើយនិង ធន់ តើមានការចាប់ខ្លួនរបស់អ្នកដទៃទៀតដែរឬទេ?” លោកបានឆ្លើយថា “ខ្ញុំមិនដែលឃើញមានការចាប់ខ្លួនអ្នកដទៃទេ ក៏ប៉ុន្តែខ្ញុំដឹងថា មានការបាត់ខ្លួននៅមន្ទីរប-១”។ ហើយបន្ទាប់មកទៀតគេសួរទៀតថា “នៅកន្លែងផ្សេងៗទៀតនោះ តើលោកដឹងថាមានការចាប់ខ្លួនដែរឬទេ?” លោកនិយាយថា “ធី ស្រី បាននិយាយប្រាប់ខ្ញុំថា បានឃើញមានការចាប់មនុស្សនៅក្រសួងការបរទេស ហើយប៉ុន្តែនៅក្នុងក្រសួងផ្នែកផ្សេងៗទៀតពីផ្នែករបស់ខ្ញុំ”។ សំណួររបស់ខ្ញុំ ថាតើអាចឲ្យលោកចាំបានដែរឬទេ សម្រង់ដែលខ្ញុំលើកឲ្យលោកនេះ? ហើយលោកមានការអត្ថាធិប្បាយអីធ្វើទៅលើសម្រង់ដែលខ្ញុំទើបតែនឹងអាននេះបានដែរឬទេ?

[១៤:៥៨:៤១]

**ឆៈ** ខ្ញុំវាអត់យល់លោកពូ កន្លែងហ្នឹង។ អត់យល់បង។

**សៈ** លោកសាក្សីខ្ញុំនិយាយថា ទី-- អង្គាល់នុះលោកនិយាយប្រាប់ទៅសហចៅក្រមស៊ើបអង្កេតថា ធី បានប្រាប់លោកថា មានការចាប់ខ្លួនមនុស្សនៅក្នុងក្រសួងការបរទេស ក៏ប៉ុន្តែមិនមែននៅក្នុងផ្នែករបស់លោកទេ។ តើលោកបាននិយាយពាក្យទាំងអស់នេះ ពាក្យពេចន៍ទាំងអស់នេះទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆៈ** មិត្ត ធី ដែលខ្ញុំនេះហ្នឹង អង្គាល់នៅជាមួយខ្ញុំ ដល់ពេលដកទៅខ្ញុំសួរវាទៀតថា វាឃើញ។ ហើយដក អាជ្រឹង ដូចខ្ញុំនិយាយពីដើមដំបូងថា ដកជ្រឹង អ៊ីចឹងចេញទៅវាប្រាប់ខ្ញុំទៅ ហើយមិនវាយកទៅណាក៏មិនដឹងលោកពូ។ ខ្ញុំវានិយាយទៅ វាភ្លេចមុខ ភ្លេចក្រោយធ្វើម៉េចទេពូ។ សូមអស់ៗហើយ។

[១៤:៥៩:៥០]

**សៈ** បាទ លោកសាក្សីយើងខ្ញុំមិនសង្កត់ធ្ងន់លើកន្លែងនេះទៀតទេ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកចម្លើយមួយរបស់លោក ប្រហែលជាចំណុចចុងក្រោយហើយ ដែលខ្ញុំនឹងនិយាយជាមួយលោកទាក់ទងទៅនឹងការអប់រំដែលលោកបាន-- អប់រំទាក់ទងនឹងបដិវត្តន៍ដែលលោកបានទទួល។ កាលពីសប្តាហ៍មុនលោកបាននិយាយថា អ្វីដែលលោកចាំអំពីការបណ្តុះបណ្តាលនោះថា ការធ្វើបដិវត្តន៍គឺប្រឆាំងតស៊ូដើម្បីសេរីភាព។ តើលោកចាំចម្លើយនេះរបស់លោកដែរឬទេ?

**ឆៈ** ដូចភ្លេចហើយលោកពូកន្លែងហ្នឹងខ្ញុំ។ ចម្លើយហ្នឹងខ្ញុំពិបាក-- ហាក់បីដូចជាចម្លើយដែរហ្នឹង ដូចភ្លេចហើយពូ ធ្វើម៉េចទេ។

**សៈ** បាទ លោកសាក្សី ដោយខ្ញុំសង្កេតឃើញថា លោកក៏បែបជាអស់កម្លាំងខ្លាំង ហើយលោក-- គេក៏បានប្រាប់យើងហើយថាលោកផ្តាសាយ។ អ៊ីចឹងខ្ញុំមិននិយាយសង្កត់ធ្ងន់អីទៀតទេ។

**លោក បាណាបេ ណេគ្រី៖**

អ៊ីចឹងខ្ញុំសូមបញ្ចប់ការចោទសំណួរទៅសាក្សីនៅពេលនេះ។ ហើយសូមឲ្យភាគីខាងការពារក្តីនោះគេបន្តការចោទសំណួរទៅលើគាត់ទៀត។ បាទ សូមអរគុណលោកប្រធាន។

[១៥:០១:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវី

ការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកមានអារម្មណ៍ ឬក៏មានកម្លាំងថាអាចបន្តទៅបានទេ?

**លោក ខឹម ងន៖**

**ឆ៖** បាន លោកពូបានអត់អីទេ បាន។

**ស៖** សូមអរគុណ។ សូមសរសើរលោកដែលបានឆ្លើយនេះ។ តើលោកចាំទេលោកសាក្សី ដែលគេសម្ភាសលោកដោយតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីឆ្នាំ២០០៤ បាទ?

[១៥:០២:១៧]

**ឆ៖** ខ្ញុំអត់យល់ទេ លោកពូអើយ។ អត់យល់។

**ស៖** តើលោកនៅចាំថាបានពិភាក្សា ឬក៏និយាយអ្នកណាម្នាក់អំពីការងាររបស់លោកនៅសម័យខ្មែរក្រហមទេ ក្នុងឆ្នាំ២០០៤ ដែលលោកបានផ្តល់ការសម្ភាសទៅគេយ៉ាងវែង គឺអ្នកនោះមកពីមជ្ឈ-មណ្ឌលឯកសារកម្ពុជា ហៅថា ឌី.ស៊ី.ខេម លោកនៅចាំទេ?

**ឆ៖** ហ្នឹងកាលរស់នៅជាមួយគ្នាបានចាំ អ្នកដឹកនាំដូច បងហុង, អាភឿង, អាណា ការរស់នៅវាហ្នឹង។ ខ្ញុំមិនចេះទេបង មិនយល់។ មិនចេះឆ្លើយខ្ញុំ។

**លោក ម៉ៃខល ផេសមិន៖**

ប្រហែលជាខ្ញុំត្រូវសួររំឭកការចងចាំរបស់លោកឡើងវិញ។ ហើយខ្ញុំចង់បង្ហាញចម្លើយដែលគាត់បានឆ្លើយទៅអង្គការ មជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៤ គឺឯកសារហ្នឹងគឺលេខ IS19.72។ ហើយខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញទៅសាក្សី ឬក៏ខ្ញុំអានជូនសាក្សីឲ្យសាក្សីស្តាប់។ ហើយចម្លើយរបស់គាត់ហ្នឹងចាប់ផ្តើមឡើងខ្មែរ ERN លេខ 00067425, អង់គ្លេស ERN 00800073 នៅខាងចុង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមុននឹងដាក់ឯកសារដេញដោលហ្នឹង សូមលោកបង្ហាញនូវលក្ខណៈនៃឯកសារនេះ

តើឯកសារនេះបានលើកយកមកដាក់ៗនៅចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ហើយបើដាក់ពីពេលណាមក? ដើម្បីបង្ហាញអំពីលក្ខណៈនៃការសមស្របនូវឯកសារ ដែលស្នើសុំដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក ម៉ៃខល ផេសមិន៖**

បាទ តាមពិតលោកប្រធាន យើងបានពិនិត្យមើលឯកសារនេះពីមុន គឺថាឯកសារនេះគឺជាឯកសារសំខាន់ គឺអាចមានផ្ទុកនូវការពិត ហើយសាក្សី ហើយភាគីទាំងអស់គឺយើងយកឯកសារនេះមកបង្ហាញការពិត ខ្ញុំចង់ប្រើឯកសារនេះ ដើម្បីសួរផ្ទាល់សាក្សីរូបនេះ។ ចម្លើយរបស់គាត់--

[១៥:០៥:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះចង់ដឹងថា តើលោកបង្ហាញនូវការដាក់ឯកសារនេះ ចំពោះមុខអង្គជំនុំជម្រះ ហើយឬនៅ? ហើយអង្គជំនុំជម្រះហ្នឹងបានសម្រេចទទួលយកតាមនីតិវិធី នៃវិធាន៨៧ រួចហើយឬនៅ? លោកត្រូវរៀបរាប់ ហើយឆ្លើយនឹងសំណួររបស់យើង ពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារនៅក្នុង នៅចំពោះមុខអង្គសវនាការនេះ។ មិនមែនសំខាន់លើខ្លឹមសារ វាជាក់ច្បាស់ ឬមិនជាក់ច្បាស់នោះទេ សំខាន់គឺអនុវត្តទៅតាមនីតិវិធី នៃវិធាន៨៧(៤) និង ៨៧(៣) ហើយនិងសេចក្តីណែនាំរបស់អង្គជំនុំជម្រះបន្តបន្ទាប់កន្លងមក។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសេចក្តីសោកស្តាយណាស់ ដែលថានីតិវិធីដែលអង្គជំនុំជម្រះសម្រេចហ្នឹងគឺថា យើងខ្ញុំចង់ស្វែងរកការពិតនៃឯកសារនេះ ត្រូវបានដាក់នៅក្នុង*អ៊ីនធីហ្វេស*របស់តុលាការ ដូចដែលលោកជ្រាបហើយគឺថា យើងដាក់ចូលក្នុងបញ្ចូលក្នុងបញ្ជីហើយក្នុងឆ្នាំ២០១១ ហើយឯកសារនេះ ខ្ញុំជឿថា នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញារួចទៅហើយ ហើយតុលាការបានទទួលយករួចមកហើយ ដោយអង្គជំនុំជម្រះសាលាដំបូងនេះ បាទ តាមដែលខ្ញុំដឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា! មានអីការបញ្ជាក់ បន្ថែមលើបញ្ហានេះទេ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទលោកប្រធាន ការពិតណាស់ឯកសារ IS19.72 នេះគឺជាឯកសារតែមួយ វាមានលេខ

យោងសម្រាប់ជីវប្រវត្តិ ហើយនិងការសម្ភាសនៅចំពោះមុខ ស៊ី.ឌី.ខេម ហើយជាបញ្ជីដែលយើងបញ្ជូននៅឆ្នាំ២០១១។ ហើយយើងពុំមានលេខរៀងនៅក្នុងតារាងរបស់នោះទេ ក៏ប៉ុន្តែយើងបានដាក់ជូនទៅអង្គជំនុំជម្រះហើយៗ។ បាទ សូមអរគុណលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៩:០៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដោយសារមានព័ត៌មានសមល្មមដែលនឹងអាចជឿបានហើយ ដោយសារខាងតំណាងសហព្រះរាជអាជ្ញា បានបញ្ជាក់អំពីបញ្ហានេះហើយ។ ប៉ុន្តែអង្គជំនុំជម្រះ សូមជម្រាបរំឮកឡើងវិញជូនដល់ក្រុមមេធាវីការពារក្ដី លោក នួន ជា ជាពិសេសលោក ម៉ៃខល ផេសមិន សូមលោកចាប់ពីពេលអំណើះតទៅ ប្រសិនបើមានឯកសាររបៀបនេះ សូមលោកបង្ហាញជាមុននូវប្រភេទលក្ខណៈជាឯកសារដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយដោយមានមូលហេតុ និងសំអាងហេតុត្រឹមត្រូវ ដើម្បីអង្គជំនុំជម្រះសម្រេច មិនមែនចាប់ផ្ដើមសួរតែម្ដងនោះទេ។

សូមអញ្ជើញ!

[១៥:១០:០០]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី ខ្ញុំចង់អានផ្នែកមួយនៃចម្លើយរបស់លោក ដែលខ្ញុំជឿថាលោកបានឆ្លើយទៅឲ្យតំណាងរបស់អង្គការ ឌី.ស៊ី.ខេម កាលពីឆ្នាំ២០០៤។ នៅចំណុចមួយនោះលោកបាននិយាយអំពីអង្គប្រជុំ ដែលបានធ្វើឡើងនៅកាលនោះ នៅប-១ ហើយនិងការប្រជុំនៅកន្លែងផ្សេងៗទៀតដែរ គឺជាពិសេសប្រជុំរបស់មេដឹកនាំថ្នាក់ខ្ពស់។ ខ្ញុំសូមដកស្រង់ចម្លើយរបស់លោក គឺផ្នែកមួយដែលគូសនៅលើអេក្រង់នេះបាទ។ សំណួរគេសួរថា៖ "នៅពេលដែលលោកធ្វើការនៅទីនោះ នៅប-១ ថាតើលោកបានឃើញមេដឹកនាំខ្ពស់ៗហ្នឹងញឹកញាប់ប៉ុនណា ដែលមកប្រជុំ? លោកឆ្លើយថា៖ មានការប្រជុំច្រើន។ សួរ៖ ប្រជុំច្រើនដងរាប់មិនអស់ទេ? ងាកប្រជុំៗ? លោកឆ្លើយថា៖ ហ្នឹងហើយងាកប្រជុំៗ។ បន្ទាប់មកលោកបន្តទៅទៀតថា៖ បាទ តើលោករាប់មន្ត្រីធំៗហ្នឹងបានទេ? ហើយលោកនិយាយថា៖ តាម៉ុក,

អៀង សារី១, ខៀវ សំផន ហើយច្រើនណាស់អ្នកធំ។ សំណួរ៖ ចុះ នួន ជា ម៉េចដែរ? លោកឆ្លើយថា៖ នួន ជា នៅទីនោះដែរ។ និយាយដោយសង្ខេប គឺ ហ៊ុន សែន ក៏អីហ្នឹង។ ប៉ុល ពត អីឃើញទេ? ឃើញទាំងអស់តាយើងទាំងអស់ហ្នឹង ហើយខ្ញុំឃើញតាយើងទាំងអស់ដែរ ហ្នឹងហើយ។ លោកឆ្លើយ។ សួរ៖ ពូឃើញតានៅឆ្នាំណា? លោកឆ្លើយថា៖ ខ្ញុំភ្លេចហើយ គឺខ្ញុំឃើញឆ្នាំ៧៥ ឬតាំងពី៧៤ទៅ។ សំណួរ៖ លោកនិយាយថា សម្តេចសីហនុឬ? លោកឆ្លើយថា៖ តាំងពីឆ្នាំ១៩៧៤។ ចុះសម្តេចតាចូលរួមប្រជុំដែរឬទេ? លោកឆ្លើយថា៖ ហ្នឹងហើយ តា ហ៊ុន សែន យើង។ សំណួរ៖ អ៊ំ លោកនិយាយថា ហ៊ុន សែន មិនមែនសម្តេចតា សីហុន ទេ។ លោកឆ្លើយថា៖ មិនមែនទេ ខ្ញុំឃើញតា សីហនុ ក៏ឃើញផងដែរនៅក្នុងភ្នំពេញ នៅក្នុងសង្គម ប៉ុល ពត។ សំណួរ៖ តាសែន ចូលរួមប្រជុំ ដែលប្រជុំឬទេ? ឆ្លើយ៖ តាហ្នឹងចូលរួមយូរមកហើយ គឺមុនពេលអ្នកផ្សេងៗទៀត។ សំណួរ៖ ថាមុនឆ្នាំ៧៤ឬ? ឆ្លើយ៖ ហ្នឹងហើយ។

[១៥:១២:៥៦]

សួរ៖ ពូឃើញនៅឯណា? សម័យគាត់តស៊ូហ្នឹង។ នេះចម្លើយរបស់លោក។ សំណួរ៖ ពូឃើញនៅឯណាដែលគាត់ចូលប្រជុំហ្នឹង? លោកឆ្លើយថា៖ កាលគាត់នៅប្រជុំនៅព្រៃមិនដឹងនៅស្អីទេ គ្នាគាត់ប៉ុន្មាននាក់ទេ ខ្ញុំស្គាល់អ្នកធំៗប៉ុន្មាននាក់ដែរ ប៉ុន្តែឥឡូវភ្លេចអស់ហើយ ខ្ញុំនៅក្មេងអង្គាល់ហ្នឹង។ សំណួរ៖ តើ តាសែន កាលហ្នឹងគាត់អាយុប៉ុន្មាននៅពេលដែលគាត់មកប្រជុំ? ឆ្លើយ៖ តាហ្នឹងកាលហ្នឹងអាយុយ៉ាងច្រើនណាស់២០ជាង បែប២០ជាង ៣០ហើយកាលហ្នឹង នៅក្មេង។ ខ្ញុំនៅក្មេង ខ្ញុំបែកពីម៉ែអាយុ១៦, ១៧ ឆ្នាំ គាត់ខ្ទង់អាយុ២៥ ឬ៣០ឆ្នាំ។ សំណួរ៖ តើឃើញហ្នឹងថានៅជិតដាច់ឆ្នាំ១៩៧៨ ឬ៧៩ ឬទេ? សំណួរ អ៊ំ ចម្លើយ៖ ហ្នឹងហើយ។ សំណួរ៖ មិនមែនក្នុងអំឡុងឆ្នាំ១៩៧៥, ៧៦ ទេ? ឆ្លើយ៖ មិនមែនទេ"។

ឥឡូវនេះដល់សំណួរទីមួយរបស់ខ្ញុំ ថាតើលោកចាំថាលោកបានឆ្លើយទៅនឹងសំណួរទាំងហ្នឹងទេ? ហើយបើមែន តើចម្លើយទាំងអស់ហ្នឹងត្រឹមត្រូវដែរឬទេ?

**លោក ខឹម ងន៖**

**ឆ៖** ចម្លើយខ្ញុំដូចអត់ទេលោកពូ ខ្ញុំមិនដែលឆ្លើយអ៊ីចឹង ខ្ញុំមិនដែលដឹង មិនដែលដឹងប្រវត្តិហ្នឹងផងហ្នឹង។ ខ្ញុំអត់ អត់ដឹងទេអាហ្នឹង។ មិនមែនឯកសាររបស់ខ្ញុំមិនដឹង មិនដឹងផងហ្នឹង បើបញ្ចូលខ្ញុំជឿនិយាយអ៊ីចឹងអត់ទេ។ អត់មានទេលោកពូ ខ្ញុំ -- តាមស្តាប់សំណួរ គ្មានទេ វាខុសសេចក្តី-- ខុសសេចក្តីខ្ញុំដែលខ្ញុំរស់នៅធម្មតាវាខុស ខ្ញុំ-- អាគេអ្នកចេះអក្សរ គេចេះតែបញ្ចេញបញ្ចូល ចម្លើយខ្ញុំមិនដែលអ៊ីចឹង

មិនដែលទេ។ ចប់ហើយលោកពូ ចប់ហើយ។

**ស៖** តើលោកចាំទេថាលោកបានជជែកជាមួយអ្នកណាម្នាក់អំពីរឿងហ្នឹង អំពីការប្រជុំហ្នឹងកាលពីឆ្នាំ២០០៤ នោះណា?

**ឆ៖** ២០០៤ ទេ វាខុសនឹងសំណួរខ្ញុំឆ្លើយ លោកពូ វា-- ២០០៤ ខ្ញុំទៅប្រជុំពិភាក្សាអីគ្មានទេ។ *(ឮមិនច្បាស់)* វាគ្មានទេ តាមសំណួរហ្នឹង។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយថាមិនដឹងរួចហើយ មេធាវីបន្តទៅសំណួរផ្សេងទៀត ដែលមិនមែនជាសំណួរអ្វីដែលលោកលើកយកកម្រងសំណួរយ៉ាងវែងមកសួរសាក្សីនោះ ពីព្រោះសាក្សីបានឆ្លើយច្បាស់ហើយ ថាខ្លួនគាត់មិនដឹងទេ។

[១៥:១៦:៤១]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើលោកបានឃើញថាមានការប្រជុំដែលលោក ហ៊ុន សែន ចូលរួមទេនៅក្នុងឆ្នាំ១៩៧០ មុនឆ្នាំហ្នឹង ឬក៏ក្រោយឆ្នាំហ្នឹង ឬក៏ក្រោយរំដោះភ្នំពេញឆ្នាំ១៩៧៥?

**លោក ខឹម ងួន៖**

**ឆ៖** បើលោកឯងសួរពីជំនាន់៧០ ខ្ញុំច្រើន ខ្ញុំកម្តស់នេះហ្នឹង ខ្ញុំមិនទាន់ដឹងប្រវត្តិហ្នឹងទេ។ បើខ្ទង់៧៥ ឬមួយ៧៤ ខ្ញុំអាចដឹងខ្លះ បើចំពោះពី ៧០មក ខ្ញុំអត់ដឹងលោកពូ។ ដល់សំណួរអត់ដឹង អាហ្នឹងអត់ដឹងសំណួរហ្នឹង ឆ្លើយម៉េចរួច ឆ្លើយតាមខ្ញុំដឹង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តាំងសំណួរផ្សេងទៀត ដែលមិនមែនជាកម្រងសំណួរដែលលោកអានយ៉ាងវែងអម្បាញ់មិញទេ។ យើងមិនអនុញ្ញាតឲ្យលោកតាំងសំណួរដដែលនេះទៀតទេ ពីព្រោះសាក្សីបានឆ្លើយបញ្ជាក់ច្បាស់លាស់ហើយ។

[១៥:១៧:៤៩]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** សាក្សី តើលោកខ្លាចក្នុងការឆ្លើយទាក់ទងទៅនឹងការចូលរួមប្រជុំរបស់លោក ហ៊ុន សែន ដែលថាក្នុងសម័យដែលលោកធ្វើការនោះ សម័យខ្មែរក្រហមនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ! ព្រោះសាក្សីបានឆ្លើយមិនដឹងរួចហើយ។ ហើយសំណួរនេះមិនពាក់ព័ន្ធទេ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំយល់ថា សំណួរនេះគឺមានការពាក់ព័ន្ធ ដោយសារសាក្សីនេះគឺថាចម្លើយរបស់គាត់ដែលគាត់ឆ្លើយទៅ ឌី.ស៊ី.ខេម នោះគឺថា លោក ហ៊ុន សែន ហ្នឹងបានចូលរួមក្នុងការប្រជុំថ្នាក់ខ្ពស់មួយចំនួន ដែលថាមានកូនក្តីរបស់ខ្ញុំចូលរួមប្រជុំទាំងនោះផង។ ដូច្នេះសាក្សីរូបនេះ គឺថាអាចនិយាយបញ្ជាក់ពេលនេះ តើគាត់និយាយកាលពីឆ្នាំ២០០៤ ហ្នឹងជាការពិតដែរអត់ ដែលថាមានលោក ហ៊ុន សែន បានចូលរួមក្នុងប្រជុំថ្នាក់ខ្ពស់ជាមួយកូនក្តីរបស់ខ្ញុំ។ ដូច្នេះ ព័ត៌មាននេះសំខាន់។ ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីសួរបន្តទៅទៀតបាទ។

[១៥:១៩:០៣]

**ប្រធានអង្គជំនុំ៖**

សូមលោកសំណួរសួរសំណួរ កម្រងសំណួរអម្បាញ់មិញនេះ យើងមិនឲ្យសាក្សីឆ្លើយទេ។ បើមានសំណួរផ្សេងទៀត យើងនឹងអនុញ្ញាត ប្រសិនបើយើងយល់ថាចាំបាច់ស្តាប់នូវចម្លើយរបស់សាក្សី។ ពីព្រោះសំណួរមិនពាក់ព័ន្ធផង ហើយនិងសាក្សីគាត់ឆ្លើយថាមិនដឹងជាទូទៅចំពោះកម្រងសំណួរដែលលោកបានលើកឡើងអម្បាញ់មិញនេះ។ ហើយតាមកម្រិតជាក់ស្តែងនៃសម្តីរបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ ធៀបជាមួយនឹងកំណត់ហេតុធ្វើដែលលោកយកមកអានអម្បាញ់មិញនេះមិនទំនងជាស៊ីសង្វាក់គ្នានៃផ្ទុះបញ្ចាំងអំពីសមត្ថភាពសាក្សីរូបនេះអាចឆ្លើយដូចអ៊ីចឹងបានទេ។

[១៥:២០:០០]

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំមិនបានដឹងទេ បើសិនជាឲ្យសាក្សីឆ្លើយទើបបានយើងដឹងលោកប្រធាន ដើម្បីគាត់បញ្ជាក់ថា តើលោក ហ៊ុន សែន នោះគាត់បានពាក់ព័ន្ធក្នុងការប្រជុំជាមួយកូនក្តីរបស់ខ្ញុំដែរឬមិនមែន។ បើសិនជាសាក្សីមិនឆ្លើយ ឬក៏អង្គជំនុំជម្រះមិនឲ្យឆ្លើយ យើងមិនអាចរកការពិតនៅកន្លែងនេះឃើញទេ។

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយទេសាក្សី ពីព្រោះសាក្សីបានឆ្លើយរួចហើយ ថាអត់ដឹង អត់អីទេនៃលើបញ្ហាទាំងអស់នេះ។ ពត៌មានទាំងអស់នេះ ខ្លួនមិនដឹងទេ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមិនឃើញថាៗ បើមិនអនុញ្ញាតឲ្យយើងខ្ញុំសួរសំណួរសំខាន់ៗទេ ហាក់ដូចជាប៉ះពាល់ដល់សិទ្ធិរបស់កូនក្តីរបស់ខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បើនៅមិនអនុញ្ញាតខ្ញុំហាក់ដូចជាមិនអាចសួរអ្វីបានទៅទៀតទេ បាទ។

[១៥:២១:០១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីផ្សេងទៀត ប្រសិនបើក្រុមមេធាវីការពារក្តីលោក នួន ជា អស់សំណួរហើយ។

សូមអញ្ជើញមេធាវីការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សួស្តីសហភាតា ព្រះរាជអាជ្ញា សួស្តីលោកអ្នកទាំងអស់ចូលរួមសវនាការក្នុងបន្ទប់ ឬនៅក្រៅបន្ទប់ក្តី។

សួស្តីលោក ខឹម ងន។ ខ្ញុំ អាង ឧត្តម សហមេធាវីរបស់លោក អៀង សារី ហើយពេលនេះយើងខ្ញុំគ្មានសំណួរសួរលោកទេ។ ប៉ុន្តែយ៉ាងណាក្តី តាងនាមលោក អៀង សារី យើងខ្ញុំ ខ្ញុំ ហើយនិងសហភាតារបស់ខ្ញុំ គឺលោក ម៉ៃខល កាណាវាស សូមអរគុណលោក ដែលបានឡើងមកថ្លែង ហើយមកឆ្លើយសំណួរ ដើម្បីជូនតុលាការ ជួយតុលាការក្នុងការស្វែងរកការពិត និងយុត្តិធម៌។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

[១៥:២២:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ តាងនាមក្នុងនាមក្រុមមេធាវីរបស់លោក ខៀវ សំផន អត់មានសំណួរសម្រាប់សាក្សីនេះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចំពោះការបង្ហាញជំហរច្បាស់លាស់ក្នុងការមិនមានសំណួរដេញដោលចំពោះសាក្សីរូបនេះ។

ឥឡូវនេះកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី ខឹម ងន ឃើញថាដល់ទីបញ្ចប់ហើយ។ ហើយអង្គជំនុំជម្រះអស់មានសំណួរសួរដល់-- ត្រូវសួរដេញដោលចំពោះលោកទៀតហើយ លោក ខឹម ងន។ ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងបានខិតខំអស់ពីបញ្ញាស្មារតី ដែលខ្លួនមានតាមសមត្ថភាព និងលទ្ធភាពដែលអាចឆ្លើយតបបាន ឆ្លើយតបនឹងការអញ្ជើញកោះហៅរបស់អង្គជំនុំជម្រះ ក៏ដូចជាការតបទៅនឹងសំណួរដេញដោលពីភាគីដែលពាក់ព័ន្ធនៃរឿងក្តី។ ហើយដោយការដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកចប់ហើយនោះ។ ដូច្នេះ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏ទីកន្លែងគោលដៅដែលលោកចង់ទៅបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញសម្របសម្រួលផ្តល់មធ្យោបាយដឹកជញ្ជូនសាក្សីត្រឡប់ទៅកាន់លំនៅដ្ឋានគាត់វិញ។

ហើយសូមឲ្យលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៥:២៤:០២]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមនឹងសម្រាកដែរហើយ។ ដោយនៅសល់ពេលវេលាបន្តិចបន្តួចមែន ប៉ុន្តែយើងបានចប់មុនផែនការដែលបានគ្រោងទុក។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការចាប់បន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១២ ខែមិថុនា ឆ្នាំ២០១២។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា កិច្ចដំណើរការសវនាការនៅព្រឹកថ្ងៃស្អែក គឺបន្តស្តាប់សក្ខីកម្មសាក្សី សៅ សារុន ដែលនឹងតាំងសំណួរដេញដោលបន្តដោយតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលសិទ្ធិពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះក៏សូមជម្រាបជូនផងដែរថា កិច្ចដំណើរ

ការស្តាប់សក្ខីកម្មសាក្សីនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះអាចនឹងដំណើរការស្តាប់សក្ខីកម្មឆ្លាស់គ្នារវាងសាក្សី ឈ្មោះសៅ សារុន និងសាក្សីម្នាក់ទៀតដែលមានរហស្សនាម TCW-488 វាអាស្រ័យទៅលើស្ថានភាពសុខភាពជាក់ស្តែងរបស់សាក្សី។

[១៥:២៥:១១]

ហើយ-- បាទ ឥឡូវនេះ គឺអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ទី១២ ខែមិថុនា ឆ្នាំ២០១២ ដោយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:២៥ នាទី)*